(ក) អាចត្រូវបានគ្រប់គ្រងដោយរដ្ឋាភិបាលឬស្ថាប័នរដ្ឋាភិបាលមួយ ហើយនឹងត្រូវបានរាយការណ៍នៅក្នុងរបាយការណ៍ចំណូលនិងចំណាយសាច់ប្រាក់ដោយអនុលោមតាម ផ្នែកទី ១ នៃស្តង់ដានេះ និង

(ខ) គឺជាប្រតិបត្តិការដែលត្រូវបានគ្រប់គ្រង ដែលមិនត្រូវបានរួមបញ្ចូលនៅលើផ្នែមុខនៃរបាយការណ៍ចំណូលនិងចំណាយសាច់ប្រាក់ ឬរបាយការណ៍ហិរញ្ញវត្ថុផ្សេងទៀតដែលអាចត្រូវបានរៀបចំឡើង ប៉ុន្តែលើកទឹកចិត្តឱ្យមានការលាតត្រដាងបន្ថែម។

**ការប្រមូលប្រាក់ចំណូល**

២.១.៩ ស្ថាប័នសាធារណៈអាចគ្រប់គ្រងសាច់ប្រាក់ ឬគ្រប់គ្រងចំណូលឬចំណាយសាច់ប្រាក់ជំនួសឱ្យរដ្ឋាភិបាលឬរដ្ឋាភិបាលផ្សេងទៀត ឬស្ថាប័នរដ្ឋាភិបាល។ ឧទាហរណ៍ នាយកដ្ឋានពន្ធដាររបស់រដ្ឋាភិបាល (ឬភ្នាក់ងារប្រមូលប្រាក់ចំណូល) អាចត្រូវបានបង្កើតឡើងដោយមានគណនីធនាគារផ្ទាល់ខ្លួន និងផ្តល់នូវវិភាជន៍មួយដើម្បីផ្តល់មូលនិធិដល់ប្រតិបត្តិការរបស់ខ្លួន។ ប្រតិបត្តិការរបស់នាយកដ្ឋាន នឹងរួមបញ្ចូលនូវការគ្រប់គ្រងផ្នែកជាក់លាក់នៃច្បាប់ពន្ធដារ និងអាចមានការប្រមូលពន្ធជំនួសរដ្ឋាភិបាល។

២.១.១០ នាយកដ្ឋានពន្ធដារអាចប្រើទឹកប្រាក់ដែលបានធ្វើវិភាជន៍និងដាក់បញ្ចើនៅក្នុងគណនីធនាគារដែលខ្លួនគ្រប់គ្រងដើម្បីសម្រេចបាននូវគោលបំណងប្រតិបត្តិការទៅតាមអាណត្តិរបស់ខ្លួន ហើយអាចមិនរាប់បញ្ចូលនូវបុគ្គលដទៃ ចំពោះការប្រើ ឬការទទួលបានអត្ថប្រយោជន៍ពីសាច់ប្រាក់នោះឡើយ។ នៅក្នុងករណីទាំងនេះ នាយកដ្ឋាននឹងគ្រប់គ្រងសាច់ប្រាក់ដែលបានធ្វើវិភាជន៍ សម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួន។ ទោះបីជាយ៉ាងណា សាច់ប្រាក់ដែលនាយកដ្ឋានប្រមូលបានជំនួសឱ្យរដ្ឋាភិបាលតាមរយៈសកម្មភាពនៃការប្រមូលពន្ធរបស់ខ្លួន គឺតែងត្រូវបានដាក់បញ្ចើនៅក្នុងមូលនិធិបរធនរបស់រដ្ឋាភិបាលជាក់លាក់មួយ ឬត្រូវបានផ្ទេរទៅកាន់គណនីធនាគាររបស់រដ្ឋាភិបាលមួយដែលបានគ្រប់គ្រងដោយរតនាគារ ឬនាយកដ្ឋានប្រហាក់ប្រហែល។ នៅក្នុងស្ថានភាពទាំងនេះ សាច់ប្រាក់ដែលបានប្រមូល មិនអាចត្រូវបានប្រើប្រាស់

ដើម្បីគាំទ្រដល់ការសម្រេចបានគោលបំណងរបស់នាយកដ្ឋានពន្ធដារ ឬក៏ត្រូវបានប្រើប្រាស់ទៅតាមសេចក្តីសម្រេចរបស់ថ្នាក់ដឹកនាំរបស់នាយកដ្ឋានដោយគ្មានវិភាជន៍ជាក់លាក់ ឬការផ្តល់សិទ្ធិផ្សេងទៀតដោយរដ្ឋាភិបាល ឬស្ថាប័នពាក់ព័ន្ធឡើយ។ ដូច្នេះ សាច់ប្រាក់ដែលបានប្រមូលមិនត្រូវបានគ្រប់គ្រងដោយនាយកដ្ឋានពន្ធដារ និងមិនបង្កើតជាផ្នែកមួយនៃចំណូលសាច់ប្រាក់ ឬសមតុល្យសាច់ប្រាក់របស់នាយកដ្ឋាននោះទេ។ ជាលទ្ធផលនៃការសម្រេចចិត្តរបស់រដ្ឋាភិបាល ចំនួនសាច់ប្រាក់ដែលប្រមូលបានមួយចំនួន អាចត្រូវបានធ្វើវិភាជន៍ ឬក៏ត្រូវបានបែងចែកសម្រាប់ការប្រើប្រាស់ដោយនាយកដ្ឋាន។ ទោះបីជាយ៉ាងណា វាស្ថិតនៅលើការសម្រេចចិត្តរបស់រដ្ឋាភិបាល ដើម្បីផ្តល់សិទ្ធិនៃការចំណាយមូលនិធិដោយនាយកដ្ឋានពន្ធដារ ជាជាងការប្រមូលសាច់ប្រាក់ដែលនាំឱ្យមានការគ្រប់គ្រង។

២.១.១១ ស្ថានភាពប្រហាក់ប្រហែលអាចកើតឡើងនៅពេលរដ្ឋាភិបាលមួយ ឧទាហរណ៍ រដ្ឋាភិបាលថ្នាក់ក្រុង ឬថ្នាក់មូលដ្ឋាន ប្រមូលសាច់ប្រាក់ជំនួសឱ្យរដ្ឋាភិបាលដទៃ (ដូចជា រដ្ឋាភិបាលថ្នាក់ជាតិមួយ)។ នៅក្នុងករណីទាំងនេះ រដ្ឋាភិបាលកំពុងដើរតួនាទីជាភ្នាក់ងារមួយជំនួសឱ្យបុគ្គលដទៃក្នុងការប្រមូលសាច់ប្រាក់។ សាច់ប្រាក់ដែលកើតឡើងជាលទ្ធផលនៃការគ្រប់គ្រងប្រតិបត្តិការក្នុងនាមជាភ្នាក់ងារមួយជំនួសឱ្យបុគ្គលដទៃនឹងមិនជារឿយៗត្រូវបានដាក់បញ្ចូលនៅក្នុងគណនីធនាគាររបស់ភ្នាក់ងារប្រមូលឡើយ ហើយដូច្នេះនឹងមិនបង្កើតជាផ្នែកមួយនៃចំណូលសាច់ប្រាក់ ចំណាយសាច់ប្រាក់ ឬសមតុល្យសាច់ប្រាក់របស់ស្ថាប័នរាយការណ៍ឡើយ។

**លំហូរសាច់ប្រាក់ "ឆ្លងកាត់"**

២.១.១២ នៅក្នុងករណីមួយចំនួន កិច្ចសម្រុះសម្រួលផ្នែករដ្ឋបាលទាក់ទងនឹងសកម្មភាពប្រមូលចំណូលដែលរដ្ឋាភិបាលឬស្ថាប័នរដ្ឋាភិបាលបានធ្វើក្នុងនាមជាភ្នាក់ងារមួយរបស់ភាគីដទៃ អាចឱ្យសាច់ប្រាក់ត្រូវបានដាក់បញ្ចូលជំបូងនៅក្នុងគណនីធនាគារផ្ទាល់របស់ស្ថាប័ន មុនពេលសាច់ប្រាក់ត្រូវបានផ្ទេរទៅកាន់គម្យជនចុងក្រោយ។ លំហូរសាច់ប្រាក់ដែលបានកើតឡើងជាលទ្ធផលនៃប្រតិបត្តិការទាំងនេះគឺពេលខ្លះត្រូវបានគេហៅថា លំហូរសាច់ប្រាក់ "ឆ្លងកាត់"។ នៅក្នុងករណីទាំងនេះ ស្ថាប័ននឹង÷

(ក) គ្រប់គ្រងសាច់ប្រាក់ដែលខ្លួនប្រមូលបានក្នុងសមត្ថភាពខ្លួនជាភ្នាក់ងារសម្រាប់រយៈពេលខ្លីដែលសាច់ប្រាក់ត្រូវបានដាក់បញ្ចូលនៅក្នុងគណនីធនាគាររបស់ស្ថាប័ន មុនពេលផ្ទេរទៅកាន់ភាគីទីបី

(ខ) តែងទទួលបានអត្ថប្រយោជន៍ពីការប្រាក់ណាមួយ ដែលកើតឡើងពីចំនួនទឹកប្រាក់ដែលបានដាក់បញ្ចូលនៅក្នុងគណនីដែលនឹងផ្តល់ការប្រាក់ មុនពេលផ្ទេរទៅកាន់ស្ថាប័នដទៃ និង

(គ) មានកាតព្វកិច្ចមួយដើម្បីផ្ទេរសាច់ប្រាក់ដែលប្រមូលបានទៅកាន់ភាគីទីបី ដោយអនុលោមតាមលក្ខខណ្ឌចាំបាច់នៃច្បាប់ ឬកិច្ចសម្រុះសម្រួលផ្នែករដ្ឋបាល។

នៅពេលលំហូរចូលនៃសាច់ប្រាក់ពីប្រតិបត្តិការដែលត្រូវបានគ្រប់គ្រង ឆ្លងកាត់គណនីធនាគារមួយដែលបានគ្រប់គ្រងដោយស្ថាប័នរាយការណ៍ នោះចំណូលសាច់ប្រាក់, ការផ្ទេរសាច់ប្រាក់ និងសមតុល្យ

សាច់ប្រាក់ដែលកើតឡើងពីសកម្មភាពនៃការប្រមូល នឹងត្រូវបានរួមបញ្ចូលនៅក្នុងរបាយការណ៍ចំណូលនិងចំណាយសាច់ប្រាក់របស់ស្ថាប័ន ដោយអនុលោមតាមកថាខណ្ឌ ១.៣.៤ (ក)នៃ ផ្នែកទី ១ នៃស្តង់ដានេះ។ កថាខណ្ឌ ១.៣.១៣ (ក) នៃផ្នែកទី ១ នៃស្តង់ដានេះបានបញ្ជាក់ថា ចំណូលនិងចំណាយសាច់ប្រាក់ដែលកើតឡើងពីប្រតិបត្តិការដែលស្ថាប័នគ្រប់គ្រងជំនួសឱ្យភាគីដទៃទៀត និងដែលត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ អាចត្រូវបានរាយការណ៍តាមមូលដ្ឋានសុទ្ធ។

**ការផ្ទេរកញ្ចប់ចំណាយ**

២.១.១៣ ដោយមានសង្គតិភាពជាមួយនឹងគោលបំណងរបស់រដ្ឋាភិបាលនិងជាមួយអង្គនីតិបញ្ញត្តិ ឬស្ថាប័នដទៃ ចំនួនទឹកប្រាក់ដែលត្រូវបានធ្វើវិភាជន៍ទៅកាន់ស្ថាប័នរដ្ឋាភិបាលមួយ (នាយកដ្ឋាន, ភ្នាក់ងារ ឬស្ថាប័នប្រហាក់ប្រហែល) អាចរួមបញ្ចូលនូវចំនួនទឹកប្រាក់ដែលត្រូវផ្ទេរទៅកាន់ភាគីទីបីទាក់ទងនឹង ឧទាហរណ៍ អត្ថប្រយោជន៍នៃភាពគ្មានការងារធ្វើ, អាយុ ឬប្រាក់សោធនដែលផុតសុពលភាព, វិភាជន៍គ្រួសារ, និងចំណាយអត្ថប្រយោជន៍សហគមន៍និងសន្តិសុខសង្គមផ្សេងទៀត។ នៅក្នុងករណីមួយចំនួន ចំនួនទឹកប្រាក់ទាំងនេះនឹងឆ្លងកាត់គណនីធនាគារមួយដែលគ្រប់គ្រងដោយស្ថាប័ន។ នៅពេលករណីនេះកើតឡើង ស្ថាប័ននឹងទទួលស្គាល់សាច់ប្រាក់ដែលបានធ្វើវិភាជន៍សម្រាប់ការផ្ទេរនៅក្នុងអំឡុងការិយបរិច្ឆេទរាយ-ការណ៍ថាជាចំណូលសាច់ប្រាក់, ចំនួនទឹកប្រាក់ដែលបានផ្ទេរនៅក្នុងអំឡុងការិយបរិច្ឆេទនោះជាចំណាយសាច់ប្រាក់និងចំនួនទឹកប្រាក់ដែលបានរក្សាទុកនាចុងគ្រាការិយបរិច្ឆេទសម្រាប់ការផ្ទេរនាពេលអនាគតជាផ្នែកនៃសមតុល្យសាច់ប្រាក់ចុងគ្រា។

**ការលាតត្រដាងផ្លាកចម្បងៗនៃលំហូរសាច់ប្រាក់**

២.១.១៤ *ស្ថាប័នមួយត្រូវបានលើកទឹកចិត្តឱ្យលាតត្រដាង នៅលើផ្នែកមុខនៃរបាយការណ៍ចំណូលនិងចំណាយសាច់ប្រាក់ ឬរបាយការណ៍ហិរញ្ញវត្ថុផ្សេងទៀត ឬនៅក្នុងកំណត់សម្គាល់លើរបាយការណ៍ទាំងនោះនូវ÷*

*(ក) ការវិភាគអំពីចំណាយសាច់ប្រាក់សរុប ដោយប្រើចំណាត់ថ្នាក់មួយផ្អែកលើចរិកលក្ខណៈរបស់ចំណាយ ឬតួនាទីរបស់ពួកគេនៅក្នុងស្ថាប័នតាមភាពសមស្រប និង*

*(ខ) ចំណូលពីកម្ចី។ បន្ថែមពីនេះ ចំនួនកម្ចីអាចត្រូវបានធ្វើចំណាត់ថ្នាក់បន្តទៀតទៅតាមប្រភេទ និងប្រភព។*

២.១.១៥ ចំណាត់ថ្នាក់រងដែលបានលើកទឹកចិត្តនៅក្នុងកថាខណ្ឌ ២.១.១៤ (ក) អាចត្រូវបានដាក់បង្ហាញនៅលើផ្នែកមុខនៃរបាយការណ៍ចំណូលនិងចំណាយសាច់ប្រាក់ ដោយអនុលោមតាមលក្ខខណ្ឌចាំបាច់នៃកថាខណ្ឌ ១.៣.១២ នៃផ្នែកទី ១ នៃស្តង់ដានេះ។ នៅពេលដែលមូលដ្ឋានចំណាត់ថ្នាក់ផ្សេងមួយត្រូវបានប្រើនៅក្នុងរបាយការណ៍ចំណូលនិងចំណាយសាច់ប្រាក់ ការលាតត្រដាងបំបែកចេញពីគ្នាបន្ថែមដែលឆ្លុះបញ្ចាំងពីការលើកទឹកចិត្តនៅក្នុងកថាខណ្ឌ ២.១.១៤ (ក) ខាងលើ ត្រូវបានលើកទឹកចិត្តជារបាយការណ៍ដាច់ដោយឡែកមួយ ឬដោយមធ្យោបាយនៃកំណត់សម្គាល់។

២.១.១៦ គណនីចំណាយសាច់ប្រាក់ អាចត្រូវបានធ្វើចំណាត់ថ្នាក់រងបន្តដើម្បីធ្វើឱ្យប្រសើរឡើងនូវគណនេយ្យភាពតាមរយៈការកំណត់គោលបំណងចម្បងៗដែលចំណាយត្រូវបានធ្វើឡើង។ ចំណាយក៏អាចធ្វើចំណាត់ថ្នាក់រងដើម្បីគួសបញ្ជាក់ពីចំណាយ និងការស្រង់ដើមមកវិញនៃកម្មវិធី, សកម្មភាព, ឬផ្នែកពាក់ព័ន្ធជាក់លាក់ផ្សេងទៀតរបស់ស្ថាប័នរាយការណ៍។ ស្ថាប័នមួយត្រូវបានលើកទឹកចិត្តឱ្យដាក់បង្ហាញព័ត៌មាននេះនៅក្នុងយ៉ាងហោចណាស់មួយក្នុងចំណោមវិធីសាស្ត្រចំនួនពីរខាងក្រោម។

២.១.១៧ វិធីសាស្ត្រទីមួយត្រូវបានសំដៅលើចរិកលក្ខណៈនៃវិធីសាស្ត្រចំណាយ។ ចំណាយត្រូវបានសរុបបញ្ចូលគ្នានៅក្នុងរបាយការណ៍ចំណូលនិងចំណាយសាច់ប្រាក់ ដោយយោងទៅតាមចរិកលក្ខណៈរបស់វា (ឧទាហរណ៍ ការបញ្ជាទិញសម្ភារៈ, ចំណាយលើការដឹកជញ្ជូន, ប្រាក់ឈ្នួល និងប្រាក់ខែ) ហើយមិនត្រូវបានបែងចែកឡើងវិញនៅក្នុងចំណោមមុខងារផ្សេងៗគ្នាជាច្រើននៅក្នុងស្ថាប័នឡើយ។ ឧទាហរណ៍មួយនៃចំណាត់ថ្នាក់ ដោយប្រើចរិកលក្ខណៈនៃវិធីសាស្ត្រចំណាយ គឺមានដូចខាងក្រោម÷

| | ចំណាយសាច់ប្រាក់ |
|---|---|
| ប្រាក់ឈ្នួល និងប្រាក់ខែ | (X) |
| ចំណាយលើការដឹកជញ្ជូន | (X) |
| ការទិញមូលធន | (X) |
| បន្ទុកលើប្រាក់កម្ចី | (X) |
| ចំណាយផ្សេងៗ | (X) |
| ចំណាយសរុប | (X) |

២.១.១៨ វិធីសាស្ត្រទីពីរដែលសំដៅលើវិធីសាស្ត្រនៃការធ្វើចំណាត់ថ្នាក់តាមមុខងារ ធ្វើចំណាត់ថ្នាក់ចំណាយដោយយោងទៅតាមកម្មវិធី ឬគោលបំណងដែលចំណាយត្រូវបានធ្វើឡើង។ ការដាក់បង្ហាញនេះតែងតែផ្តល់នូវព័ត៌មានពាក់ព័ន្ធបន្ថែមចំពោះអ្នកប្រើប្រាស់ បើទោះបីជាការបែងចែកចំណាយទៅតាមមុខងារអាចធ្វើដោយឯកច្ឆ័ន ហើយអាចពាក់ព័ន្ធនឹងការវិនិច្ឆ័យដែលគួរយកមកពិចារណាក៏ដោយ។ ឧទាហរណ៍មួយនៃការធ្វើចំណាត់ថ្នាក់តាមមុខងារនៃចំណាយសាច់ប្រាក់ គឺមានដូចខាងក្រោម÷

| | ចំណាយសាច់ប្រាក់ |
|---|---|
| សេវាសុខាភិបាល | (X) |
| សេវាអប់រំ | (X) |
| ផ្សេងៗ | (X) |
| ចំណាយសរុប | (X) |

២.១.១៩ តាមវិធីសាស្ត្រនេះ ចំណាយសាច់ប្រាក់ដែលពាក់ព័ន្ធនឹងមុខងារសំខាន់ៗដែលបានធ្វើឡើងដោយស្ថាប័ន ត្រូវបានបង្ហាញដាច់ដោយឡែក។ នៅក្នុងឧទាហរណ៍នេះ ស្ថាប័នមានមុខងារពាក់ព័ន្ធនឹងការផ្តល់សេវាសុខាភិបាល និងសេវាអប់រំ។ ស្ថាប័នអាចធ្វើការដាក់បង្ហាញបន្ទាត់គណនីនៃចំណាយសាច់ប្រាក់សម្រាប់មុខងារនីមួយៗ។

២.១.២០ ស្ថាប័នដែលធ្វើចំណាត់ថ្នាក់ចំណាយសាច់ប្រាក់ទៅតាមមុខងារ ត្រូវបានលើកទឹកចិត្តឱ្យដាក់បង្ហាញព័ត៌មានបន្ថែមអំពីចរិកលក្ខណៈនៃចំណាយ ដោយរួមបញ្ចូលទាំងចំណាយដែលបានធ្វើឡើងសម្រាប់ប្រាក់ខែ និងអត្ថប្រយោជន៍និយោជិតផ្សេងទៀត។

២.១.២១ កថាខណ្ឌ ១.៣.១២ នៃផ្នែកទី១ នៃស្តង់ដានេះ តម្រូវឱ្យមានការលាតត្រដាងអំពីចំណូលសាច់ប្រាក់សរុបរបស់ស្ថាប័នដែលបង្ហាញដាច់ដោយឡែកអំពីចំណាត់ថ្នាក់រងនៃចំណូលសាច់ប្រាក់សរុប ដោយប្រើប្រាស់មូលដ្ឋាននៃការធ្វើចំណាត់ថ្នាក់មួយដែលសមស្របចំពោះប្រតិបត្តិការរបស់ស្ថាប័ន។ ការធ្វើចំណាត់ថ្នាក់រងនៃចំណូលសាច់ប្រាក់ទៅតាមថ្នាក់សមស្រប នឹងផ្អែកលើទំហំ ចរិកលក្ខណៈ និងមុខងារនៃចំនួនទឹកប្រាក់ដែលពាក់ព័ន្ធ។ បន្ថែមពីលើការលាតត្រដាងអំពីចំនួនចំណូលពីកម្ចី ការធ្វើចំណាត់ថ្នាក់រងខាងក្រោមអាចមានភាពសមស្រប÷

(ក) ចំណូលពីពន្ធ (ចំណូលទាំងនេះអាចត្រូវបានធ្វើចំណាត់ថ្នាក់រងបន្តទៅតាមប្រភេទពន្ធ)

(ខ) ចំណូលពីកម្រៃ, ការពិន័យ, ទោសបញ្ញត្តិ និងអាជ្ញាបណ្ណ

(គ) ចំណូលពីប្រតិបត្តិការប្តូរប្រាក់ រួមបញ្ចូលទាំងចំណូលពីការលក់ទំនិញនិងសេវា និងការគិតថ្លៃពីអ្នកប្រើប្រាស់ (នៅពេលប្រតិបត្តិការទាំងនេះត្រូវបានធ្វើចំណាត់ថ្នាក់ជាប្រតិបត្តិការប្តូរប្រាក់)

(ឃ) ចំនួនចំណូលសរុបពីជំនួយខាងក្រៅ និងជំនួយផ្សេងទៀត (អាចត្រូវបានធ្វើចំណាត់ថ្នាក់ទៅតាមចំនួនទឹកប្រាក់នៃអំណោយ, ឥណទាន និងជំនួយផ្សេងទៀតដែលបានផ្តល់, ចំណាត់ថ្នាក់សំខាន់ៗនៃអ្នកផ្តល់ជំនួយ និងចំនួនទឹកប្រាក់ដែលបានផ្តល់)

(ង) ចំណូលពីអំណោយ ការផ្ទេរ ឬវិភាជន៍ផែនការថវិកាផ្សេងទៀត (អាចត្រូវបានធ្វើចំណាត់ថ្នាក់ទៅតាមប្រភព និងគោលបំណង)

(ច) ចំណូលពីការប្រាក់ និងភាគលាភ និង

(ឆ) ចំណូលពីកាដូ, ការបរិច្ចាគ និងទម្រង់ជំនួយផ្សេងទៀត។

**ការលាតត្រដាងអំពីភាគីពាក់ព័ន្ធ**

២.១.២២ *ស្ថាប័នមួយ ត្រូវបានលើកទឹកចិត្តឱ្យលាតត្រដាងនៅក្នុងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ នូវព័ត៌មានដែលបានតម្រូវដោយស្តង់ដាគណនេយ្យអន្តរជាតិសម្រាប់វិស័យសាធារណៈ IPSAS ២០, "ការលាតត្រដាងអំពីភាគីពាក់ព័ន្ធ"។*

២.១.២៣ ស្តង់ដា IPSAS ២០ នៅក្នុងស៊ីរីនៃស្តង់ដា IPSAS តាមមូលដ្ឋានបង្ករ បានផ្តល់និយមន័យចំពោះពាក្យភាគីពាក់ព័ន្ធ និងពាក្យពាក់ព័ន្ធដទៃទៀត, តម្រូវឱ្យមានការលាតត្រដាងអំពីទំនាក់ទំនងជាមួយភាគីពាក់ព័ន្ធនៅពេលមានការគ្រប់គ្រង និងតម្រូវឱ្យមានការលាតត្រដាងព័ត៌មានជាក់លាក់អំពីប្រតិបត្តិការរបស់ភាគីពាក់ព័ន្ធ រួមបញ្ចូលទាំងព័ត៌មានអំពីលាភការសរុបរបស់ថ្នាក់ដឹកនាំសំខាន់ៗ។

**ការលាតត្រដាងអំពីទ្រព្យសកម្ម, បំណុល, ចំណូល, ចំណាយ និងការប្រៀបធៀបជាមួយផែនការថវិកា**

២.១.២៤ *ស្ថាប័នមួយត្រូវបានលើកទឹកចិត្តឱ្យលាតត្រដាងនៅក្នុងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ នូវ÷*

(ក) *ព័ត៌មានអំពីទ្រព្យសកម្ម, បំណុល, ចំណូល និងចំណាយរបស់ស្ថាប័ន និង*

(ខ) *ការប្រៀបធៀបជាមួយផែនការថវិកា ប្រសិនបើស្ថាប័នមិនបានធ្វើឱ្យមានជាសាធារណៈនូវផែនការថវិកាដែលបានអនុម័តរបស់ខ្លួន។*

២.១.២៥ រដ្ឋាភិបាលនិងស្ថាប័នរដ្ឋាភិបាល គ្រប់គ្រងធនធានសំខាន់ៗបន្ថែមពីលើសាច់ប្រាក់ ហើយប្រើប្រាស់ធនធានទាំងនោះដើម្បីសម្រេចបាននូវគោលបំណងនៃការផ្តល់សេវា។ ពួកគេខ្ចីដើម្បីផ្តល់មូលនិធិដល់សកម្មភាពរបស់ខ្លួន, បង្កើតបំណុល និងបំណុលផ្សេងទៀតដើម្បីធ្វើប្រតិបត្តិការរបស់ខ្លួន និងធ្វើការតាំងចិត្តដើម្បីបង្កើនប្រាក់នាពេលអនាគតតាមរយៈការទិញទ្រព្យសកម្មមូលធន។ ពួកគេក៏នាំឱ្យមានចំណាយនិងបង្កើតជាចំណូលនៅក្នុងអំឡុងការិយបរិច្ឆេទរាយការណ៍ ដែលនឹងផ្តល់លទ្ធផលជាលំហូរសាច់ប្រាក់នាការិយបរិច្ឆេទរាយការណ៍នាពេលអនាគត។ ទ្រព្យសកម្មមិនមែនសាច់ប្រាក់, បំណុល, ចំណូល និងចំណាយនឹងមិនត្រូវបានរាយការណ៍នៅលើផ្នែកមុខនៃរបាយការណ៍ចំណូលនិងចំណាយសាច់ប្រាក់ ឬរបាយការណ៍ហិរញ្ញវត្ថុផ្សេងទៀតដែលអាចត្រូវបានរៀបចំឡើងតាមមូលដ្ឋានគណនេយ្យសាច់ប្រាក់នោះទេ។ ទោះបីជាយ៉ាងណា រដ្ឋាភិបាលរក្សាទុកកំណត់ត្រានិងត្រួតពិនិត្យ និងគ្រប់គ្រងបំណុលរបស់ខ្លួននិងបំណុលផ្សេងទៀត, ទ្រព្យសកម្មមិនមែនសាច់ប្រាក់និងចំណាយសម្រាប់សកម្មភាពរបស់ខ្លួននៅក្នុងការិយបរិច្ឆេទរាយការណ៍ និងប្រភព និងចំនួននៃចំណូលពាក់ព័ន្ធ។ ការលាតត្រដាងព័ត៌មានអំពីទ្រព្យសកម្ម, បំណុល និងចំណាយ និងចំណូលនៃកម្មវិធីនិងសកម្មភាពជាក់លាក់ នឹងធ្វើឱ្យប្រសើរឡើងនូវគណនេយ្យភាព និងផ្តល់នូវព័ត៌មានដែលមានសារៈសំខាន់សម្រាប់គោលបំណងនៃការធ្វើសេចក្តីសម្រេចចិត្ត ហើយដូច្នេះ ត្រូវបានលើកទឹកចិត្តដោយស្តង់ដានេះ។

២.១.២៦ ស្ថាប័នដែលធ្វើការលាតត្រដាងបែបនេះ ត្រូវបានលើកទឹកចិត្តឱ្យកំណត់អត្តសញ្ញាណអំពីចំណូល និងចំណាយទៅតាមចរិកលក្ខណៈ ឬមុខងាររបស់ពួកវាឱ្យបានសមស្របទៅនឹងប្រតិបត្តិការរបស់ស្ថាប័ននិងទ្រព្យសកម្ម ឬបំណុលទៅតាមប្រភេទ ឧទាហរណ៍តាមរយៈការធ្វើចំណាត់ថ្នាក់÷

(ក) ទ្រព្យសកម្មជាប្រាក់ដែលត្រូវទទួល, ការវិនិយោគ ឬអចលនទ្រព្យ, រោងចក្រ និងបរិក្ខារ និង

(ខ) បំណុលជាប្រាក់ដែលត្រូវសង, កម្ចីទៅតាមប្រភេទ ឬប្រភព និងបំណុលផ្សេងទៀត។

នៅពេលការលាតត្រដាងបែបនេះអាចនឹងមិនមានភាពលម្អិតក្នុងការប៉ុនប៉ងជាលើកដំបូង ស្ថាប័នត្រូវបានលើកទឹកចិត្តឱ្យបន្តអភិវឌ្ឍ និងកសាងជាបណ្តើរៗ ខណៈពេលដែលស្ថាប័នកំពុងផ្លាស់ប្តូរទៅកាន់ការប្រើប្រាស់ពេញលេញនៃស្តង់ដាគណនេយ្យអន្តរជាតិសម្រាប់វិស័យសាធារណៈ មូលដ្ឋានបង្គរ។ ដើម្បីអនុលោមទៅតាមលក្ខខណ្ឌចាំបាច់នៃ កថាខណ្ឌ ១.៣.៥ និង ១.៣.៣២ នៃផ្នែកទី ១ នៃស្តង់ដានេះ ការលាតត្រដាងទាំងនេះចាំបាច់ត្រូវអនុលោមតាមបុគ្គលិកលក្ខណៈបែបគុណភាពនៃព័ត៌មានហិរញ្ញវត្ថុ និងគួរត្រូវបានពិពណ៌នាឱ្យបានច្បាស់លាស់ និងងាយយល់។

២.១.២៧ ស្តង់ដាគណនេយ្យអន្តរជាតិសម្រាប់វិស័យសាធារណៈមូលដ្ឋានបង្គរ អាចផ្តល់នូវការណែនាំដ៏មានសារៈប្រយោជន៍ចំពោះស្ថាប័នដែលបានលាតត្រដាងព័ត៌មានបន្ថែមអំពីទ្រព្យសកម្ម, បំណុល, ចំណូល និងចំណាយ។ គោលការណ៍ណែនាំអំពីការអនុវត្តក៏នឹងផ្តល់នូវការណែនាំអំពីការលាតត្រដាងដែលនឹងជួយដល់អ្នកប្រើប្រាស់ឱ្យយល់កាន់តែច្បាស់អំពីបញ្ហាដូចជា ស្ថានភាពហិរញ្ញវត្ថុ, ប្រតិបត្តិការហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់របស់ស្ថាប័ន; គោលបំណង និងជោគជ័យលើប្រតិបត្តិការសេវា និងនិរន្តរភាពនៃហិរញ្ញវត្ថុរបស់ខ្លួន។

**ការប្រៀបធៀបជាមួយផែនការថវិកា**

២.១.២៨ ស្ថាប័នសាធារណៈ ជាទូទៅស្ថិតនៅក្រោមផែនកំណត់ថវិកាក្នុងទម្រង់ជាវិភាជន៍ ឬអាជ្ញាធរថវិកាផ្សេងទៀតដែលអាចចូលជាធរមាន តាមរយៈការផ្តល់សិទ្ធិដោយច្បាប់។ គោលបំណងមួយនៃការរាយការណ៍ហិរញ្ញវត្ថុដោយស្ថាប័នសាធារណៈ គឺដើម្បីរាយការណ៍អំពីថាតើសាច់ប្រាក់ត្រូវបានទទួល និងប្រើប្រាស់ស្របតាមផែនការថវិកាដែលបានអនុម័តដោយច្បាប់ដែរឬទេ។ នៅក្នុងយុត្តាធិការមួយចំនួន លក្ខខណ្ឌចាំបាច់នេះត្រូវបានឆ្លុះបញ្ចាំងនៅក្នុងច្បាប់។ ស្ថាប័នដែលធ្វើឱ្យផែនការថវិកាដែលបានអនុម័តរបស់ខ្លួនអាចមានជាសាធារណៈបាន ត្រូវបានតម្រូវឱ្យអនុលោមតាមលក្ខខណ្ឌចាំបាច់នៃកថាខណ្ឌ ១.៧.១ ដល់ ១.៧.៤៦ នៃផ្នែកទី ១ នៃស្តង់ដានេះ។ ស្តង់ដានេះលើកទឹកចិត្តដល់ស្ថាប័នដទៃទៀត (ស្ថាប័នដែលមិនបង្ហាញផែនការថវិកាដែលបានអនុម័តរបស់ខ្លួនជាសាធារណៈ) ដើម្បីរួមបញ្ចូលក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ពួកគេនូវការលាតត្រដាងអំពីការប្រៀបធៀបរវាងចំនួនទឹកប្រាក់ជាក់ស្តែង ជាមួយនឹងចំនួនទឹកប្រាក់ផែនការថវិកាសម្រាប់ការិយបរិច្ឆេទរាយការណ៍ នៅពេលដែលរបាយការណ៍ហិរញ្ញវត្ថុនិងផែនការថវិកាស្ថិតក្រោមមូលដ្ឋានគណនេយ្យដូចគ្នា។ ការរាយការណ៍ដោយផ្អែកលើផែនការថវិកាសម្រាប់ស្ថាប័នផ្សេងទៀតទាំងនេះ អាចត្រូវបានដាក់បង្ហាញតាមវិធីផ្សេងៗគ្នា រួមមាន÷

(ក) ការរៀបចំកំណត់សម្គាល់មួយជាមួយនឹងតារាងដាច់ដោយឡែក សម្រាប់ចំនួនទឹកប្រាក់ផែនការថវិកា និងចំនួនទឹកប្រាក់ជាក់ស្តែង។ តារាងមួយដែលបង្ហាញពីភាពខុសគ្នាណាមួយពីផែនការថវិកា ឬវិភាជន៍ ក៏អាចត្រូវបានដាក់បង្ហាញដើម្បីឱ្យមានភាពពេញលេញផងដែរ និង

(ខ) ការលាតត្រដាងដែលចំនួនទឹកប្រាក់ផែនការថវិកាមិនបានលើស។ ប្រសិនបើចំនួនទឹកប្រាក់ផែនការថវិកា ឬវិភាជន៍បានលើស ឬចំណាយដែលបានធ្វើឡើងដោយគ្មានវិភាជន៍ ឬទម្រង់

អាជ្ញាធរផ្សេងទៀត ដូច្នេះ ព័ត៌មានលម្អិតអាចត្រូវបានលាតត្រដាងតាមរយៈមធ្យោបាយនៃកំណត់សម្គាល់ចំពោះគណនីពាក់ព័ន្ធនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

២.១.២៩ *ស្ថាប៉ន់ដែលលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន នូវការប្រៀបធៀបមួយរវាងចំនួនទឹកប្រាក់ជាក់ស្តែងជាមួយចំនួនទឹកប្រាក់ផែនការថវិកា ត្រូវបានលើកទឹកចិត្តឱ្យរួមបញ្ចូលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនូវការផ្ទឿងផ្ទាត់ជាមួយនឹងរបាយការណ៍ដែលរួមបញ្ចូលនូវព័ត៌មានអំពីជោគជ័យសេវា។*

២.១.៣០ *ស្ថាប៉ន់ដែលប្រើប្រាស់ផែនការថវិការច្រើនការិយបរិច្ឆេទ ត្រូវបានលើកទឹកចិត្តឱ្យផ្តល់នូវការលាតត្រដាងកំណត់សម្គាល់បន្ថែមអំពីទំនាក់ទំនងរវាងផែនការថវិកា និងចំនួនទឹកប្រាក់ជាក់ស្តែងនៅក្នុងអំឡុងការិយបរិច្ឆេទផែនការថវិកា។*

២.១.៣១ ព័ត៌មានផែនការថវិកាបន្ថែម រួមបញ្ចូលទាំងព័ត៌មានអំពីជោគជ័យសេវា អាចត្រូវបានដាក់បង្ហាញនៅក្នុងឯកសារផ្សេងក្រៅពីរបាយការណ៍ហិរញ្ញវត្ថុ។ ស្ថាប៉ន់ដែលលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួននូវការប្រៀបធៀបមួយរវាងចំនួនទឹកប្រាក់ជាក់ស្តែងនិងចំនួនទឹកប្រាក់ផែនការថវិកា ត្រូវបានលើកទឹកចិត្តឱ្យរួមបញ្ចូលក្នុងរបាយការណ៍ហិរញ្ញវត្ថុនូវការផ្ទឿងផ្ទាត់មួយ ជាមួយនឹងឯកសារទាំងនេះជាពិសេស ដើម្បីផ្សារភ្ជាប់ផែនការថវិកានិងទិន្នន័យជាក់ស្តែងទៅនឹងទិន្នន័យផែនការថវិកាមិនមែនហិរញ្ញវត្ថុ និងជោគជ័យសេវា។

២.១.៣២ ដូចកត់ចំណាំនៅក្នុងកថាខណ្ឌ ១.៧.៣២ នៃស្តង់ដានេះ ស្ថាប៉ន់អាចប្រើវិធីសាស្ត្រផ្សេងគ្នាក្នុងការកំណត់ផែនការថវិកាប្រចាំឆ្នាំនៅក្នុងផែនការថវិការច្រើនការិយបរិច្ឆេទ។ នៅពេលផែនការថវិការច្រើនការិយបរិច្ឆេទត្រូវបានប្រើប្រាស់ ស្ថាប៉ន់ត្រូវបានលើកទឹកចិត្តឱ្យផ្តល់នូវការលាតត្រដាងបន្ថែមអំពីបញ្ហាដូចជា ទំនាក់ទំនងរវាងផែនការថវិការច្រើនការិយបរិច្ឆេទ និងផែនការថវិកាប្រចាំឆ្នាំតាមសមាសធាតុ និងចំនួនទឹកប្រាក់ជាក់ស្តែងនៅក្នុងអំឡុងការិយបរិច្ឆេទផែនការថវិកា។

**របាយការណ៍ហិរញ្ញវត្ថុរួម**

**និយមន័យ**

២.១.៣៣ *ពាក្យខាងក្រោមត្រូវបានប្រើនៅក្នុងផ្នែកនេះនៃស្តង់ដានេះជាមួយនឹងអត្ថន័យដូចបានបញ្ជាក់÷*

*<u>របាយការណ៍ហិរញ្ញវត្ថុរួម</u> គឺជារបាយការណ៍ហិរញ្ញវត្ថុរបស់ស្ថាប៉ន់សេដ្ឋកិច្ចមួយ ដែលចំណូលសាច់ប្រាក់, ចំណាយសាច់ប្រាក់ និងសមតុល្យសាច់ប្រាក់របស់ស្ថាប៉ន់គ្រប់គ្រង និងស្ថាប៉ន់ក្រោមការគ្រប់គ្រងរបស់ខ្លួនត្រូវបានដាក់បង្ហាញជារបាយការណ៍ហិរញ្ញវត្ថុរបស់ស្ថាប៉ន់តែមួយ។*

*<u>ការគ្រប់គ្រងស្ថាប៉ន់មួយ÷</u> ស្ថាប៉ន់មួយគ្រប់គ្រងស្ថាប៉ន់ផ្សេងទៀត នៅពេលដែលស្ថាប៉ន់ទទួលរងឥទ្ធិពល ឬមានសិទ្ធិទទួលបានអត្ថប្រយោជន៍អថេរពីការចូលរួមរបស់ខ្លួនជាមួយស្ថាប៉ន់ផ្សេងទៀត និង*

*មានសមត្ថភាពក្នុងការជះឥទ្ធិពលដល់ចរិកលក្ខណៈ ឬចំនួនអត្ថប្រយោជន៍ទាំងនោះ តាមរយៈអំណាចរបស់ខ្លួនមកលើស្ថាប័នផ្សេងទៀត។*

*<u>ស្ថាប័នក្រោមការគ្រប់គ្រង</u> គឺជាស្ថាប័នមួយដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ស្ថាប័នផ្សេងទៀត (ស្គាល់ថាជា ស្ថាប័នគ្រប់គ្រង) ។*

*<u>ស្ថាប័នគ្រប់គ្រង</u> គឺជាស្ថាប័នមួយដែលមានស្ថាប័នក្រោមការគ្រប់គ្រងមួយ ឬច្រើន។*

*<u>ស្ថាប័នសេដ្ឋកិច្ច</u> មានន័យថាជាស្ថាប័នគ្រប់គ្រង និងស្ថាប័នក្រោមការគ្រប់គ្រងរបស់ខ្លួន។*

**ស្ថាប័នសេដ្ឋកិច្ច**

២.១.៣៤ ពាក្យ "ស្ថាប័នសេដ្ឋកិច្ច" ត្រូវបានប្រើក្នុងស្តង់ដានេះដើម្បីផ្តល់និយមន័យក្នុងគោលបំណងរាយការណ៍ហិរញ្ញវត្ថុថាជា ក្រុមស្ថាប័នដែលមានស្ថាប័នគ្រប់គ្រង និងស្ថាប័នក្រោមការគ្រប់គ្រងណាមួយ។ ពាក្យផ្សេងទៀតពេលខ្លះដែលត្រូវបានប្រើដើម្បីសំដៅលើស្ថាប័នសេដ្ឋកិច្ចមួយ រួមបញ្ចូលទាំងស្ថាប័នរដ្ឋបាល, ស្ថាប័នហិរញ្ញវត្ថុ, ស្ថាប័នរួមបញ្ចូលគ្នា, និងក្រុម។ កត្តាដែលត្រូវពិចារណាក្នុងការវាយតម្លៃថាតើស្ថាប័នមួយគ្រប់គ្រងស្ថាប័នដទៃសម្រាប់គោលបំណងរាយការណ៍ហិរញ្ញវត្ថុ គឺត្រូវបានបង្ហាញនៅក្នុងស្តង់ដា IPSAS ៣៥, *របាយការណ៍ហិរញ្ញវត្ថុរួម*។

២.១.៣៥ ស្ថាប័នសេដ្ឋកិច្ចមួយ អាចរួមបញ្ចូលទាំងស្ថាប័នដែលមានទាំងគោលនយោបាយសង្គម និងគោលបំណងពាណិជ្ជកម្ម។ ឧទាហរណ៍ នាយកដ្ឋានលំនៅស្ថានរបស់រដ្ឋាភិបាលអាចជាស្ថាប័នសេដ្ឋកិច្ចមួយដែលរួមបញ្ចូលទាំងស្ថាប័នដែលផ្តល់លំនៅដ្ឋានក្នុងតម្លៃដើម (nominal Charge) ក៏ដូចជាស្ថាប័នដែលផ្តល់កន្លែងស្នាក់នៅ ក្រោមមូលដ្ឋាននៃការធ្វើពាណិជ្ជកម្ម។

២.១.៣៦ ការប្តេជ្ញាចិត្តរបស់ស្ថាប័នសេដ្ឋកិច្ច នឹងត្រូវធ្វើឡើងទាក់ទងទៅនឹងកិច្ចសម្រុះសម្រួលរដ្ឋធម្មនុញ្ញនៅក្នុងយុត្តាធិការមួយ ជាពិសេសមធ្យោបាយដែលអំណាចរបស់រដ្ឋាភិបាលមានកម្រិតនិងត្រូវបានបែងចែក និងរបៀបដែលប្រព័ន្ធរដ្ឋាភិបាលត្រូវបានបង្កើតឡើង និងដំណើរការ។ ឧទាហរណ៍ នៅក្នុងយុត្តាធិការដែលមានអង្គនីតិប្រតិបត្តិ, អង្គនីតិបញ្ញត្តិ និងប្រព័ន្ធតុលាការ យុត្តាធិការទាំងនេះអាចបង្កើតជាស្ថាប័នសេដ្ឋកិច្ចមួយដែលមានតម្រូវការអ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុរួម។ របាយការណ៍ហិរញ្ញវត្ថុរួមបែបនេះ ជាធម្មតា ត្រូវបានសំដៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់រដ្ឋាភិបាលទាំងមូល។

**វិសាលភាពនៃរបាយការណ៍ហិរញ្ញវត្ថុរួម**

២.១.៣៧ *ស្ថាប័នគ្រប់គ្រងមួយ ក្រៅពីស្ថាប័នគ្រប់គ្រងដូចបានកំណត់នៅក្នុងកថាខណ្ឌ ២.១.៤០ ត្រូវបានលើកទឹកចិត្តឱ្យដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុរួម ដែលរួមបញ្ចូលនូវស្ថាប័នក្រោមការគ្រប់គ្រងទាំងអស់ទាំងបរទេសនិងក្នុងស្រុក ដោយអនុវត្តនីតិវិធីនៃការរួមបញ្ចូល ដូចខាងក្រោម÷*

(ក) *សមតុល្យសាច់ប្រាក់និងប្រតិបត្តិការសាច់ប្រាក់រវាងស្ថាប័ននានានៅក្នុងស្ថាប័នសេដ្ឋកិច្ច ត្រូវបានលុបបំបាត់ពេញលេញ*

(ខ) *នៅពេលរបាយការណ៍ហិរញ្ញវត្ថុដែលបានប្រើនៅក្នុងការរួមបញ្ចូល ត្រូវបានរៀបចំឡើងតាមកាលបរិច្ឆេទរាយការណ៍ផ្សេងគ្នា ការកែតម្រូវត្រូវបានធ្វើឡើងសម្រាប់ការចូលជាធរមាននៃប្រតិបត្តិការសាច់ប្រាក់ជាសារវន្តដែលបានកើតឡើងរវាងកាលបរិច្ឆេទទាំងនោះ និងកាលបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុរបស់ស្ថាប័នគ្រប់គ្រង និង*

(គ) *របាយការណ៍ហិរញ្ញវត្ថុរួមត្រូវបានរៀបចំឡើង ដោយប្រើគោលនយោបាយគណនេយ្យរួម សម្រាប់ប្រតិបត្តិការសាច់ប្រាក់។ ប្រសិនបើមិនអាចប្រើគោលនយោបាយគណនេយ្យរួម ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរួមទេ ការពិតនោះគួរត្រូវបានលាតត្រដាងជាមួយគ្នានឹងចំនួនគណនីនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរួម ដែលគោលនយោបាយគណនេយ្យផ្សេងគ្នាត្រូវបានអនុវត្តចំពោះគណនីទាំងនោះ។*

២.១.៣៨ *នៅពេលស្ថាប័នគ្រប់គ្រង ក្រៅពីស្ថាប័នគ្រប់គ្រងដូចបានកំណត់នៅក្នុង កថាខណ្ឌ ២.១.៤០ មិនបានដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុដែលបានរួមបញ្ចូលទូវាល់ស្ថាប័នក្រោមការគ្រប់គ្រងទាំងអស់ នោះស្ថាប័នគ្រប់គ្រងត្រូវបានលើកទឹកចិត្តឱ្យដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុដែលរួមបញ្ចូលទូវ ស្ថាប័នក្រោមការគ្រប់គ្រងទាំងនោះរបស់ខ្លួនដែលតំណាងឱ្យវិស័យចរិក, វិស័យរដ្ឋាភិបាលទូទៅ ឬស្ថាប័នសេដ្ឋកិច្ចផ្សេងទៀតដែលតំណាងឱ្យសកម្មភាពស្នូលរបស់រដ្ឋាភិបាល និងឆ្លើយតបទៅនឹងតម្រូវការព័ត៌មានរបស់អ្នកប្រើប្រាស់។*

២.១.៣៩ *ស្ថាប័នសេដ្ឋកិច្ចមួយប្រើពាក្យ "របាយការណ៍ហិរញ្ញវត្ថុរួម" ដើម្បីពិពណ៌នាអំពីរបាយការណ៍ហិរញ្ញវត្ថុដែលមានស្ថាប័នគ្រប់គ្រង និងស្ថាប័នក្រោមការគ្រប់គ្រងទាំងអស់របស់ខ្លួន ដូចបានកំណត់នៅក្នុងកថាខណ្ឌ ២.១.៣៧។ របាយការណ៍ហិរញ្ញវត្ថុរបស់ស្ថាប័នសេដ្ឋកិច្ចមួយដែលមិនមានស្ថាប័នគ្រប់គ្រងនិងស្ថាប័នក្រោមការគ្រប់គ្រងទាំងអស់របស់ខ្លួនដូចបានកំណត់នៅក្នុងកថាខណ្ឌ ២.១.៣៧ ត្រូវបានកំណត់ដោយពាក្យមួយដែលងាយយល់ និងពិពណ៌នាយ៉ាងច្បាស់អំពីថ្នាក់ ឬ (បុគ្គលិកលក្ខណៈ) របស់ស្ថាប័នដែលបង្កើតបានជាស្ថាប័នសេដ្ឋកិច្ច។*

២.១.៤០ *ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរួម គឺមិនមានភាពចាំបាច់នោះទេសម្រាប់ស្ថាប័នគ្រប់គ្រងមួយដែលបំពេញតាមគ្រប់លក្ខខណ្ឌទាំងអស់ ដូចខាងក្រោម÷*

(ក) *ស្ថាប័នខ្លួនឯងជាស្ថាប័នក្រោមការគ្រប់គ្រង ហើយតម្រូវការព័ត៌មានរបស់អ្នកប្រើប្រាស់ត្រូវបានបំពេញដោយរបាយការណ៍ហិរញ្ញវត្ថុរួមរបស់ស្ថាប័នគ្រប់គ្រងរបស់ខ្លួន និងនៅក្នុងករណីស្ថាប័នក្រោមការគ្រប់គ្រងដោយផ្ទែក ម្ចាស់ដទៃផ្សេងទៀតទាំងអស់របស់ខ្លួន រួមបញ្ចូលទាំងម្ចាស់ដែលមិនមានសិទ្ធិបោះឆ្នោត ត្រូវបានជូនដំណឹង ហើយមិនបដិសេធចំពោះស្ថាប័នដែលមិនដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុរួម។*

(ខ) *បំណុលឬឧបករណ៍មូលធនរបស់ខ្លួនមិនត្រូវបានជួញដូរក្នុងទីផ្សារសាធារណៈ (ទីផ្សារមូលបត្រក្នុងស្រុកឬបរទេស ឬទីផ្សារ អ្ហ-ស៊ី-ធី រួមបញ្ចូលទាំងទីផ្សារក្នុងស្រុក និងទីផ្សារក្នុងតំបន់)*

(គ) *ស្ថាប័នគ្រប់គ្រងមិនបានធ្វើ ឬស្ថិតនៅក្នុងដំណើរការនៃការធ្វើរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនជាមួយនឹងគណៈកម្មការមូលបត្រ ឬអង្គការគ្រប់គ្រងផ្សេងទៀតសម្រាប់គោលបំណងនៃការចោះផ្សាយថ្នាក់នៃឧបករណ៍ណាមួយនៅក្នុងទីផ្សារសាធារណៈមួយ និង*

(ឃ) *ស្ថាប័នគ្រប់គ្រងចុងក្រោយឬស្ថាប័នថ្នាក់កណ្តាលណាមួយ បង្កើតរបាយការណ៍ហិរញ្ញវត្ថុរួមដែលមានសម្រាប់ប្រើប្រាស់ជាសាធារណៈ និងអនុលោមតាមស្តង់ដាគណនេយ្យសាធារណៈកម្ពុជាមូលដ្ឋានសាច់ប្រាក់ ឬស្តង់ដាគណនេយ្យសាធារណៈ មូលដ្ឋានបង្គរ។*

២.១.៤១ សម្រាប់គោលបំណងគណនេយ្យភាពនិងការធ្វើសេចក្តីសម្រេចចិត្ត អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុរបស់រដ្ឋាភិបាលឬស្ថាប័នសាធារណៈផ្សេងទៀត ជាធម្មតាមានការព្រួយបារម្ភ និងចាំបាច់ត្រូវបានជូនដំណឹងអំពីធនធានសាច់ប្រាក់ដែលបានគ្រប់គ្រងដោយស្ថាប័នសេដ្ឋកិច្ចទាំងមូល។ តម្រូវការនេះត្រូវបានផ្តល់ជូនដោយរបាយការណ៍ហិរញ្ញវត្ថុរួម ដែលដាក់បង្ហាញព័ត៌មានហិរញ្ញវត្ថុអំពីស្ថាប័នសេដ្ឋកិច្ច ជាស្ថាប័នតែមួយ ដោយមិនគិតពីដែនកំណត់ផ្នែកច្បាប់របស់នីតិបុគ្គលដាច់ដោយឡែកពីគ្នានោះទេ។

២.១.៤២ ស្តង់ដានេះលើកទឹកចិត្តដល់រដ្ឋាភិបាលនិងស្ថាប័នគ្រប់គ្រងសាធារណៈផ្សេងទៀត ឱ្យធ្វើការដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុដែលរួមបញ្ចូលស្ថាប័នក្រោមការគ្រប់គ្រងទាំងអស់ នៅពេលដែលទំនងជាអាចមានអ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

២.១.៤៣ របាយការណ៍ហិរញ្ញវត្ថុរួមរបស់ស្ថាប័នសេដ្ឋកិច្ចមួយដែលមានរដ្ឋាភិបាលមួយ និងស្ថាប័នក្រោមការគ្រប់គ្រងទាំងអស់របស់ខ្លួន នឹងផ្តល់ជូនទូវព័ត៌មានអំពីធនធានសាច់ប្រាក់ដែលបានគ្រប់គ្រងដោយរដ្ឋាភិបាលដោយផ្ទាល់ និងតាមរយៈស្ថាប័នក្រោមការគ្រប់គ្រងរបស់ខ្លួននាកាលបរិច្ឆេទរាយការណ៍ និងការប្រែប្រួលនៃធនធានទាំងនោះនៅក្នុងអំឡុងការិយបរិច្ឆេទរាយការណ៍។ របាយការណ៍ហិរញ្ញវត្ថុរួមរបស់ស្ថាប័នសេដ្ឋកិច្ចសាធារណៈផ្សេងទៀតដូចជា ឧទាហរណ៍ ក្រសួងសុខាភិបាល ឬនាយកដ្ឋានអប់រំ នឹងផ្តល់ទូវព័ត៌មានអំពីធនធានសាច់ប្រាក់ដែលបានគ្រប់គ្រងដោយក្រសួង ឬនាយកដ្ឋាន និងការប្រែប្រួលនៃធនធានទាំងនោះនៅក្នុងអំឡុងការិយបរិច្ឆេទរាយការណ៍។

២.១.៤៤ ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរួម មិនមែនជាដំណើរការដែលគ្មានការចំណាយនោះទេ។ ដូច្នេះ វាមានសារៈសំខាន់ដែលអត្ថប្រយោជន៍នៃការរៀបចំរបាយការណ៍ទាំងនេះ បង្ហាញពីហេតុផលសមស្របនៃចំណាយលើការរៀបចំរបាយការណ៍ទាំងនេះ។ ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរួម ដោយស្ថាប័នគ្រប់គ្រងដែលជាស្ថាប័នក្រោមការគ្រប់គ្រងខ្លួនឯង នឹងមិនតែងតែចាំបាច់នៅក្នុងស្ថានភាពដូចបានកំណត់នៅក្នុងកថាខណ្ឌ ២.១.៤០ នោះទេ។ នេះគឺដោយសារតែតម្រូវការរបស់អ្នកប្រើប្រាស់ចំពោះព័ត៌មានដែលបានដាក់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុមូលដ្ឋានសាច់ប្រាក់ តែងត្រូវបានបំពេញដោយរបាយ-

ការណ៍ហិរញ្ញវត្ថុរួមរបស់ស្ថាប័នគ្រប់គ្រងរបស់ខ្លួន នៅពេលរបាយការណ៍ទាំងនេះត្រូវបានរៀបចំឡើង ស្របតាមលក្ខខណ្ឌចាំបាច់នៃស្តង់ដាគណនេយ្យសាធារណៈកម្ពុជា មូលដ្ឋានសាច់ប្រាក់ ឬមូលដ្ឋានបង្គរ និងស្ថានភាពផ្សេងទៀតដូចបានកំណត់នៅក្នុងកថាខណ្ឌ ២.១.៤០ ត្រូវបានអនុវត្ត។ ទោះបីជាយ៉ាងណា នៅក្នុងករណីផ្សេងទៀត របាយការណ៍ហិរញ្ញវត្ថុរួម ក្នុងកម្រិតរដ្ឋាភិបាលទាំងមូល ប្រហែលជាមិនអាចបំពេញតាមតម្រូវការព័ត៌មានរបស់អ្នកប្រើប្រាស់បានឡើយពាក់ព័ន្ធនឹងវិស័យ ឬសកម្មភាពសំខាន់ៗ របស់រដ្ឋាភិបាល។ នៅក្នុងយុត្តាធិការជាច្រើន មានលក្ខខណ្ឌចាំបាច់នៃការរាយការណ៍ហិរញ្ញវត្ថុដែល បានបង្កើត ជាមួយនឹងគោលបំណងដោះស្រាយតម្រូវការព័ត៌មានរបស់អ្នកប្រើប្រាស់ទាំងនេះ។

២.១.៤៥ នៅក្នុងករណីមួយចំនួន ស្ថាប័នមួយដែលមានអំណាចគ្រប់គ្រងសកម្មភាពពាក់ព័ន្ធរបស់ស្ថាប័នដទៃ ប្រហែលជាមិនអាចទាញយកអត្ថប្រយោជន៍ពីសកម្មភាពរបស់ស្ថាប័នដទៃនោះទេ ឧទាហរណ៍នៅពេល ស្ថាប័នដទៃប្រឈមនឹងការរឹតត្បិតខាងក្រៅរយៈពេលវែងធ្ងន់ធ្ងរដែលរារាំងស្ថាប័ន ពីការប្រើអំណាច ក្នុងការគ្រប់គ្រងសកម្មភាពរបស់ខ្លួនក្នុងការទទួលបានអត្ថប្រយោជន៍ពីសកម្មភាពទាំងនោះ។ លំហូរ សាច់ប្រាក់ និងសមតុល្យរបស់ស្ថាប័នទាំងនេះ មិនត្រូវបានរួមបញ្ចូលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរួម នោះទេ។ នេះគឺដោយសាររបាយការណ៍ហិរញ្ញវត្ថុរួម ដាក់បង្ហាញព័ត៌មានអំពីធនធានសាច់ប្រាក់របស់ រដ្ឋាភិបាល ឬស្ថាប័នរាយការណ៍សាធារណៈផ្សេងទៀត ដែលអាចត្រូវបានប្រើដើម្បីគាំទ្រដល់ការផ្តល់ ទំនិញនិងសេវា ឬទទួលបានអត្ថប្រយោជន៍ពីស្ថាប័នរាយការណ៍។

២.១.៤៦ កថាខណ្ឌ ២.១.៤០ (ឃ) ទទួលស្គាល់ថា ស្ថាប័នគ្រប់គ្រងចុងក្រោយ ឬស្ថាប័នថ្នាក់កណ្តាលណាមួយ របស់ស្ថាប័នមួយដែលប្រើស្តង់ដាគណនេយ្យសាធារណៈកម្ពុជា មូលដ្ឋានសាច់ប្រាក់ អាចរៀបចំ និង ដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុរួមតាមមូលដ្ឋានបង្គរ។ នៅពេលករណីនេះកើតឡើងនៅក្នុងយុត្តាធិការ មួយចំនួន ស្ថាប័នគ្រប់គ្រងចុងក្រោយ ឬស្ថាប័នថ្នាក់កណ្តាលណាមួយ គឺទំនងជាអាចជួបប្រទះនូវបញ្ហានៃ ការអនុវត្តសំខាន់ៗក្នុងការចងក្រងព័ត៌មានចាំបាច់ ដើម្បីអនុលោមតាមស្តង់ដាគណនេយ្យសាធារណៈ មូលដ្ឋានបង្គរ ពាក់ព័ន្ធនឹងស្ថាប័នក្រោមការគ្រប់គ្រងដែលប្រើមូលដ្ឋានសាច់ប្រាក់។

**ការផ្លាស់ប្តូរទៅកាន់របាយការណ៍ហិរញ្ញវត្ថុរួម**

២.១.៤៧ រដ្ឋាភិបាល និងស្ថាប័នសាធារណៈផ្សេងទៀតអាចគ្រប់គ្រងស្ថាប័នច្រើន រួមបញ្ចូលទាំងនាយកដ្ឋាន រដ្ឋាភិបាល, ភ្នាក់ងារ និងស្ថាប័នសាធារណៈពាណិជ្ជកម្មផងដែរ។ ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរួម ដែលរួមបញ្ចូលស្ថាប័នគ្រប់គ្រងមួយនិងស្ថាប័នក្រោមការគ្រប់គ្រងទាំងអស់របស់ខ្លួន អាចជាដំណើរការ ស្មុគស្មាញ និងត្រូវការធនធានច្រើន។ រដ្ឋាភិបាលមួយចំនួន និងស្ថាប័នសាធារណៈផ្សេងទៀតជួបប្រទះ នូវឧបសគ្គយ៉ាងច្រើនក្នុងការរៀបចំនិងដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុរួម ហើយប្រហែលជាមិនអាច រៀបចំឱ្យបានពេញលេញនូវរបាយការណ៍ហិរញ្ញវត្ថុរួម នៅក្នុងរយៈពេលខ្លីទៅមធ្យមនោះទេ នៅពេល ពួកគេចាប់ផ្តើមដំណើរការផ្លាស់ប្តូរទៅកាន់មូលដ្ឋានបង្គរពេញលេញ។ នេះអាចដោយសារតែបញ្ហា សមត្ថភាពដែលកម្រិតសមត្ថភាពរបស់រដ្ឋាភិបាល ឬស្ថាប័នផ្សេងទៀតក្នុងការប្រមូល និងដំណើរការ

ទិន្នន័យពីគ្រប់ស្ថាប័នក្រោមការគ្រប់គ្រងទាំងអស់ឱ្យបានទាន់ពេលវេលា ដោយសារលក្ខខណ្ឌចាំបាច់ផ្នែកច្បាប់ ឬលក្ខខណ្ឌចាំបាច់ដទៃទៀត ដើម្បីដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ក្រុមរងរបស់ស្ថាប័នក្រោមការគ្រប់គ្រង ជាជាងសម្រាប់ស្ថាប័នក្រោមការគ្រប់គ្រងទាំងអស់ ឬសម្រាប់ហេតុផលផ្សេងទៀត។

២.១.៤៨ នៅពេលរដ្ឋាភិបាលនិងស្ថាប័នសាធារណៈផ្សេងទៀតដែលរាយការណ៍តាមមូលដ្ឋានសាច់ប្រាក់ ធ្វើដំណើរផ្លាស់ប្តូរទៅកាន់មូលដ្ឋានបង្គរនៃការរបាយការណ៍ហិរញ្ញវត្ថុ និងអភិវឌ្ឍសមត្ថភាព, ប្រព័ន្ធ និងក្របខ័ណ្ឌច្បាប់ដើម្បីជម្នះឧបសគ្គចំពោះការរួមបញ្ចូល នោះសក្តានុពលដើម្បីរួមបញ្ចូលនៅក្នុងរបាយ-ការណ៍ហិរញ្ញវត្ថុតាមមូលដ្ឋានសាច់ប្រាក់នូវព័ត៌មានអំពីស្ថាប័នក្រោមការគ្រប់គ្រងបន្ថែម នឹងមានការកើនឡើង។ សម្រាប់រដ្ឋាភិបាល ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុដែលរាយការណ៍ព័ត៌មានអំពីចំណូលសាច់ប្រាក់, ចំណាយសាច់ប្រាក់ និងសមតុល្យសាច់ប្រាក់របស់ស្ថាប័នសេដ្ឋកិច្ចមួយដែលមានស្ថាប័នក្រោមការគ្រប់គ្រងដែលតំណាងឱ្យ ឧទាហរណ៍ វិស័យថវិកា, វិស័យរដ្ឋាភិបាលទូទៅ ឬតំណាងផ្សេងទៀតនៃសកម្មភាពស្នូលរបស់រដ្ឋាភិបាល នឹងផ្តល់នូវព័ត៌មានអំពីវិស័យគន្លឹះរបស់រដ្ឋាភិបាលដែលមានសារៈសំខាន់ចំពោះអ្នកប្រើប្រាស់សម្រាប់គោលបំណងគណនេយ្យភាព និងការធ្វើសេចក្តីសម្រេចចិត្ត។ ស្តង់ដានេះលើកទឹកចិត្តដល់ស្ថាប័នគ្រប់គ្រងដែលមិនបានដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុរួមពេញលេញ ឱ្យធ្វើការដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ស្ថាប័នសេដ្ឋកិច្ចបែបនេះជាជំហានបណ្តោះ-អាសន្នក្នុងការផ្លាស់ប្តូរទៅកាន់មូលដ្ឋានបង្គរនៃការរាយការណ៍ហិរញ្ញវត្ថុ និងការដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុរួមពេញលេញ ដោយអនុលោមតាមស្តង់ដាគណនេយ្យសាធារណៈ មូលដ្ឋានបង្គរ។ ភ្នាក់ងាររដ្ឋាភិបាលដែលមិនបានរួមបញ្ចូលស្ថាប័នក្រោមការគ្រប់គ្រងទាំងអស់របស់ខ្លួន ក៏ត្រូវបានលើកទឹកចិត្តឱ្យដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុដែលរួមបញ្ចូលស្ថាប័នក្រោមការគ្រប់គ្រង ដែលតំណាងឱ្យក្រុមរងនៃសកម្មភាពរបស់ពួកគេដែលមានសារៈសំខាន់ចំពោះអ្នកប្រើប្រាស់ សម្រាប់គោលបំណងគណនេយ្យភាពនិងការធ្វើសេចក្តីសម្រេចចិត្ត។

២.១.៤៩ ពាក្យ "របាយការណ៍ហិរញ្ញវត្ថុរួម" ត្រូវបានប្រើដើម្បីពិពណ៌នាអំពីរបាយការណ៍ហិរញ្ញវត្ថុដែលដាក់បង្ហាញ "ការរួមបញ្ចូលពេញលេញ" មួយនៃស្ថាប័នក្រោមការគ្រប់គ្រងទាំងអស់ដូចបានកំណត់នៅក្នុងកថាខណ្ឌ ២.១.៣៧ នៃស្តង់ដានេះ។ ពាក្យមួយ ក្រៅពីពាក្យ "របាយការណ៍ហិរញ្ញវត្ថុរួម" នឹងត្រូវបានប្រើដើម្បីពិពណ៌នាអំពីរបាយការណ៍ហិរញ្ញវត្ថុដែលដាក់បង្ហាញព័ត៌មានអំពីស្ថាប័នសេដ្ឋកិច្ចមួយ ដែលមិនបានរួមបញ្ចូលស្ថាប័នគ្រប់គ្រង និងស្ថាប័នក្រោមការគ្រប់គ្រងទាំងអស់របស់ខ្លួន។ ពាក្យនោះប្រើដើម្បីឱ្យគេងាយយល់ និងដើម្បីពិពណ៌នាឱ្យបានច្បាស់អំពីថ្នាក់ ឬ (បុគ្គលិកលក្ខណៈ) របស់ស្ថាប័នដែលបង្កើតបានជាស្ថាប័នសេដ្ឋកិច្ច។ ការជ្រើសរើសពាក្យឱ្យបានសមរម្យមួយ គឺជាការវិនិច្ឆ័យបែបវិជ្ជាជីវៈ។ ការវិនិច្ឆ័យនោះគួរត្រូវបានធ្វើឡើងក្នុងបរិបទនៃបុគ្គលិកលក្ខណៈបែបគុណភាពនៃការរាយការណ៍ហិរញ្ញវត្ថុដែលវាមានភាពងាយយល់ និងជាតំណាងដ៏ត្រឹមត្រូវមួយនៃស្ថាប័នសេដ្ឋកិច្ចដែលបានដាក់បង្ហាញ។ សម្រាប់រដ្ឋាភិបាលថ្នាក់ជាតិ ក្រុងឬខេត្ត ឬរដ្ឋាភិបាលថ្នាក់មូលដ្ឋានដែលរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

ទាំងនេះ ពាក្យដូចជា ឧទាហរណ៍ របាយការណ៍ហិរញ្ញវត្ថុនៃវិស័យថវិកា ឬវិស័យរដ្ឋាភិបាលទូទៅ អាចមានភាពសមរម្យ។

**នីតិវិធីនៃការរួមបញ្ចូលគ្នា**

២.១.៥០ នីតិវិធីនៃការរួមបញ្ចូលគ្នា ដូចបានបង្ហាញនៅក្នុងកថាខណ្ឌ ២.១.៣៧ ផ្តល់នូវមូលដ្ឋានសម្រាប់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរួម សម្រាប់ស្ថាប័នទាំងអស់ដែលមាននៅក្នុងស្ថាប័នសេដ្ឋកិច្ច ជាស្ថាប័នសេដ្ឋកិច្ចតែមួយ ដូចបានលើកទឹកចិត្តដោយស្តង់ដានេះ។

២.១.៥១ របាយការណ៍ហិរញ្ញវត្ថុរួមដែលបានលើកទឹកចិត្តដោយស្តង់ដានេះ ឆ្លុះបញ្ចាំងពីប្រតិបត្តិការរវាងស្ថាប័នសេដ្ឋកិច្ច និងស្ថាប័នផ្សេងទៀតខាងក្រៅស្ថាប័នសេដ្ឋកិច្ចនោះ ។ ដូច្នេះហើយ ប្រតិបត្តិការរវាងស្ថាប័ននានានៅក្នុងស្ថាប័នសេដ្ឋកិច្ចត្រូវបានលុបបំបាត់ដើម្បីជៀសវាងការរាប់ទ្វេដង។ ឧទាហរណ៍ នាយកដ្ឋានរដ្ឋាភិបាលមួយអាចលក់ទ្រព្យសកម្មរូបិយមួយទៅនាយកដ្ឋានរដ្ឋាភិបាលផ្សេងទៀត។ ដោយសារឥទ្ធិពលនៃសាច់ប្រាក់សុទ្ធទៅលើស្ថាប័នរាយការណ៍របស់រដ្ឋាភិបាលទាំងមូលគឺមិនមាននោះទេ ប្រតិបត្តិការនេះចាំបាច់ត្រូវលុបបំបាត់ដើម្បីជៀសវាងការនិយាយបំផ្លើសពីចំណូលសាច់ប្រាក់ និងចំណាយសាច់ប្រាក់របស់ស្ថាប័នរាយការណ៍របស់រដ្ឋាភិបាលទាំងមូល។ ស្ថាប័នរដ្ឋាភិបាលមួយអាចរក្សាទុកមូលនិធិជាមួយនឹងគ្រឹះស្ថានហិរញ្ញវត្ថុសាធារណៈមួយ។ សមតុល្យទាំងនេះអាចនឹងត្រូវបានលុបបំបាត់នៅក្នុងកម្រិតរដ្ឋាភិបាលទាំងមូល ពីព្រោះសមតុល្យទាំងនេះតំណាងឱ្យសមតុល្យនៅក្នុងស្ថាប័នសេដ្ឋកិច្ច។ ស្រដៀងគ្នានេះដែរ ស្ថាប័នសាធារណៈពាណិជ្ជកម្មមួយដែលធ្វើប្រតិបត្តិការនៅក្រៅប្រទេស អាចធ្វើការចំណាយមួយទៅនាយកដ្ឋានរដ្ឋាភិបាលមួយដែលស្ថិតនៅក្នុងរយៈពេលអន្តរកាល នាកាលបរិច្ឆេទរាយការណ៍។ នៅក្នុងករណីនេះ បរាជ័យក្នុងការលុបបំបាត់ប្រតិបត្តិការក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរួមរបស់រដ្ឋាភិបាលទាំងមូល អាចនាំឱ្យមានការវាយតម្លៃទាបទៅលើសមតុល្យសាច់ប្រាក់របស់ស្ថាប័នសេដ្ឋកិច្ចរបស់រដ្ឋាភិបាលទាំងមូល និងការនិយាយបំផ្លើសអំពីចំណាយសាច់ប្រាក់របស់ខ្លួន។ ទោះបីជាយ៉ាងណា ប្រតិបត្តិការអាចនឹងមិនត្រូវបានលុបបំបាត់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ដែលបានរៀបចំឡើងសម្រាប់ស្ថាប័នជាក្រុមមួយដែល ឧទាហរណ៍ បានតំណាងឱ្យវិស័យរដ្ឋាភិបាលទូទៅមួយដែលមិនរាប់បញ្ចូលនូវស្ថាប័នសាធារណៈពាណិជ្ជកម្ម។

២.១.៥២ ស្ថាប័ននានានៅក្នុងស្ថាប័នសេដ្ឋកិច្ច អាចអនុវត្តគោលនយោបាយផ្សេងគ្នាសម្រាប់ការធ្វើចំណាត់ថ្នាក់ចំណូលសាច់ប្រាក់និងចំណាយសាច់ប្រាក់ និងការដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន។ ចំណូលសាច់ប្រាក់ឬចំណាយសាច់ប្រាក់ដែលកើតឡើងពីប្រតិបត្តិការបែបនេះ ត្រូវបានធ្វើចំណាត់ថ្នាក់ និងដាក់បង្ហាញនៅក្នុងលក្ខណៈដូចគ្នានៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរួម ប្រសិនបើអាចអនុវត្តបាន។

**ការលាតត្រដាងនៃការរួមបញ្ចូលគ្នា**

២.១.៥៣ *ស្ថាប័នមួយត្រូវបានលើកទឹកចិត្តឱ្យលាតត្រដាងនៅក្នុងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុរួមរបស់ស្ថាប័នសេដ្ឋកិច្ចមួយដែលបានរៀបចំ ដោយអនុលោមតាមការលើកទឹកចិត្តក្នុងកថាខណ្ឌ ២.១.៣៧ ខ្លះ÷*

(ក) *ការរាយនាមស្ថាប័នក្រោមការគ្រប់គ្រងសំខាន់ៗ ដោយរួមបញ្ចូលទាំងឈ្មោះយុត្តាធិការដែលស្ថាប័នក្រោមការគ្រប់គ្រងកំពុងធ្វើប្រតិបត្តិការ (នៅពេលវាមានភាពខុសគ្នាពីឈ្មោះ និងយុត្តាធិការរបស់ស្ថាប័នគ្រប់គ្រងនោះ)*

(ខ) *ហេតុផលដែលមិនធ្វើការរួមបញ្ចូលនូវស្ថាប័នក្រោមការគ្រប់គ្រងមួយ*

(គ) *ផ្នែកនៃអត្ថប្រយោជន៍ភាពជាម្ចាស់កម្មសិទ្ធិនៅក្នុងស្ថាប័នក្រោមការគ្រប់គ្រង និងការពិពណ៌នាអំពីរបៀបដែលអត្ថប្រយោជន៍ភាពជាម្ចាស់កម្មសិទ្ធិនោះត្រូវបានកំណត់ និង*

(ឃ) *ប្រសិនបើអាចអនុវត្តបាន កត្តាដែលត្រូវបានពិចារណាក្នុងការកំណត់ថា ស្ថាប័នគ្រប់គ្រង÷*

(១) *គ្រប់គ្រងស្ថាប័នដទៃ (ឬប្រភេទស្ថាប័ន) ទោះបីជាស្ថាប័នគ្រប់គ្រងរក្សាទុកតិចជាងពាក់កណ្តាលនៃសិទ្ធិក្នុងការបោះឆ្នោតរបស់ស្ថាប័នដទៃ (ឬស្ថាប័នច្រើន) ជាមួយគ្នានឹងការពន្យល់មួយអំពីរបៀបដែលការគ្រប់គ្រងកើតមានឡើង និង*

(២) *មិនគ្រប់គ្រងស្ថាប័នដទៃ (ឬប្រភេទស្ថាប័ន) ទោះបីជាស្ថាប័នគ្រប់គ្រងរក្សាទុកច្រើនជាងពាក់កណ្តាលនៃសិទ្ធិក្នុងការបោះឆ្នោតរបស់ស្ថាប័នដទៃ (ឬស្ថាប័នច្រើន)។*

២.១.៥៤ *ស្ថាប័នមួយ ដែលដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ស្ថាប័នសេដ្ឋកិច្ចមួយដែលរួមបញ្ចូលស្ថាប័នក្រោមការគ្រប់គ្រងមួយចំនួនប៉ុន្តែមិនទាំងអស់ដូចបានលើកទឹកចិត្តនៅក្នុងកថាខណ្ឌ ២.១.៣៧ ត្រូវបានលើកទឹកចិត្តឱ្យលាតត្រដាងក្នុងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុទាំងនោះ នូវការលាតត្រដាងដូចបានលើកទឹកចិត្តនៅក្នុងកថាខណ្ឌ ២.១.៥៣ ជាមួយគ្នានឹង÷*

(ក) *ការពិពណ៌នាអំពីថ្នាក់ (ឬបុគ្គលិកលក្ខណៈ) របស់ស្ថាប័នក្រោមការគ្រប់គ្រងដែលត្រូវបានរួមបញ្ចូលនិងដកចេញពីបណ្តុំរបាយការណ៍ហិរញ្ញវត្ថុ ជាមួយគ្នានឹងការពន្យល់មួយអំពីហេតុផលសម្រាប់ការដកថ្នាក់ណាមួយចេញពីគណនីជាក្រុម និង*

(ខ) *ការរាយនាមស្ថាប័នសំខាន់ៗដែលត្រូវបានបន្ថែម ឬដកចេញពីស្ថាប័នដែលត្រូវបានរួមបញ្ចូលនៅក្នុងបណ្តុំរបាយការណ៍ហិរញ្ញវត្ថុ ចាប់តាំងពីការដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុនាការិយ-បរិច្ឆេទមុន។*

២.១.៥៥ *ស្ថាប័នគ្រប់គ្រងដែលមិនបានដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុរួម ដូចបានលើកទឹកចិត្តក្នុងកថាខណ្ឌ ២.១.៣៧ ត្រូវបានលើកទឹកចិត្តឱ្យលាតត្រដាងអំពីហេតុផលដែលរបាយការណ៍ហិរញ្ញវត្ថុរួម មិនត្រូវបានដាក់បង្ហាញជាមួយគ្នានឹងវិធីសាស្ត្រដែលបានប្រើ ដើម្បីបង្កើតជាស្ថាប័នក្រោមការគ្រប់គ្រងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែករបស់ខ្លួន។ វាក៏ត្រូវបានលើកទឹកចិត្តឱ្យលាតត្រដាងផងដែរអំពី*

*ឈ្មោះនិងអាសយដ្ឋានសំខាន់របស់ស្ថាប័នគ្រប់គ្រងរបស់ខ្លួន ដែលបានធ្វើការបោះផ្សាយរបាយការណ៍ហិរញ្ញវត្ថុរួមមួយ។*

២.១.៥៦ ការលាតត្រដាងដូចបានលើកទឹកចិត្តនៅក្នុងកថាខណ្ឌ ២.១.៥៣ និង ២.១.៥៤ នឹងផ្តល់ឱ្យអ្នកប្រើប្រាស់នូវព័ត៌មានអំពីសមាសភាព និងគុណសម្បត្តិសំខាន់ៗនៃរបាយការណ៍ហិរញ្ញវត្ថុរួមពេញលេញដែលត្រូវបានរៀបចំឡើងដោយអនុលោមតាមការលើកទឹកចិត្តនៅក្នុងកថាខណ្ឌ ២.១.៣៧ និងរបាយការណ៍ហិរញ្ញវត្ថុដែលរួមបញ្ចូលបណ្តុំនៃស្ថាប័នក្រោមការគ្រប់គ្រងរបស់ខ្លួន ដោយអនុលោមទៅតាមការលើកទឹកចិត្តនៅក្នុងកថាខណ្ឌ ២.១.៣៨។ ការលាតត្រដាងដូចបានលើកទឹកចិត្តនៅក្នុងកថាខណ្ឌ ២.១.៥៥ នឹងអនុញ្ញាតឱ្យអ្នកប្រើប្រាស់អាចកំណត់ថាតើ ស្ថាប័នគ្រប់គ្រងមួយរៀបចំរបាយការណ៍ហិរញ្ញវត្ថុរួម និងវិធីសាស្ត្រដែលបានប្រើដើម្បីបង្កើតជាស្ថាប័នក្រោមការគ្រប់គ្រង។

**ការទិញ និងការលក់ស្ថាប័នក្រោមការគ្រប់គ្រង និងស្ថាប័នប្រតិបត្តិចំណុះផ្សេងទៀត**

២.១.៥៧ *ស្ថាប័នមួយត្រូវបានលើកទឹកចិត្តឱ្យលាតត្រដាង និងដាក់បង្ហាញដាច់ដោយឡែកអំពីលំហូរសាច់ប្រាក់សរុបបញ្ចូលគ្នាដែលកើតឡើងពីការទិញនិងការលក់ស្ថាប័នក្រោមការគ្រប់គ្រងឬស្ថាប័នប្រតិបត្តិចំណុះផ្សេងទៀត។*

២.១.៥៨ *ស្ថាប័នមួយត្រូវបានលើកទឹកចិត្តឱ្យលាតត្រដាងនៅក្នុងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ ជាចំនួនទឹកប្រាក់សរុបបញ្ចូលគ្នា ទាក់ទងនឹងការទិញនិងការលក់ស្ថាប័នក្រោមការគ្រប់គ្រង ឬស្ថាប័នប្រតិបត្តិចំណុះផ្សេងទៀតនៅក្នុងអំឡុងការិយបរិច្ឆេទ នូវចំណុចនីមួយៗដូចខាងក្រោម÷*

(ក) *ការទិញសរុប ឬការពិចារណាក្នុងការលក់ (រួមបញ្ចូលទាំងសាច់ប្រាក់ ឬទ្រព្យសកម្មដទៃ)*

(ខ) *ចំនួននៃការទិញ ឬការពិចារណាក្នុងការលក់ដែលបានទូទាត់សងដោយការប្រើសាច់ប្រាក់ និង*

(គ) *ចំនួនសាច់ប្រាក់ក្នុងស្ថាប័នក្រោមការគ្រប់គ្រង ឬស្ថាប័នប្រតិបត្តិចំណុះដែលត្រូវបានទិញ ឬលក់។*

២.១.៥៩ ការដាក់បង្ហាញដាច់ដោយឡែកអំពីឥទ្ធិពលលំហូរសាច់ប្រាក់នៃការទិញនិងការលក់ស្ថាប័នក្រោមការគ្រប់គ្រង និងប្រតិបត្តិការផ្សេងទៀត ជាមួយគ្នានឹងការលាតត្រដាងដាច់ដោយឡែកអំពីចំនួនទ្រព្យសកម្ម និងបំណុលដែលត្រូវបានទិញឬលក់ អាចជួយញែកលំហូរសាច់ប្រាក់ទាំងនោះឱ្យដាច់ពីចំណូលសាច់ប្រាក់ និងចំណាយសាច់ប្រាក់ដែលកើតឡើងពីសកម្មភាពផ្សេងទៀតរបស់ស្ថាប័ន។ ដើម្បីអនុញ្ញាតឱ្យអ្នកប្រើប្រាស់អាចកំណត់ពីឥទ្ធិពលនៃការទិញនិងការលក់ ឥទ្ធិពលលំហូរសាច់ប្រាក់នៃការលក់នឹងមិនត្រូវបានកាត់ចេញពីការទិញទាំងនោះឡើយ។

២.១.៦០ ចំនួនសាច់ប្រាក់សរុបបញ្ចូលគ្នាដែលបានទូទាត់ ឬទទួលបានក្នុងទម្រង់ជាការទិញ ឬការពិចារណាក្នុងការលក់ ត្រូវបានរាយការណ៍នៅក្នុងរបាយការណ៍ចំណូលនិងចំណាយសាច់ប្រាក់ ជាសាច់ប្រាក់សុទ្ធដែលត្រូវបានទិញ ឬលក់។

២.១.៦១ កថាខណ្ឌ ២.១.២៤ លើកទឹកចិត្តឱ្យមានការលាតត្រដាងអំពីទ្រព្យសកម្ម, បំណុល, ចំណូល និងចំណាយរបស់ស្ថាប័ន។ ទ្រព្យសកម្ម, បំណុល, ចំណូល និងចំណាយ ក្រៅពីសាច់ប្រាក់ឬលំហូរសាច់ប្រាក់របស់ស្ថាប័នក្រោមការគ្រប់គ្រង ឬស្ថាប័នប្រតិបត្តិចំណុះដែលត្រូវបានទិញឬលក់ ក៏អាចត្រូវបានលាតត្រដាងដាច់ដោយឡែកផងដែរ ដូចបានសង្ខេបទៅតាមខ្នង់សំខាន់នីមួយៗ។ ដោយអនុលោមទៅតាមលក្ខខណ្ឌចាំបាច់នៃកថាខណ្ឌ ១.៣.៣២ នៃផ្នែកទី ១ នៃស្តង់ដានេះ នៅពេលការលាតត្រដាងបែបនេះត្រូវបានធ្វើឡើង នោះទ្រព្យសកម្ម, បំណុល, ចំណូល និងចំណាយគួរត្រូវបានកំណត់ឱ្យបានច្បាស់ ហើយមូលដ្ឋានដែលពួកគេត្រូវបានវាស់វែងនិងត្រូវបានទទួលស្គាល់ គួរត្រូវបានពន្យល់ផងដែរ។

**កិច្ចសម្រុះសម្រួលរួមគ្នា**

២.១.៦២ *ស្ថាប័នមួយត្រូវបានលើកទឹកចិត្តឱ្យធ្វើការលាតត្រដាងអំពីកិច្ចសម្រុះសម្រួលរួមគ្នាដែលចាំបាច់សម្រាប់ការដាក់បង្ហាញដ៏ត្រឹមត្រូវមួយនៃចំណូលនិងចំណាយសាច់ប្រាក់របស់ស្ថាប័ន នៅក្នុងអំឡុងការិយបរិច្ឆេទ និងសមតុល្យសាច់ប្រាក់ គិតត្រឹមកាលបរិច្ឆេទរាយការណ៍។*

២.១.៦៣ កិច្ចសម្រុះសម្រួលរួមគ្នា គឺជាកិច្ចសម្រុះសម្រួលមួយ ដែលភាគីពីរឬច្រើនមានការគ្រប់គ្រងរួមគ្នា។ ស្ថាប័នសាធារណៈជាច្រើនបង្កើតកិច្ចសម្រុះសម្រួលរួមគ្នានេះឡើង ដើម្បីចាប់ផ្តើមសកម្មភាពជាច្រើន។ ចរិកលក្ខណៈនៃសកម្មភាពទាំងនេះមានរាប់ចាប់ពីការចាប់ផ្តើមពាណិជ្ជកម្ម រហូតដល់ការផ្តល់សេវាសហគមន៍ដោយមិនគិតថ្លៃ។ ពាក្យថា កិច្ចសម្រុះសម្រួលរួមគ្នា ត្រូវបានកំណត់នៅក្នុងកិច្ចសន្យាមួយ ឬកិច្ចសម្រុះសម្រួលដែលត្រូវអនុវត្តតាមដទៃទៀត និងតែងតែបញ្ជាក់ពីការចូលរួមវិភាគទានដ៏ប្លែកនៃអ្នករួមទុនទាំងនីមួយៗ និងការបែងចែកចំណូលឬអត្ថប្រយោជន៍ដទៃទៀត (បើមាន) និងចំណាយរបស់អ្នករួមទុនទាំងនីមួយៗ។ ស្ថាប័នដែលរាយការណ៍តាមមូលដ្ឋានសាច់ប្រាក់ ជាទូទៅ នឹងរាយការណ៍អំពី÷

(ក) ជាចំណាយសាច់ប្រាក់, សាច់ប្រាក់ដែលត្រូវបានបង្កើតក្នុងការទិញអត្ថប្រយោជន៍មួយនៅក្នុងកិច្ចសម្រុះសម្រួលរួមគ្នា និងនៅក្នុងប្រតិបត្តិការបន្តនៃកិច្ចសម្រុះសម្រួលរួមគ្នា និង

(ខ) ជាចំណូលសាច់ប្រាក់, សាច់ប្រាក់ដែលទទួលបានពីកិច្ចសម្រុះសម្រួលរួមគ្នា។

ការលាតត្រដាងអំពីកិច្ចសម្រុះសម្រួលរួមគ្នា អាចរួមបញ្ចូលទាំងការរាយនាម និងការពិពណ៌នាអំពីអត្ថប្រយោជន៍នៅក្នុងកិច្ចសម្រុះសម្រួលរួមគ្នាសំខាន់ៗ។ ស្តង់ដា IPSAS ៣៦, *ការវិនិយោគក្នុងសមាគត និងក្រុមហ៊ុនរួមគ្នា* និង IPSAS ៣៧, *កិច្ចសម្រុះសម្រួលរួមគ្នា* នៅក្នុងស្តង់ដាគណនេយ្យសាធារណៈមូលដ្ឋានបង្គរ បានផ្តល់នូវសេចក្តីណែនាំអំពីទម្រង់និងរចនាសម្ព័ន្ធផ្សេងៗគ្នានៃការរៀបចំកិច្ចសម្រុះសម្រួលរួមគ្នានោះ និងការលាតត្រដាងបន្ថែមដ៏មានសក្តានុពលដែលអាចត្រូវបានធ្វើឡើង។ និយមន័យនិងការពន្យល់អំពីពាក្យ "គ្រប់គ្រង" នៅក្នុងស្តង់ដា IPSAS ៣៥ នឹងត្រូវបានពិចារណាក្នុងការកំណត់ថាតើស្ថាប័នមួយគឺជាសមាគត និងថាតើកិច្ចសម្រុះសម្រួលមួយគឺជាកិច្ចសម្រុះសម្រួលរួមគ្នា ដូចបានកំណត់នៅក្នុងស្តង់ដា IPSAS ៣៦ និង IPSAS ៣៧ ឬក៏យ៉ាងណា។

**ការរាយការណ៍ហិរញ្ញវត្ថុនៅក្នុងប្រទេសដែលមានអតិផរណាខ្ពស់**

២.១.៦៤ នៅក្នុងប្រទេសដែលមានអតិផរណាខ្ពស់ ការដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុជារូបិយបណ្ណក្នុងស្រុកដោយគ្មានការអះអាងឡើងវិញ មិនមានសារៈសំខាន់នោះទេ។ ទឹកប្រាក់បានបាត់បង់អំណាចនៃការទិញក្នុងអត្រាមួយ ដែលការប្រៀបធៀបចំនួនទឹកប្រាក់ដែលបានពីប្រតិបត្តិការនិងព្រឹត្តិការណ៍ផ្សេងទៀតដែលបានកើតឡើងនៅក្នុងពេលវេលាខុសគ្នា សូម្បីតែនៅក្នុងការិយបរិច្ឆេទគណនេយ្យដូចគ្នាក៏ដោយអាចបង្កឱ្យមានការភាន់ច្រឡំផងដែរ។

២.១.៦៥ ស្ពង់ដានេះមិនបានកំណត់ពីអត្រាជាច់ខាតដែលអតិផរណាខ្ពស់ត្រូវបានគេចាត់ទុកថានឹងកើតឡើងទេ។ វាជាបញ្ហានៃការវិនិច្ឆ័យនៅពេលការអះអាងឡើងវិញនៃរបាយការណ៍ហិរញ្ញវត្ថុ ដោយអនុលោមទៅតាមការលើកទឹកចិត្តនៅក្នុងស្ពង់ដានេះ អាចនឹងចាំបាច់។ អតិផរណាខ្ពស់ត្រូវបានចង្អុលបង្ហាញដោយបុគ្គលិកលក្ខណៈនៃបរិយាកាសសេដ្ឋកិច្ចរបស់ប្រទេសមួយដែលរួមបញ្ចូល ប៉ុន្តែមិនត្រូវបានកំណត់ចំពោះ÷

(ក) ប្រជាជនទូទៅប្រាថ្នាចង់រក្សាទ្រព្យសម្បត្តិរបស់ខ្លួនជាទ្រព្យសកម្មមិនមែនរូបិយវត្ថុឬជារូបិយបណ្ណបរទេសដែលមានស្ថេរភាពជាង។ ចំនួនរូបិយបណ្ណក្នុងស្រុកដែលបានរក្សាទុក ត្រូវបានវិនិយោគភ្លាមៗ ដើម្បីរក្សាបាននូវអំណាចនៃការទិញ

(ខ) ប្រជាជនទូទៅចាត់ទុកចំនួនទឹកប្រាក់ជារូបិយវត្ថុ មិនមែនក្នុងទម្រង់ជារូបិយបណ្ណក្នុងស្រុកនោះទេ ប៉ុន្តែក្នុងទម្រង់ជារូបិយបណ្ណបរទេសដែលមានស្ថេរភាពជាង។ តម្លៃអាចត្រូវបានជកស្រង់ជារូបិយបណ្ណនោះ

(គ) ការលក់និងការទិញជាឥណទាន កើតឡើងតាមតម្លៃដែលទូទាត់សងសម្រាប់ការខាតបង់នៃអំណាចនៃការទិញដែលបានរំពឹងទុកនៅក្នុងអំឡុងការិយបរិច្ឆេទឥណទាន បើទោះបីជាការិយបរិច្ឆេទមានរយៈពេលខ្លីក៏ពិតមែន

(ឃ) អត្រាការប្រាក់, ប្រាក់ឈ្នួល និងតម្លៃត្រូវបានភ្ជាប់ទៅកាន់សន្ទស្សន៍តម្លៃ និង

(ង) អត្រាអតិផរណាដែលបានកើនឡើងក្នុងរយៈពេល ៣ឆ្នាំមកនេះ កំពុងខិតជិតឬលើស ១០០%។

**ការអះអាងឡើងវិញនៃរបាយការណ៍ហិរញ្ញវត្ថុ**

២.១.៦៦ *ស្ថាប័នមួយដែលរាយការណ៍ជារូបិយបណ្ណរបស់ប្រទេសដែលមានអតិផរណាខ្ពស់មួយ ត្រូវបានលើកទឹកចិត្តឱ្យ÷*

(ក) *អះអាងឡើងវិញនូវរបាយការណ៍ចំណូលនិងចំណាយសាច់ប្រាក់ និងរបាយការណ៍ហិរញ្ញវត្ថុផ្សេងទៀតរបស់ខ្លួន ក្នុងទម្រង់ជាឯកតាវាស់វែងចរន្ត នាកាលបរិច្ឆេទរាយការណ៍*

(ខ) *អះអាងឡើងវិញនូវព័ត៌មានប្រៀបធៀបសម្រាប់ការិយបរិច្ឆេទមុន និងរាល់ព័ត៌មានដែលទាក់ទងនឹងការិយបរិច្ឆេទមុនៗ ក្នុងទម្រង់ជាឯកតាវាស់វែងចរន្ត នាកាលបរិច្ឆេទរាយការណ៍ និង*

(គ) *ប្រើសន្ទស្សន៍តម្លៃទូទៅមួយដែលឆ្លុះបញ្ចាំងពីការប្រែប្រួលអំណាចនៃការទិញទូទៅ។ វាជាការប្រសើរជាងមុន ដែលស្ថាប័នទាំងអស់ដែលរាយការណ៍ជាវិបិយបណ្ណរបស់ប្រទេសដូចគ្នាប្រើប្រាស់សន្ទស្សន៍ដូចគ្នា។*

២.១.៦៧ *ស្ថាប័នត្រូវបានលើកទឹកចិត្តឱ្យធ្វើការលាតត្រដាង ដូចខាងក្រោម÷*

(ក) *ការពិតដែលរបាយការណ៍ចំណូលនិងចំណាយសាច់ប្រាក់ និងរបាយការណ៍ហិរញ្ញវត្ថុដទៃទៀត និងតួលេខដែលត្រូវគ្នាសម្រាប់ការិយបរិច្ឆេទមុនៗ ត្រូវបានអះអាងឡើងវិញសម្រាប់ការប្រែប្រួលអំណាចនៃការទិញទូទៅរបស់វិបិយបណ្ណរាយការណ៍ ហើយជាលទ្ធផលត្រូវបានអះអាងក្នុងទម្រង់ជាឯកតាវាស់វែងចរន្ត នាកាលបរិច្ឆេទរាយការណ៍ និង*

(ខ) *អត្តសញ្ញាណ និងកម្រិតសន្ទស្សន៍តម្លៃ នាកាលបរិច្ឆេទរបាយការណ៍ និងការផ្លាស់ប្តូរដែលមាននៅក្នុងសន្ទស្សន៍ក្នុងអំឡុងការិយបរិច្ឆេទរាយការណ៍បច្ចុប្បន្ន និងការិយបរិច្ឆេទរាយការណ៍មុន។*

២.១.៦៨ តម្លៃបានប្រែប្រួលជាបន្តបន្ទាប់ជាលទ្ធផលនៃកម្លាំងនយោបាយ សេដ្ឋកិច្ច និងសង្គម។ កម្លាំងជាក់លាក់ដូចជា ការប្រែប្រួលនៃការផ្គត់ផ្គង់និងតម្រូវការ និងការប្រែប្រួលផ្នែកបច្ចេកវិទ្យាអាចធ្វើឱ្យតម្លៃនីមួយៗមានការកើនឡើង ឬថយចុះយ៉ាងខ្លាំង និងដោយឯករាជ្យរវាងគ្នានឹងគ្នា។ លើសពីនេះទៅទៀត កម្លាំងសេដ្ឋកិច្ចទូទៅអាចបង្ករឱ្យមានការប្រែប្រួលកម្រិតតម្លៃទូទៅ ហើយដូច្នេះ នឹងមានការប្រែប្រួលអំណាចនៃការទិញទូទៅនៃទឹកប្រាក់។

២.១.៦៩ នៅក្នុងសេដ្ឋកិច្ចដែលមានអតិផរណាខ្ពស់ សារៈប្រយោជន៍នៃរបាយការណ៍ហិរញ្ញវត្ថុត្រូវបានកើនឡើងយ៉ាងខ្លាំង ប្រសិនបើរបាយការណ៍ហិរញ្ញវត្ថុត្រូវបានបង្ហាញក្នុងទម្រង់ជាឯកតាវាស់វែងចរន្ត នាកាល-បរិច្ឆេទរាយការណ៍។ ជាលទ្ធផល ប្រព្រឹត្តិកម្ម និងការលាតត្រដាងនៅក្នុងកថាខណ្ឌ ២.១.៦៦ និង ២.១.៦៧ ខាងលើ ត្រូវបានលើកទឹកចិត្ត។ ការដាក់បង្ហាញព័ត៌មាននេះជាការដាក់បង្ហាញចម្បង ជាជាងការបន្ថែមទៅលើរបាយការណ៍ហិរញ្ញវត្ថុដែលមិនត្រូវបានអះអាងឡើងវិញ ត្រូវបានលើកទឹកចិត្ត។ ការដាក់បង្ហាញជាច់ដោយឡែកនៃរបាយការណ៍ចំណូលនិងចំណាយសាច់ប្រាក់ និងរបាយការណ៍ហិរញ្ញវត្ថុដទៃទៀតមុនការអះអាងឡើងវិញ មិនត្រូវបានលើកទឹកចិត្តនោះទេ។

២.១.៧០ គណនីទាំងអស់នៅក្នុងរបាយការណ៍ចំណូលនិងចំណាយសាច់ប្រាក់ នឹងត្រូវបានបង្ហាញក្នុងទម្រង់ជាឯកតាវាស់វែងចរន្ត នាកាលបរិច្ឆេទរាយការណ៍។ ដូច្នេះ ចំនួនទឹកប្រាក់ទាំងអស់ រួមបញ្ចូលទាំងចំណាយណាមួយដោយភាគីទីបី ដូចត្រូវបានលាតត្រដាងនៅលើផ្នែកមុខនៃរបាយការណ៍ចំណូលនិងចំណាយសាច់ប្រាក់ ឬនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុផ្សេងទៀត អាចនឹងត្រូវបានអះអាងឡើងវិញ ដោយអនុវត្តការប្រែប្រួលនៃសន្ទស្សន៍តម្លៃទូទៅ គិតចាប់ពីកាលបរិច្ឆេទដែលចំណាយនិងចំណូលត្រូវបានកត់ត្រាជាលើកដំបូង។

២.១.៧១ ស្ថាប័នជាច្រើននៅក្នុងវិស័យសាធារណៈរួមបញ្ចូលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន នូវព័ត៌មានផែនការថវិកាពាក់ព័ន្ធ ដើម្បីសម្របសម្រួលការប្រៀបធៀបជាមួយនឹងផែនការថវិកា។ នៅពេលករណីនេះកើតឡើង ស្តង់ដានេះលើកទឹកចិត្តឱ្យមានការអះអាងឡើងវិញនៃព័ត៌មានអំពីផែនការថវិកា ដោយអនុលោមតាមស្តង់ដានេះ។

**ព័ត៌មានប្រៀបធៀប**

២.១.៧២ ប្រសិនបើចង់ឱ្យការប្រៀបធៀបជាមួយនឹងការិយបរិច្ឆេទមុនៗពោរពេញទៅដោយអត្ថន័យ ព័ត៌មានប្រៀបធៀបសម្រាប់ការិយបរិច្ឆេទរាយការណ៍មុន នឹងត្រូវបានអះអាងឡើងវិញដោយអនុវត្តសន្ទស្សន៍តម្លៃទូទៅមួយ ដូច្នេះ របាយការណ៍ហិរញ្ញវត្ថុដែលអាចប្រៀបធៀបគ្នាបាន ត្រូវបានដាក់បង្ហាញក្នុងទម្រង់ជាឯកតាវាស់វែងចរន្ត នាចុងការិយបរិច្ឆេទរាយការណ៍។ ព័ត៌មានដែលត្រូវបានលាតត្រដាងនៅក្នុងការិយបរិច្ឆេទមុនៗ ក៏ត្រូវបានបង្ហាញក្នុងទម្រង់ជាឯកតាវាស់វែងចរន្ត នាចុងការិយបរិច្ឆេទរាយការណ៍ផងដែរ។

**របាយការណ៍ហិរញ្ញវត្ថុរួម**

២.១.៧៣ ស្ថាប័នគ្រប់គ្រងមួយដែលរាយការណ៍ជារូបិយបណ្ណរបស់ប្រទេសដែលមានអតិផរណាខ្ពស់មួយ អាចមានស្ថាប័នក្រោមការគ្រប់គ្រង ដែលក៏ធ្វើការរាយការណ៍ជារូបិយបណ្ណរបស់ប្រទេសដែលមានអតិផរណាខ្ពស់ផងដែរ។ ប្រសិនបើរបាយការណ៍ចំណូលនិងចំណាយសាច់ប្រាក់ និងរបាយការណ៍ហិរញ្ញវត្ថុផ្សេងទៀតនឹងត្រូវបានរៀបចំឡើងជាទៀងទាត់ របាយការណ៍ហិរញ្ញវត្ថុរបស់ស្ថាប័នក្រោមការគ្រប់គ្រងណាមួយនឹងត្រូវបានអះអាងឡើងវិញ ដោយអនុវត្តសន្ទស្សន៍តម្លៃទូទៅមួយរបស់ប្រទេសជារូបិយបណ្ណដែលស្ថាប័នក្រោមការគ្រប់គ្រងរាយការណ៍ជារូបិយបណ្ណរបស់ប្រទេសនោះ មុនពេលរបាយការណ៍ហិរញ្ញវត្ថុទាំងនោះត្រូវបានរួមបញ្ចូលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរួម ដែលបានបោះផ្សាយដោយស្ថាប័នគ្រប់គ្រងរបស់ខ្លួន។ នៅពេលស្ថាប័នក្រោមការគ្រប់គ្រងនោះ គឺជាស្ថាប័នក្រោមការគ្រប់គ្រងបរទេស របាយការណ៍ហិរញ្ញវត្ថុដែលត្រូវបានអះអាងឡើងវិញរបស់ខ្លួន ត្រូវបានបកប្រែតាមអត្រាប្តូរប្រាក់ចុងគ្រា។

២.១.៧៤ ប្រសិនបើរបាយការណ៍ហិរញ្ញវត្ថុដែលមានកាលបរិច្ឆេទរាយការណ៍ខុសគ្នាត្រូវបានរួមបញ្ចូល នោះគណនីទាំងអស់ មិនថាក្នុងទម្រង់ជារូបិយវត្ថុ ឬមិនមែនរូបិយវត្ថុ គឺចាំបាច់ត្រូវបានអះអាងឡើងវិញក្នុងទម្រង់ជាឯកតាវាស់វែងចរន្ត នាកាលបរិច្ឆេទរបស់របាយការណ៍ហិរញ្ញវត្ថុរួម។

**ការជ្រើសរើស និងការប្រើប្រាស់សន្ទស្សន៍តម្លៃទូទៅ**

២.១.៧៥ ការអះអាងឡើងវិញនៃរបាយការណ៍ហិរញ្ញវត្ថុ ដោយអនុលោមទៅតាមវិធីសាស្ត្រដូចបានលើកទឹកចិត្ត ដោយស្តង់ដានេះ តម្រូវឱ្យប្រើសន្ទស្សន៍តម្លៃទូទៅដែលឆ្លុះបញ្ចាំងពីការប្រែប្រួលអំណាចនៃការទិញទូទៅ។ វាជាការប្រសើរដែលស្ថាប័នទាំងអស់ដែលធ្វើការរាយការណ៍ជារូបិយបណ្ណរបស់ប្រទេសដូចគ្នាប្រើប្រាស់សន្ទស្សន៍ដូចគ្នា។

២.១.៧៦ ការលាតត្រដាងដូចបានលើកទឹកចិត្តដោយស្តង់ដានេះ មានគោលបំណងបញ្ជាក់ឱ្យច្បាស់អំពីមូលដ្ឋាននៃការប្រឈមនឹងឥទ្ធិពលនៃអតិផរណាខ្ពស់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ ការលាតត្រដាងទាំងនេះក៏មានគោលបំណងផ្តល់នូវព័ត៌មានចាំបាច់ផ្សេងទៀត ដើម្បីយល់អំពីមូលដ្ឋាន និងលទ្ធផលនៃចំនួនអតិផរណានោះ។

**ចំណាយដោយតាគីទីបី ជំនួសឱ្យស្ថាប័ន**

២.១.៧៧ *នៅក្នុងអំឡុងការិយបរិច្ឆេទរាយការណ៍នៅពេលស្ថាប័នរាយការណ៍មួយត្រូវបានផ្តល់យោបល់ជាផ្លូវការថា ចំណាយត្រូវបានធ្វើឡើងដើម្បីទូទាត់ភាពកិច្ចរបស់ខ្លួនដោយផ្ទាល់ ឬដើម្បីទិញទំនិញ និងសេវាសម្រាប់ផលប្រយោជន៍របស់ខ្លួនតាមរយៈភាគីទីបី ឬស្ថាប័នបានផ្ទៀងផ្ទាត់ផ្សេងពីនេះថា ការទូទាត់បែបនេះត្រូវបានធ្វើឡើង នោះស្ថាប័នត្រូវបានលើកទឹកចិត្តឱ្យធ្វើការលាតត្រដាងនៅក្នុងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ នូវ÷*

(ក) *ចំណាយសរុបដែលត្រូវបានធ្វើឡើងដោយភាគីទីបី និង*

(ខ) *ចំណាត់ថ្នាក់រងនៃចំនួនចំណាយសរុប ដោយប្រើមូលដ្ឋាននៃការធ្វើចំណាត់ថ្នាក់ដែលមានភាពសមស្របទៅនឹងប្រតិបត្តិការរបស់ស្ថាប័ន។*

២.១.៧៨ នៅក្នុងករណីមួយចំនួន ភាគីទីបីទិញទំនិញឬសេវាជំនួសឱ្យស្ថាប័ន ឬធ្វើការទូទាត់ភាពកិច្ចរបស់ស្ថាប័ន។ ឧទាហរណ៍ រដ្ឋាភិបាលថ្នាក់ជាតិមួយអាចផ្តល់មូលនិធិដល់ប្រតិបត្តិការនៃកម្មវិធីអប់រំ ឬកម្មវិធីសុខភាពរបស់រដ្ឋាភិបាលថ្នាក់រាជធានី ឬថ្នាក់ខេត្តឯករាជ្យមួយ ដោយទូទាត់ឱ្យអ្នកផ្តល់សេវា និងទិញ និងផ្ទេរទៅកាន់រដ្ឋាភិបាលដទៃនូវសម្ភារៈចាំបាច់នៅក្នុងអំឡុងការិយបរិច្ឆេទ។ ស្រដៀងគ្នានេះដែរ រដ្ឋាភិបាលថ្នាក់ជាតិ ឬភ្នាក់ងារផ្តល់ជំនួយឯករាជ្យមួយអាចទូទាត់ឱ្យក្រុមហ៊ុនសាងសង់ដោយផ្ទាល់សម្រាប់ការសាងសង់ផ្លូវឱ្យរដ្ឋាភិបាលផ្សេងទៀត ជាជាងផ្តល់មូលនិធិដោយផ្ទាល់ទៅកាន់រដ្ឋាភិបាល។ ចំណាយទាំងនេះអាចត្រូវបានធ្វើឡើងក្នុងទម្រង់ជាអំណោយ, ការបរិច្ចាគ ឬទម្រង់នៃជំនួយផ្សេងទៀត ឬជាឥណទានដែលត្រូវសងវិញ។ នៅក្នុងករណីទាំងនេះ រដ្ឋាភិបាលថ្នាក់រាជធានី ឬថ្នាក់ខេត្តមិនបានទទួលសាច់ប្រាក់ (រួមបញ្ចូលទាំងសាច់ប្រាក់សមមូល) ដោយផ្ទាល់ពីស្ថាប័នដទៃ ឬទទួលបានការគ្រប់គ្រងលើគណនីធនាគារ ឬឧបករណ៍ប្រហាក់ប្រហែលដែលត្រូវបានបង្កើតឡើងសម្រាប់អត្ថប្រយោជន៍ផ្ទាល់ខ្លួន ដោយស្ថាប័នដទៃនោះទេ។ ដូច្នេះ ចំនួនទឹកប្រាក់ដែលត្រូវបានទូទាត់សង ឬទូទាត់ជំនួសឱ្យស្ថាប័នខ្លួនឯងមិនបានបង្កើតជា "សាច់ប្រាក់" ដូចបានផ្តល់និយមន័យនៅក្នុងស្តង់ដានេះទេ។ ទោះបីជាយ៉ាងណារដ្ឋាភិបាលដែលជាគម្រោងទទួលបាននូវអត្ថប្រយោជន៍ពីចំណាយសាច់ប្រាក់ដែលកំពុងត្រូវបានធ្វើឡើងជំនួសឱ្យស្ថាប័នខ្លួនឯង។

២.១.៧៩ ការលាតត្រដាងព័ត៌មានអំពីចំនួនទឹកប្រាក់ និងថ្នាក់នៃចំណាយដែលត្រូវបានធ្វើឡើងដោយភាគីទីបី (មិនថាតាមរយៈចរិកលក្ខណៈ, មុខងារ ឬក៏ទាំងពីរ) នឹងផ្តល់នូវព័ត៌មានបន្ថែមដែលមានសារៈសំខាន់សម្រាប់គោលបំណងគណនេយ្យភាព និងការធ្វើសេចក្តីសម្រេចចិត្ត។ នៅក្នុងករណីមួយចំនួន ស្ថាប័ន

មួយអាចមិនត្រូវបានគេផ្តល់យោបល់ជាផ្លូវការ ឬក៏បានដឹងអំពីចំណាយរបស់ភាគីទីបីដែលបានធ្វើឡើងជំនួសឱ្យស្ថាប័នខ្លួនឯងនៅក្នុងអំឡុងការិយបរិច្ឆេទរាយការណ៍ ឬមិនអាចផ្ទៀងផ្ទាត់ថា ចំណាយដែលបានរំពឹងទុកមួយបានកើតឡើង។ ប្រសិនបើស្ថាប័នមួយមិនមានជំនឿថា ចំនួនចំណាយរបស់ភាគីទីបីដែលបានលាតត្រដាងគឺជាការតំណាងដ៏ស្មោះត្រង់មួយនៃចំណាយទាំងអស់ ដែលបានធ្វើឡើងជំនួសឱ្យស្ថាប័នក្នុងអំឡុងការិយបរិច្ឆេទទេ កំណត់សម្គាល់គួរផ្តល់យោបល់ដល់អ្នកប្រើប្រាស់ថា ការលាតត្រដាងទាំងនេះប្រហែលជាមិនរាប់បញ្ចូលនូវចំណាយរបស់ភាគីទីបីទាំងអស់នោះទេ។

២.១.៨០ កថាខណ្ឌ ២.១.៧៧ លើកទឹកចិត្តឱ្យមានការលាតត្រដាងអំពីចំនួនចំណាយសរុបរបស់ភាគីទីបីដែលបានធ្វើឡើងនៅក្នុងអំឡុងការិយបរិច្ឆេទរាយការណ៍ និងថ្នាក់សំខាន់ៗនៃចំណាយទាំងនេះ។ ចំណាយរបស់ភាគីទីបីនឹងរាប់បញ្ចូលនូវចំនួនទឹកប្រាក់ដែលបានផ្តល់និយមន័យថាជាជំនួយខាងក្រៅ និងជំនួយផ្សេងទៀតនៅក្នុងកថាខណ្ឌ ២.១.៨២ នៃស្តង់ដានេះ។ កថាខណ្ឌ ២.១.៩០ (ខ) លើកទឹកចិត្តឱ្យមានការលាតត្រដាងអំពីចំនួនទឹកប្រាក់នៃជំនួយខាងក្រៅដែលបានផ្តល់ឱ្យស្ថាប័នមួយក្នុងទម្រង់ជាចំណាយរបស់ភាគីទីបី។ កថាខណ្ឌ ២.១.៩១ លើកទឹកចិត្តឱ្យការលាតត្រដាងបែបនេះត្រូវបានធ្វើឡើងចំពោះជំនួយផ្សេងទៀត តាមដែលអាចអនុវត្តបាន។

២.១.៨១ ចំណាត់ថ្នាក់រង (ឬថ្នាក់)នៃចំណាយរបស់ភាគីទីបីដែលអាចត្រូវបានលាតត្រដាង ដោយអនុលោមតាមកថាខណ្ឌ ២.១.៧៧ (ខ) គឺជាការវិនិច្ឆ័យបែបវិជ្ជាជីវៈ។ កត្តាដែលនឹងត្រូវយកមកពិចារណាក្នុងការអនុវត្តការវិនិច្ឆ័យនោះ ត្រូវបានបង្ហាញនៅក្នុងកថាខណ្ឌ ១.៣.១៧ នៃផ្នែកទី ១ នៃស្តង់ដានេះ។

**គម្យជនៃជំនួយខាងក្រៅ និងជំនួយផ្សេងទៀត**

**និយមន័យ**

២.១.៨២ *ពាក្យខាងក្រោមត្រូវបានប្រើនៅក្នុងស្តង់ដានេះជាមួយនិយមន័យដូចបានបញ្ជាក់÷*

*<u>ជំនួយ</u> មានន័យថា ជំនួយខាងក្រៅ និងជំនួយផ្សេងទៀត។*

*<u>ភ្នាក់ងារផ្តល់ជំនួយខាងក្រៅទ្វេភាគី</u> គឺជាភ្នាក់ងារដែលត្រូវបានបង្កើតឡើងក្រោមច្បាប់ជាតិ, បទប្បញ្ញត្តិ ឬអាជ្ញាធរជាតិផ្សេងទៀតសម្រាប់គោលបំណង ឬរួមបញ្ចូលទាំងគោលបំណងនៃការផ្តល់ជំនួយខាងក្រៅមួយចំនួន ឬទាំងអស់របស់ជាតិនោះ។*

*<u>ប្រតិបត្តិការប្តូរប្រាក់</u> គឺជាប្រតិបត្តិការដែលស្ថាប័នមួយទទួលទ្រព្យសកម្ម ឬសេវា ឬមានបំណុល និងផ្តល់តម្លៃប្រហាក់ប្រហែលស្មើរតែស្មើគ្នា (ក្នុងទម្រង់ជាសាច់ប្រាក់, ទំនិញ, សេវា ឬការប្រើប្រាស់ទ្រព្យសកម្ម) ទៅកាន់ស្ថាប័នផ្សេងទៀត ជាការផ្លាស់ប្តូរគ្នាទៅវិញទៅមក។*

*<u>ជំនួយខាងក្រៅ</u> មានន័យថា ធនធានផ្លូវការទាំងអស់ដែលគម្យជនអាចប្រើ ឬក៏ទទួលបានអត្ថប្រយោជន៍ពីវាក្នុងការសម្រេចបាននូវគោលបំណងរបស់ខ្លួន។*

*ភ្នាក់ងារផ្តល់ជំនួយខាងក្រៅពហុភាគី* *គឺជាភ្នាក់ងារទាំងអស់ដែលត្រូវបានបង្កើតឡើងក្រោមកិច្ចព្រមព្រៀងឬសន្ធិសញ្ញាអន្តរជាតិ សម្រាប់គោលបំណង ឬរួមបញ្ចូលទាំងគោលបំណងនៃការផ្តល់ជំនួយខាងក្រៅ។*

*អង្គការមិនមែនរដ្ឋាភិបាល* *គឺជាភ្នាក់ងារជាតិឬអន្តរជាតិទាំងអស់ដែលត្រូវបានបង្កើតឡើងឯករាជ្យពីការគ្រប់គ្រងដោយរដ្ឋាភិបាលណាមួយ សម្រាប់គោលបំណងនៃការផ្តល់ជំនួយទៅកាន់រដ្ឋាភិបាល, ភ្នាក់ងាររដ្ឋាភិបាល, អង្គការ ឬបុគ្គលផ្សេងទៀត។*

*ធនធានផ្ទាល់ការ* *មានន័យថា ឥណទាន, អំណោយ, ជំនួយបច្ចេកទេស, ការធានា ឬទម្រង់នៃជំនួយផ្សេងទៀតដែលត្រូវបានផ្តល់ ឬប្តេជ្ញាចិត្តក្រោមកិច្ចព្រមព្រៀងដែលត្រូវអនុវត្តតាមដោយភ្នាក់ងារផ្តល់ជំនួយខាងក្រៅទ្វេភាគីឬពហុភាគី ឬដោយរដ្ឋាភិបាលមួយ ឬភ្នាក់ងាររបស់រដ្ឋាភិបាលមួយ ជាជាងទៅកាន់គម្រោងមួយដែលមានជាតិសាសន៍ដូចគ្នាទៅនឹងរដ្ឋាភិបាល ឬភ្នាក់ងាររបស់រដ្ឋាភិបាលដែលផ្តល់ ឬប្តេជ្ញាចិត្តថានឹងផ្តល់ជំនួយនោះ។*

*ជំនួយផ្សេងទៀត* *មានន័យថា ធនធានដែលបានផ្តល់ដោយអង្គការមិនមែនរដ្ឋាភិបាល និងអំណោយ និងការបរិច្ចាគ ឬទម្រង់នៃជំនួយផ្សេងទៀតដែលបានផ្តល់ដោយស្ម័គ្រចិត្តដោយអង្គការវិស័យឯកជន និងបុគ្គលផ្សេងទៀតដែលគម្រោងអាចប្រើប្រាស់ ឬក៏ទទួលបានអត្ថប្រយោជន៍ពីការសម្រេចឱ្យបាននូវគោលបំណងរបស់ខ្លួន។ ជំនួយផ្សេងទៀត មិនបានរួមបញ្ចូលនូវធនធានផ្ទាល់ការ, ពន្ធ, ការពិន័យ និងកម្រៃ, ធនធានដែលបានផ្តល់នៅក្នុងប្រតិបត្តិការប្តូរប្រាក់ ឬធនធានដែលត្រូវបានផ្តល់ដោយរដ្ឋាភិបាលឬភ្នាក់ងាររបស់រដ្ឋាភិបាលមួយដែលមានជាតិសាសន៍ដូចគ្នាទៅនឹងគម្រោងនោះទេ។*

**ជំនួយ**

២.១.៨៣ "ជំនួយ" ត្រូវបានផ្តល់និយមន័យយ៉ាងទូលំទូលាយក្នុងស្តង់ដានេះ ដើម្បីរួមបញ្ចូលនូវ "ជំនួយខាងក្រៅ" និង "ជំនួយផ្សេងទៀត"។ លក្ខណៈសម្បត្តិនៃជំនួយខាងក្រៅ និងជំនួយផ្សេងទៀតត្រូវបានបង្ហាញដូចខាងក្រោម។

*ជំនួយខាងក្រៅ*

២.១.៨៤ ជំនួយខាងក្រៅ ត្រូវបានផ្តល់និយមន័យថាជា ធនធានផ្ទាល់ការទាំងអស់ដែលគម្រោងអាចប្រើ ឬទទួលបានអត្ថប្រយោជន៍ក្នុងការសម្រេចគោលបំណងរបស់ខ្លួន។ អង្គការផ្សេងគ្នាអាចប្រើវាក្យសព្ទផ្សេងគ្នាសម្រាប់ពាក្យ ជំនួយខាងក្រៅ ឬថ្នាក់នៃជំនួយខាងក្រៅ។ ឧទាហរណ៍ អង្គការមួយចំនួនអាចប្រើពាក្យថា "ជំនួយខាងក្រៅ ឬជំនួយ" (external aid or aid) ជាជាង "ជំនួយខាងក្រៅ" (external assistance)។ នៅក្នុងករណីទាំងនេះ វាក្យសព្ទផ្សេងគ្នាទំនងជាមិនបានបង្កជាការភ័ន្តច្រលំឡើយ។ ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងករណីផ្សេងទៀត វាក្យសព្ទអាចមានភាពខុសគ្នាច្រើន។ នៅក្នុងករណីទាំងនេះ វានឹង

មានភាពចាំបាច់ដើម្បីអនុវត្តការវិនិច្ឆ័យបែបវិជ្ជាជីវៈក្នុងការកំណត់ថាតើធនធានដែលបានផ្តល់ គួរត្រូវបានធ្វើចំណាត់ថ្នាក់ជាជំនួយខាងក្រៅ ឬក៏យ៉ាងណា។

២.១.៨៥ ធនធានផ្លូវការ គឺជាធនធានដែលត្រូវបានផ្តល់ ឬប្តេជ្ញាចិត្តក្រោមកិច្ចព្រមព្រៀងដែលត្រូវអនុវត្តតាមដោយភ្នាក់ងារផ្តល់ជំនួយខាងក្រៅទ្វេភាគីឬពហុភាគី ឬរដ្ឋាភិបាល ឬភ្នាក់ងាររបស់រដ្ឋាភិបាល ជាជាងទៅកាន់គម្យជននៃជាតិសាសន៍ដូចគ្នាទៅនឹងអ្នកផ្តល់ជំនួយ។ រដ្ឋាភិបាល ដូចបានសំដៅដល់នៅក្នុងនិយមន័យនៃពាក្យធនធានផ្លូវការ អាចរួមបញ្ចូលនូវរដ្ឋាភិបាលថ្នាក់ជាតិ ក្រុង ខេត្ត ឬថ្នាក់មូលដ្ឋាននៅក្នុងជាតិសាសន៍ណាមួយ។ ដូច្នេះ ជំនួយដែលត្រូវបានផ្តល់ដោយ ឧទាហរណ៍ រដ្ឋាភិបាលថ្នាក់ជាតិមួយ ឬភ្នាក់ងាររបស់រដ្ឋាភិបាលថ្នាក់ក្រុងនៃជាតិសាសន៍មួយទៅកាន់រដ្ឋាភិបាលថ្នាក់ក្រុង ឬថ្នាក់មូលដ្ឋាននៃជាតិសាសន៍ដទៃ គឺជាជំនួយខាងក្រៅដូចបានផ្តល់និយមន័យនៅក្នុងស្តង់ដានេះ។ ទោះបីជាយ៉ាងណា ជំនួយដែលបានផ្តល់ដោយរដ្ឋាភិបាលថ្នាក់ជាតិ ឬថ្នាក់ក្រុងទៅកាន់កម្រិតរដ្ឋាភិបាលផ្សេងទៀតនៅក្នុងជាតិសាសន៍ដូចគ្នានិងជំនួយដែលបានផ្តល់ដោយអង្គការមិនមែនរដ្ឋាភិបាល សូម្បីតែជំនួយទាំងនោះត្រូវបានផ្តល់ក្រោមកិច្ចព្រមព្រៀងដែលត្រូវអនុវត្តតាម មិនបានបំពេញតាមនិយមន័យនៃពាក្យធនធានផ្លូវការ ហើយដូច្នេះ មិនមែនជាជំនួយខាងក្រៅនោះទេ។

២.១.៨៦ កិច្ចព្រមព្រៀងផ្តល់ជំនួយខាងក្រៅ អាចផ្តល់ដល់ស្ថាប័នដើម្បី÷

(ក) កាត់បន្ថយជាសាច់ប្រាក់នូវចំណូលពេញលេញដែលបានពីឥណទាន ឬអំណោយ ឬចំណែកមួយនៃឥណទាន ឬអំណោយ

(ខ) ស្វែងរកសំណងសម្រាប់កំណត់ចំណាយដែលបានធ្វើឡើងដោយស្ថាប័ន ទៅកាន់ភាគីទីបីដែលទូទាត់សងកាតព្វកិច្ចរបស់ស្ថាប័នជាសាច់ប្រាក់ ដូចត្រូវបានកំណត់ដោយកិច្ចព្រមព្រៀងទទួលឥណទាន ឬអំណោយ ឬ

(គ) ស្នើសុំឱ្យភ្នាក់ងារផ្តល់ជំនួយខាងក្រៅធ្វើការចំណាយដោយផ្ទាល់ទៅកាន់ភាគីទីបី ដែលបានទូទាត់សងកាតព្វកិច្ចរបស់ស្ថាប័នគម្យជនជាសាច់ប្រាក់ ដូចត្រូវបានកំណត់ដោយកិច្ចព្រមព្រៀងផ្តល់ឥណទាន ឬអំណោយ រួមបញ្ចូលទាំងកាតព្វកិច្ចរបស់ស្ថាប័នគម្យជនសម្រាប់ទំនិញឬសេវាដែលបានត្រូវផ្តល់ ឬដែលនឹងត្រូវបានផ្តល់ដោយអង្គការមិនមែនរដ្ឋាភិបាល។

កិច្ចព្រមព្រៀងផ្តល់ជំនួយខាងក្រៅ ក៏អាចរួមបញ្ចូលនូវការផ្តល់ទំនិញ ឬសេវាទៅកាន់គម្យជនផងដែរ។

*ជំនួយផ្សេងទៀត*

២.១.៨៧ ជំនួយផ្សេងទៀតត្រូវបានផ្តល់និយមន័យថាជា ធនធានដែលបានផ្តល់ដោយអង្គការមិនមែនរដ្ឋាភិបាលនិងជំនួយដែលត្រូវបានផ្តល់ដោយស្ម័គ្រចិត្តដោយ ឧទាហរណ៍ បុគ្គល និងអង្គការសប្បុរសធម៌ និងអង្គការផ្សេងទៀត។ ពន្ធនិងធនធានផ្សេងទៀតដែលត្រូវបានទូទាត់ជាចាំបាច់ ឬដែលត្រូវសងទៅកាន់

ស្ថាប័នសាធារណៈ ដោយអនុលោមទៅតាមច្បាប់ ឬបទប្បញ្ញត្តិ ការពិន័យ ឬទោសបញ្ញត្តិ សម្រាប់ការបំពានច្បាប់ឬបទប្បញ្ញត្តិ និងកម្រៃសម្រាប់សេវាដែលត្រូវបានផ្តល់ដោយ ឬជំនួសឱ្យស្ថាប័នសាធារណៈ គឺមិនមែនជាជំនួយផ្សេងទៀត ដូចបានផ្តល់និយមន័យនៅក្នុងកថាខណ្ឌ ២.១.៨២ នោះទេ។ ស្រដៀងគ្នានេះដែរ ធនធានដែលត្រូវបានផ្តល់ជាប្រតិបត្តិការប្តូរប្រាក់ ឬការផ្ទេរធនធានរវាងរដ្ឋាភិបាលនានានៅក្នុងជាតិសាសន៍ដូចគ្នា គឺមិនត្រូវបានចាត់ថ្នាក់ជាជំនួយផ្សេងទៀតឡើយ។

២.១.៨៨ នៅក្នុងករណីភាគច្រើន វានឹងមានភាពច្បាស់លាស់ថាតើធនធានត្រូវបានផ្តល់ដោយស្ម័គ្រចិត្ត និងថាតើចេតនារបស់គេ គឺដើម្បីផ្តល់នូវជំនួយសម្រាប់គោលបំណងនៃ ឧទាហរណ៍ ការដោះស្រាយភាពបន្ទាន់ ឬដើម្បីជួយដល់ស្ថាប័នក្នុងការសម្រេចបាននូវការអភិវឌ្ឍសេដ្ឋកិច្ច ឬគោលបំណងសុខុមាលភាព ឬសម្រាប់គោលបំណងផ្សេងទៀត។ ទោះបីជាយ៉ាងណា នៅក្នុងករណីមួយចំនួន វានឹងមានភាពចាំបាច់ដើម្បីអនុវត្តការវិនិច្ឆ័យបែបវិជ្ជាជីវៈ ក្នុងការកំណត់ថាតើធនធានដែលត្រូវបានផ្តល់គួរត្រូវបានចាត់ថ្នាក់ជាជំនួយផ្សេងទៀត ឬក៏យ៉ាងណា។

២.១.៨៩ អង្គការមិនមែនរដ្ឋាភិបាល គឺជាភ្នាក់ងារជាតិឬបរទេសដែលត្រូវបានបង្កើតឡើងឯករាជ្យពីការគ្រប់គ្រងដោយរដ្ឋាភិបាលណាមួយ។ នៅក្នុងករណីកម្រមួយចំនួន វាមិនអាចមានភាពច្បាស់លាស់ទេថាតើអង្គការម្ចាស់ជំនួយគឺជាភ្នាក់ងារផ្តល់ជំនួយខាងក្រៅទ្វេភាគីឬពហុភាគី ឬជាអង្គការមិនមែនរដ្ឋាភិបាលមួយ ហើយដូច្នេះឯករាជ្យពីការគ្រប់គ្រងដោយរដ្ឋាភិបាលណាមួយ។ នៅពេលដែលអង្គការម្ចាស់ជំនួយទាំងនេះផ្តល់ឬប្តេជ្ញាចិត្តក្នុងការផ្តល់ជំនួយក្រោមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងដែលត្រូវអនុវត្តតាម នោះភាពខុសគ្នារវាងធនធានផ្ទាល់ការ ដូចបានផ្តល់និយមន័យនៅក្នុងស្តង់ដានេះ និងធនធានដែលបានផ្តល់ដោយអង្គការមិនមែនរដ្ឋាភិបាលមួយ អាចនៅមានភាពស្រពិចស្រពិល។ ក្នុងករណីទាំងនេះ ការវិនិច្ឆ័យបែបវិជ្ជាជីវៈនឹងចាំបាច់ត្រូវអនុវត្ត ដើម្បីកំណត់ថាតើជំនួយដែលបានទទួលបំពេញតាមនិយមន័យនៃពាក្យថាជំនួយខាងក្រៅ ឬជំនួយផ្សេងទៀតដែរឬទេ។

**ជំនួយខាងក្រៅដែលបានទទួល**

២.១.៩០ *ស្ថាប័នមួយត្រូវបានលើកទឹកចិត្តឱ្យលាតត្រដាងដាច់ដោយឡែកនៅក្នុងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ នូវ÷*

(ក) *ចំនួនទឹកប្រាក់សរុបនៃជំនួយខាងក្រៅដែលបានទទួលជាសាច់ប្រាក់ នៅក្នុងអំឡុងការិយបរិច្ឆេទ ប្រសិនបើមិនត្រូវបានលាតត្រដាងជាថ្នាក់ដាច់ដោយឡែកមួយនៃចំណូលសាច់ប្រាក់ នៅលើផ្ទៃមុខនៃរបាយការណ៍ចំណូលនិងចំណាយសាច់ប្រាក់នោះទេ*

(ខ) *ជំនួយខាងក្រៅសុរបដែលត្រូវបានទូទាត់ដោយភាគីទីបីនៅក្នុងអំឡុងការិយបរិច្ឆេទ ដើម្បីទូទាត់សងដោយផ្ទាល់នូវកាតព្វកិច្ចរបស់ស្ថាប័ន ឬទិញទំនិញនិងសេវាជំនួសឱ្យស្ថាប័ន នៅពេលត្រូវបានផ្តល់យោបល់ដោយភាគីទីបី ឬក៏ត្រូវបានផ្ទៀងផ្ទាត់ដោយគម្យជន*

(គ) *ចំនួនទឹកប្រាក់សុរបនៃជំនួយខាងក្រៅដែលបានទទួលនៅក្នុងអំឡុងការិយបរិច្ឆេទ ជាឥណទាន និងចំនួនទឹកប្រាក់សុរបដែលបានទទួលជាអំណោយ*

(ឃ) *ថ្នាក់សំខាន់ៗនៃអ្នកផ្តល់ជំនួយខាងក្រៅ និងចំនួនទឹកប្រាក់ដែលបានផ្តល់*

(ង) *ទៅតាមថ្នាក់សំខាន់ៗនិងចំនួនទឹកប្រាក់ គោលបំណងដែលជំនួយខាងក្រៅត្រូវបានទទួល និងត្រូវបានប្រើក្នុងអំឡុងការិយបរិច្ឆេទរាយការណ៍ ដែលបង្ហាញជាច់ដោយឡែកនូវចំនួនទឹកប្រាក់ដែលត្រូវបានផ្តល់តាមរយៈឥណទាន និងអំណោយ និង*

(ច) *សមតុល្យនៃឥណទាននិងអំណោយជាជំនួយខាងក្រៅដែលមិនទាន់បានប្រើប្រាស់ ដែលមាននាកាលបរិច្ឆេទរាយការណ៍ ដើម្បីផ្តល់មូលនិធិដល់ប្រតិបត្តិការនាពេលអនាគត នៅពេលចំនួនទឹកប្រាក់នៃឥណទានឬអំណោយដែលមានសម្រាប់គម្យជនត្រូវបានបញ្ជាក់នៅក្នុងកិច្ចព្រមព្រៀងដែលត្រូវអនុវត្តតាម ហើយការបំពេញទៅតាមលក្ខខណ្ឌសំខាន់ដែលកំណត់ ឬជះឥទ្ធិពលដល់ការទទួលបានចំនួនទឹកប្រាក់នោះ អាចកើតមានឡើង ដែលបង្ហាញជាច់ដោយឡែកនូវ÷*

(១) *ឥណទានជាជំនួយខាងក្រៅសុរប*

(២) *អំណោយជាជំនួយខាងក្រៅសុរប និង*

(៣) *គោលបំណងដែលជំនួយជាឥណទាន និងជំនួយជាអំណោយដែលមិនទាន់បានប្រើប្រាស់អាចត្រូវបានប្រើ។*

**ជំនួយផ្សេងទៀតដែលបានទទួល**

២.១.៩១ *ប្រសិនបើអាចអនុវត្តបាន ស្ថាប័នមួយត្រូវបានលើកទឹកចិត្តឱ្យអនុវត្តការលាតត្រដាង ដូចបានកំណត់នៅក្នុងកថាខណ្ឌ ២.១.៩០ ខាងលើចំពោះជំនួយផ្សេងទៀតដែលបានទទួល។*

**ជំនួយខាងក្រៅ និងជំនួយផ្សេងទៀតដែលបានទទួល**

២.១.៩២ ការលាតត្រដាងអំពីចំនួនទឹកប្រាក់សុរបនៃជំនួយខាងក្រៅដែលបានទទួល និងជំនួយផ្សេងទៀតដែលបានទទួលជាច់ដោយឡែកក្នុងទម្រង់ជាសាច់ប្រាក់ និងក្នុងទម្រង់ជាចំណាយរបស់ភាគីទីបី ដែលត្រូវបានធ្វើឡើងជំនួសឱ្យស្ថាប័ន អាចផ្តល់នូវព័ត៌មានដ៏មានសារៈសំខាន់អំពីវិសាលភាពដែលប្រតិបត្តិការរបស់ស្ថាប័នរាយការណ៍ត្រូវបានផ្តល់មូលនិធិពីពន្ធ និង/ឬ ធនធានផ្ទៃក្នុង ឬពីងផ្ទៃកលើជំនួយខាងក្រៅ និងជំនួយផ្សេងទៀតនិងទម្រង់នៃជំនួយនោះ មិនថាជាសាច់ប្រាក់ ឬអត្ថប្រយោជន៍ដទៃទៀត។ ការលាតត្រដាងអំពីជំនួយខាងក្រៅ និងជំនួយផ្សេងទៀតដែលបានទទួលក្នុងទម្រង់ជាចំណាយដែលបានធ្វើឡើង

ដោយភាគីទីបីត្រូវបានលើកទឹកចិត្តនៅពេលស្ថាប័នត្រូវបានផ្តល់យោបល់ជាផ្លូវការ ឬត្រូវបានផ្ទៀងផ្ទាត់ថា ចំណាយទាំងនេះត្រូវបានធ្វើឡើងនៅក្នុងអំឡុងការិយបរិច្ឆេទរាយការណ៍។

២.១.៩៣ ការលាតត្រដាងអំពីចំនួនទឹកប្រាក់នៃជំនួយខាងក្រៅនិងជំនួយផ្សេងទៀតដែលបានទទួល តាមរយៈ ឥណទាន ឬអំណោយ នឹងអនុញ្ញាតឱ្យអ្នកប្រើប្រាស់អាចកំណត់ថាតើស្ថាប័នមានកាតព្វកិច្ច ដើម្បីទូទាត់សងជំនួយដែលត្រូវបានផ្តល់នាពេលណាមួយនាពេលអនាគត ឬក៏យ៉ាងណា។

២.១.៩៤ ការលាតត្រដាងអំពីថ្នាក់សំខាន់ៗនៃអ្នកផ្តល់ជំនួយដូចជា, ឧទាហរណ៍ ម្ចាស់ជំនួយពហុភាគី, ម្ចាស់ជំនួយទ្វេភាគី, អង្គការផ្តល់ជំនួយអន្តរជាតិ, អង្គការមិនមែនរដ្ឋាភិបាល, អង្គការផ្តល់ជំនួយជាតិ, ឬថ្នាក់សំខាន់ៗផ្សេងទៀតដែលសមស្របចំពោះស្ថាប័នរាយការណ៍ នឹងកំណត់អំពីវិសាលភាពនៃការពឹងផ្អែករបស់ស្ថាប័នទៅលើថ្នាក់ជាក់លាក់ផ្សេងៗនៃអ្នកផ្តល់ជំនួយ និងមានការពាក់ព័ន្ធចំពោះការវាយតម្លៃទៅលើនិរន្តរភាពនៃជំនួយទាំងនោះ។

២.១.៩៥ ស្ថាប័នអាចទទួលបានជំនួយខាងក្រៅសម្រាប់គោលបំណងជាច្រើន រួមបញ្ចូលទាំងជំនួយ ដើម្បីគាំទ្រ÷

(ក) ការអភិវឌ្ឍសេដ្ឋកិច្ច ឬគោលបំណងសុខុមាលភាព ដែលតែងសំដៅដល់ជំនួយអភិវឌ្ឍន៍

(ខ) គោលបំណងដោះស្រាយបញ្ហាបន្ទាន់ ដែលតែងសំដៅដល់ជំនួយបន្ទាន់

(គ) ស្ថានភាពសមតុល្យនៃចំណាយ ឬដើម្បីការពារអត្រាប្តូររូបិយបណ្ណរបស់ខ្លួន ដែលតែងសំដៅដល់ជំនួយលើសមតុល្យនៃចំណាយ

(ឃ) គោលបំណងយោធា និង/ឬ គោលបំណងការពារជាតិ ដែលតែងសំដៅដល់ជំនួយយោធា និង

(ង) សកម្មភាពជួញដូរ រួមបញ្ចូលទាំងការផ្តល់ឥណទាននាំចេញ ឬឥណទានដែលត្រូវបានផ្តល់ដោយធនាគារនាំចេញ/នាំចូល ឬភ្នាក់ងាររបស់រដ្ឋាភិបាលផ្សេងទៀត ដែលតែងសំដៅដល់ហិរញ្ញប្បទានពាណិជ្ជកម្ម។

២.១.៩៦ ជំនួយផ្សេតទៀតក៏អាចត្រូវបានផ្តល់សម្រាប់គោលបំណងមួយចំនួនដូចជា, ឧទាហរណ៍ ការដោះស្រាយបញ្ហាបន្ទាន់ និងដើម្បីគាំទ្រដល់គោលបំណងសុខុមាលភាពរបស់ស្ថាប័ន។

២.១.៩៧ ការលាតត្រដាងទៅតាមថ្នាក់សំខាន់ៗនៃគោលបំណងដែលជំនួយខាងក្រៅនិងជំនួយផ្សេងទៀតត្រូវបានផ្តល់ និងត្រូវបានប្រើនៅក្នុងអំឡុងការិយបរិច្ឆេទរាយការណ៍ នឹងធ្វើឱ្យប្រសើរឡើងនូវគណនេយ្យភាពរបស់ស្ថាប័នសម្រាប់ការប្រើប្រាស់ជំនួយដែលបានទទួលរបស់ខ្លួន។

២.១.៩៨ ចំនួនទឹកប្រាក់នៃជំនួយខាងក្រៅ និងជំនួយពីអង្គការមិនមែនរដ្ឋាភិបាល និងប្រភពផ្សេងទៀត ដែលបច្ចុប្បន្នត្រូវបានបេតជ្ញាចិត្តក្រោមកិច្ចព្រមព្រៀងដែលត្រូវអនុវត្តតាម ប៉ុន្តែមិនទាន់បានប្រើប្រាស់ អាចមានសារៈសំខាន់។ នៅក្នុងករណីមួយចំនួន ចំនួនទឹកប្រាក់នៃឥណទានជាជំនួយ ឬជាអំណោយ ត្រូវបានបញ្ជាក់នៅក្នុងកិច្ចព្រមព្រៀងដែលត្រូវអនុវត្តតាម ហើយការបំពេញទៅតាមលក្ខខណ្ឌណាមួយចាំបាច់

ដែលត្រូវបំពេញដើម្បីទទួលបានចំនួនទឹកប្រាក់នោះ មានអត្រាខ្ពស់។ ករណីនេះអាចកើតឡើងទាក់ទងនឹងសមតុល្យនៃការផ្តល់មូលនិធិដល់គម្រោងដែលមិនទាន់បានប្រើប្រាស់សម្រាប់គម្រោងដែលបច្ចុប្បន្ន ស្ថិតក្រោមការអភិវឌ្ឍដែលលក្ខខណ្ឌត្រូវបានបំពេញតាម និងត្រូវបន្តឱ្យបំពេញតាម ហើយគម្រោងត្រូវបានព្យាករណ៍ថានឹងបន្តក្រោមលក្ខខណ្ឌនៃកិច្ចព្រមព្រៀង។ ការលាតត្រដាងអំពីសមតុល្យនៃជំនួយខាងក្រៅដែលមិនទាន់បានប្រើប្រាស់ និងជំនួយផ្សេងទៀតនៅក្នុងស្ថានភាពទាំងនេះនឹងផ្តល់នូវព័ត៌មានអំពីវិសាលភាពដែលជំនួយដែលមានចំពោះស្ថាប័នត្រូវបានដក នៅក្នុងអំឡុងការិយបរិច្ឆេទរាយការណ៍ ហើយចំនួនទឹកប្រាក់នៃជំនួយខាងក្រៅនិងជំនួយផ្សេងទៀតដែលបានប្តេជ្ញាចិត្ត គឺមានសម្រាប់ការគាំទ្រដល់ការអភិវឌ្ឍជាបន្តបន្ទាប់នៃគម្រោងជាក់លាក់។

២.១.៩៩ នៅក្នុងករណីមួយចំនួន ម្ចាស់ជំនួយអាចបង្ហាញចេតនាមួយដើម្បីផ្តល់ជំនួយជាបន្តបន្ទាប់ទៅកាន់ស្ថាប័នរាយការណ៍ ប៉ុន្តែមិនបានបញ្ជាក់នៅក្នុងកិច្ចព្រមព្រៀងដែលត្រូវអនុវត្តតាម នូវចំនួនទឹកប្រាក់នៃឥណទានជាជំនួយ ឬជាអំណោយដែលត្រូវបានផ្តល់នាការិយបរិច្ឆេទនាពេលអនាគត។ នៅក្នុងករណីផ្សេងទៀត ចំនួនទឹកប្រាក់នៃជំនួយអាចត្រូវបានបញ្ជាក់ ប៉ុន្តែស្ថិតក្រោមលក្ខខណ្ឌ ដែលការបំពេញតាមមិនអាចត្រូវបានវាយតម្លៃថាទំនងជាអាចកើតឡើងនាការិយបរិច្ឆេទរាយការណ៍ឡើយ។ នៅក្នុងករណីទាំងនេះ ការលាតត្រដាងអំពីចំនួនទឹកប្រាក់ដែលមិនទាន់បានប្រើប្រាស់ មិនត្រូវបានលើកទឹកចិត្តដោយកថាខណ្ឌ ២.១.៩០ (ច) នោះទេ។ នៅក្នុងករណីមួយចំនួន ការវិនិច្ឆ័យបែបវិជ្ជាជីវៈអាចចាំបាច់ត្រូវអនុវត្ត ដើម្បីវាយតម្លៃថាតើការបំពេញតាមលក្ខខណ្ឌដែលកំណត់ ឬជះឥទ្ធិពលដល់ការទទួលបានជំនួយខាងក្រៅ ឬជំនួយផ្សេងទៀត គឺទំនងជាអាចកើតឡើង ឬក៏យ៉ាងណា។

**ទំនិញ និងសេវាដែលបានទទួល**

២.១.១០០ *ស្ថាប័នមួយ ត្រូវបានលើកទឹកចិត្តឱ្យលាតត្រដាងដាច់ដោយឡែកនៅក្នុងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ នូវតម្លៃនៃជំនួយដែលបានទទួលនៅក្នុងអំឡុងការិយបរិច្ឆេទក្នុងទម្រង់ជាទំនិញ ឬសេវា និងមូលដ្ឋានដែលតម្លៃនោះត្រូវបានកំណត់។*

២.១.១០១ ធនធានសំខាន់ៗអាចត្រូវបានទទួលជាជំនួយក្នុងទម្រង់ជាទំនិញឬសេវា។ វានឹងកើតឡើងនៅពេលដែលទំនិញថ្មី ឬទំនិញដែលបានប្រើប្រាស់រួច ដូចជា ទោចក្រយានយន្ត កុំព្យូទ័រ ឬបរិក្ខារផ្សេងទៀតត្រូវបានផ្ទេរទៅកាន់ស្ថាប័នក្រោមកិច្ចព្រមព្រៀងផ្តល់ជំនួយខាងក្រៅ ឬដោយ ឧទាហរណ៍ ឧបការីរបស់អង្គការមិនមែនរដ្ឋាភិបាល ឬវិស័យឯកជន។ វាក៏នឹងកើតឡើងផងដែរ នៅពេលជំនួយជាអាហារត្រូវបានផ្តល់ឱ្យរដ្ឋាភិបាលមួយ ដើម្បីចែកចាយទៅកាន់ប្រជាពលរដ្ឋរបស់ខ្លួនជាការដោះស្រាយបញ្ហាបន្ទាន់ក្រោមកិច្ចព្រមព្រៀងផ្តល់ជំនួយខាងក្រៅ ឬដោយម្ចាស់ជំនួយរបស់អង្គការមិនមែនរដ្ឋាភិបាល ឬម្ចាស់ជំនួយផ្សេងទៀត។ សម្រាប់គម្យជនមួយចំនួន ទំនិញឬសេវាអាចជាទម្រង់ដ៏សំខាន់ដែលជំនួយត្រូវបានទទួល។

២.១.១០២ ការលាតត្រដាងអំពីតម្លៃនៃជំនួយដែលបានទទួលជាទំនិញនិងសេវាក្នុងអំឡុងការិយបរិច្ឆេទរាយការណ៍នឹងជួយឱ្យអ្នកអានរបាយការណ៍ហិរញ្ញវត្ថុយល់បានកាន់តែប្រសើរអំពីវិសាលភាពពេញលេញនៃជំនួយ

ដែលបានទទួលនៅក្នុងអំឡុងការិយបរិច្ឆេទរាយការណ៍។ ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងករណីមួយចំនួន និងសម្រាប់គម្យជនមួយចំនួន ការកំណត់តម្លៃទំនិញ និងសេវាទាំងនោះ អាចជាដំណើរការដ៏លំបាកមួយដែលត្រូវការពេលវេលានិងថវិកាច្រើន។ វាគឺដូច្នេះនៅពេលតម្លៃទីផ្សារក្នុងស្រុកសម្រាប់ទំនិញនិងសេវាទាំងនោះមិនអាចត្រូវបានកំណត់ឱ្យបានឆាប់រហ័ស ខណៈដែលទំនិញនិងសេវាដែលបានផ្តល់មិនត្រូវបានជួញដូរឱ្យបានទូលំទូលាយនៅក្នុងទីផ្សារអន្តរជាតិឡើយ ឬនៅពេលដែលទំនិញនិងសេវាមានថវិកលក្ខណៈពិសេសដាច់ដោយឡែកពីគេ ដូចជាតែងតែកើតមានឡើង ពាក់ព័ន្ធនឹងជំនួយបន្ទាន់។

២.១.១០៣ ស្តង់ដានេះ មិនបានបញ្ជាក់ពីមូលដ្ឋានដែលតម្លៃទំនិញឬសេវានឹងត្រូវបានកំណត់នោះទេ។ ដូច្នេះ តម្លៃរបស់ពួកគេអាចត្រូវបានកំណត់ជាថ្លៃដើមប្រវត្តិសាស្ត្រនៃទ្រព្យសកម្មរូបិយដែលបានធ្លាក់ថ្លៃ ស្របពេលដែលទ្រព្យសកម្មត្រូវបានផ្ទេរទៅឱ្យគម្យជន ឬតម្លៃដែលបានទូទាត់សម្រាប់អាហារដោយភ្នាក់ងារផ្តល់ជំនួយខាងក្រៅ ឬម្ចាស់ជំនួយផ្សេងទៀត។ វាក៏អាចត្រូវបានកំណត់ ដោយផ្អែកលើមូលដ្ឋាននៃការវាយតម្លៃទៅលើតម្លៃដោយថ្នាក់ដឹកនាំរបស់អ្នកផ្ទេរ ឬគម្យជន ឬដោយភាគីទីបី ។ នៅពេលតម្លៃជំនួយក្នុងទម្រង់ជាទំនិញ ឬសេវាត្រូវបានលាតត្រដាង នោះកថាខណ្ឌ ២.១.១០០ បានលើកទឹកចិត្តឱ្យមានការលាតត្រដាងអំពីមូលដ្ឋានដែលតម្លៃនោះត្រូវបានកំណត់។ នៅពេលដែលតម្លៃនេះត្រូវបានពិពណ៌នាជាតម្លៃទីផ្សារ វានឹងស្របជាមួយនឹងនិយមន័យនៃតម្លៃទីផ្សារ ពោលគឺចំនួនទឹកប្រាក់ដែលទ្រព្យសកម្មមួយអាចត្រូវបានដោះដូរ ឬបំណុលត្រូវបានទូទាត់សងរវាងភាគីស្ម័គ្រចិត្តដែលមានចំណេះដឹងនៅក្នុងប្រតិបត្តិការបើកចំហ។

**២.២ រដ្ឋាភិបាល និងស្ថាប័នសាធារណៈដទៃទៀត ដែលបំពេញដំណើរនៃការផ្លាស់ប្តូរទៅកាន់មូលដ្ឋានបង្គរនៃការរាយការណ៍ហិរញ្ញវត្ថុ និងការអនុវត្តស្តង់ដាគណនេយ្យសាធារណៈ: មូលដ្ឋានបង្គរការដាក់បង្ហាញរបាយការណ៍ចំណូលនិងចំណាយសាច់ប្រាក់**

*២.២.១ ស្ថាប័នមួយដែលកំពុងតែបំពេញដំណើរនៃការផ្លាស់ប្តូររបស់ខ្លួនទៅកាន់មូលដ្ឋានបង្គរ នៃការរាយការណ៍ហិរញ្ញវត្ថុនិងការអនុវត្តស្តង់ដាគណនេយ្យសាធារណៈមូលដ្ឋានបង្គរ ត្រូវបានលើកទឹកចិត្តឱ្យដាក់បង្ហាញរបាយការណ៍ចំណូលនិងចំណាយសាច់ប្រាក់ ក្នុងទ្រង់ទ្រាយដូចគ្នាទៅនឹងរបាយការណ៍ដែលបានតម្រូវដោយស្តង់ដា IPSAS ២, របាយការណ៍លំហូរសាច់ប្រាក់។*

២.២.២ នៅពេលស្ថាប័នផ្លាស់ប្តូរទៅកាន់មូលដ្ឋានបង្គរនៃការរាយការណ៍ហិរញ្ញវត្ថុ ស្ថាប័ននឹងចាំបាច់ត្រូវកសាងជាបន្តបន្ទាប់នូវព័ត៌មាននិងប្រព័ន្ធចាំបាច់ ដើម្បីអនុលោមតាមស្តង់ដាគណនេយ្យសាធារណៈមូលដ្ឋានបង្គរនីមួយៗលើបញ្ហាដែលបានកើតឡើងមុនការអនុវត្តផ្លូវការនៃស្តង់ដាគណនេយ្យសាធារណៈមូលដ្ឋានបង្គរ។ ការដាក់បង្ហាញព័ត៌មានក្នុងទម្រង់មួយដែលដូចគ្នាតាមដែលអាចទៅរួច ទៅនឹងទម្រង់ដែលបានអនុវត្តដោយស្តង់ដាគណនេយ្យសាធារណៈ មូលដ្ឋានបង្គរ នឹងជួយដល់ដំណើរការអន្តរការណ៍នេះ។

២.២.៣ IPSAS ២ ផ្តល់នូវសេចក្តីណែនាំលើការធ្វើចំណាត់ថ្នាក់លំហូរសាច់ប្រាក់ ជាសកម្មភាពប្រតិបត្តិការ, សកម្មភាពហិរញ្ញប្បទាន និងសកម្មភាពវិនិយោគ និងរួមបញ្ចូលនូវលក្ខខណ្ឌចាំបាច់សម្រាប់ការរៀបចំរបាយការណ៍លំហូរសាច់ប្រាក់មួយ ដែលរាយការណ៍អំពីថ្នាក់ទាំងនេះដាច់ដោយឡែកនៅលើផ្នែកមុខនៃរបាយការណ៍។ ការសង្ខេបអំពីផ្នែកសំខាន់ៗនៃស្តង់ដា IPSAS ២ និងសេចក្តីណែនាំលើការអនុវត្តសម្រាប់ការរាយការណ៍ហិរញ្ញវត្ថុក្រោមស្តង់ដានេះ ត្រូវបានរួមបញ្ចូលនៅក្នុងឧបសម្ព័ន្ធ ៣។ ផ្នែកទី ២ នៃស្តង់ដានេះលើកទឹកចិត្តឱ្យមានការលាតត្រដាងអំពីព័ត៌មាន បន្ថែមពីលើព័ត៌មានដែលបានតម្រូវដោយស្តង់ដា IPSAS ២។ ស្ថាប័នដែលប្រើទម្រង់តាមស្តង់ដា IPSAS ២ សម្រាប់ការដាក់បង្ហាញរបាយការណ៍ចំណូល និងចំណាយសាច់ប្រាក់ ត្រូវបានលើកទឹកចិត្តឱ្យធ្វើការលាតត្រដាងបន្ថែមផងដែរដូចបានកំណត់នៅក្នុងផ្នែកទី ២ នៃស្តង់ដានេះ។

**របាយការណ៍ហិរញ្ញវត្ថុរួម -- ស្ថាប័នសេដ្ឋកិច្ច**

២.២.៤ ស្តង់ដានេះលើកទឹកចិត្តឱ្យស្ថាប័នគ្រប់គ្រងធ្វើការដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុរួម ដែលរួមបញ្ចូលនូវស្ថាប័នក្រោមការគ្រប់គ្រងទាំងអស់ ដោយអនុលោមតាមដំណើរការរួមបញ្ចូលដែលបានទទួលយកជាទូទៅ និងកំណត់ពីស្ថានភាពមួយចំនួនដែលវាអាចមិនមានភាពចាំបាច់។ ស្ថានភាពទាំងនេះឆ្លុះបញ្ចាំងពីដំណើរការទាំងនោះនៅក្នុងស្តង់ដា IPSAS ៣៥, *របាយការណ៍ហិរញ្ញវត្ថុរួម*។ ទោះបីជាយ៉ាងណាក៏ដោយ IPSAS ៣៥ រួមបញ្ចូលនូវការលើកលែងបន្ថែមពីលក្ខខណ្ឌចាំបាច់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរួមសម្រាប់ស្ថាប័នគ្រប់គ្រងដែលជាស្ថាប័នវិនិយោគ និងវាស់វែងស្ថាប័នក្រោមការគ្រប់គ្រងរបស់ពួកគេទៅតាមតម្លៃទីផ្សារតាមរយៈអតិរេក ឬខិនភាព។ ការលើកលែងនេះមិនបានអនុវត្តចំពោះស្ថាប័នគ្រប់គ្រងដែលជាស្ថាប័នវិនិយោគ និងអនុវត្តស្តង់ដាគណនេយ្យសាធារណៈកម្ពុជា មូលដ្ឋានសាច់ប្រាក់នោះទេ។

២.២.៥ នៅពេលរបាយការណ៍ហិរញ្ញវត្ថុដែលរួមបញ្ចូលនូវស្ថាប័នក្រោមការគ្រប់គ្រងទាំងអស់ មិនត្រូវបានដាក់បង្ហាញ ស្តង់ដានេះលើកទឹកចិត្តឱ្យមានការដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុដែលដាក់បង្ហាញព័ត៌មានអំពីស្ថាប័នសេដ្ឋកិច្ចមួយដែលរួមមាន ក្រុមរងនៃស្ថាប័នក្រោមការគ្រប់គ្រងដូចជាក្រុមរងដែលឆ្លុះបញ្ចាំងពីវិស័យថវិកា ឬវិស័យរដ្ឋាភិបាលទូទៅ ឬតំណាងផ្សេងទៀតនៃសកម្មភាពស្នូលរបស់រដ្ឋាភិបាល។ នៅពេលស្តង់ដាគណនេយ្យសាធារណៈ មូលដ្ឋានបង្គរ មិនបានហាមឃាត់ការដាក់បង្ហាញព័ត៌មានអំពីស្ថាប័នសេដ្ឋកិច្ចទាំងនោះ ព័ត៌មានទាំងនោះមិនអាចត្រូវបានដាក់បង្ហាញជាជម្រើសបន្ថែមចំពោះការរួមបញ្ចូលនៃស្ថាប័នក្រោមការគ្រប់គ្រងទាំងអស់ ដូចបានបង្ហាញនៅក្នុងស្តង់ដា IPSAS ៣៥ នោះទេ។

២.២.៦ ស្ថាប័នដែលកំពុងបំពេញដំណើរនៃការផ្លាស់ប្តូរទៅកាន់មូលដ្ឋានបង្គរនៃការរាយការណ៍ហិរញ្ញវត្ថុ និងការអនុវត្តស្តង់ដាគណនេយ្យសាធារណៈ មូលដ្ឋានបង្គរ នឹងចាំបាច់ត្រូវដឹងអំពីភាពខុសគ្នានៃលក្ខខណ្ឌចាំបាច់នៃការរួមបញ្ចូលនៃស្តង់ដាគណនេយ្យសាធារណៈកម្ពុជាមូលដ្ឋានសាច់ប្រាក់ និងស្តង់ដាគណនេយ្យសាធារណៈ មូលដ្ឋានបង្គរ។

**ការលាតត្រដាងដែលបានតម្រូវ និងការលាតត្រដាងដែលត្រូវបានលើកទឹកចិត្ត ក្រោមស្តង់ដាគណនេយ្យសាធារណៈកម្ពុជា មូលដ្ឋានសាច់ប្រាក់**

២.២.៧ លក្ខខណ្ឌចាំបាច់ និងការលើកទឹកចិត្តនៃស្តង់ដានេះ មិនមែនមិនមានសង្គតិភាពជាមួយនឹងលក្ខខណ្ឌចាំបាច់ និងការលើកទឹកចិត្តនៃស្តង់ដាគណនេយ្យសាធារណៈមូលដ្ឋានបង្គរសមមូលនោះទេ នៅក្នុងវិសាលភាពដែលពួកគេអនុវត្តចំពោះការរាយការណ៍ហិរញ្ញវត្ថុតាមមូលដ្ឋានសាច់ប្រាក់។ ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងករណីមួយចំនួន ស្តង់ដានេះលើកទឹកចិត្តឱ្យមានការលាតត្រដាងដែលមិនបានតម្រូវដោយស្តង់ដាគណនេយ្យសាធារណៈ មូលដ្ឋានបង្គរ។ នេះកើតឡើងទាក់ទងនឹង ឧទាហរណ៍ ការលាតត្រដាងដែលបានលើកទឹកចិត្តអំពីបញ្ហាដូចជា ចំណាយរបស់ភាគីទីបី និងជំនួយខាងក្រៅ និងជំនួយផ្សេងទៀត។ ការលាតត្រដាងទាំងនេះត្រូវបានលើកទឹកចិត្តនៅក្នុងស្តង់ដានេះ ដើម្បីផ្តល់នូវព័ត៌មានបន្ថែមដែលមានសារៈសំខាន់ក្នុងការវាយតម្លៃអំពីរបៀបដែលស្ថាប័នត្រូវបានផ្តល់ធនធាន។ ព័ត៌មានទាំងនេះមានសារៈសំខាន់ចំពោះអ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុសម្រាប់គោលបំណងទូទៅទាំងអស់ សម្រាប់គោលបំណងគណនេយ្យភាព និងការធ្វើសេចក្តីសម្រេចចិត្ត។ វាក៏អាចពាក់ព័ន្ធនឹងតម្រូវការនៃ "គោលបំណងពិសេស" ឧទាហរណ៍ អំពីអ្នកផ្តល់ជំនួយខាងក្រៅ និងជំនួយផ្សេងទៀតសម្រាប់ព័ត៌មានដែលមានសារៈសំខាន់ក្នុងការត្រួតពិនិត្យការផ្តល់និងការប្រើប្រាស់ជំនួយដែលបានផ្តល់ទៅកាន់ស្ថាប័ន។

**IPSAS ៣៣ - ការអនុវត្តស្តង់ដាគណនេយ្យសាធារណៈ: មូលដ្ឋានបង្គរ ជាលើកដំបូង**

២.២.៨ ស្តង់ដា IPSAS ៣៣, *ការអនុវត្តស្តង់ដាគណនេយ្យសាធារណៈ: មូលដ្ឋានបង្គរ ជាលើកដំបូង* បានកំណត់អំពីបទប្បញ្ញត្តិអន្តរកាលដែលផ្តល់ឱ្យស្ថាប័ននូវដំណោះស្រាយពីការអនុវត្តលក្ខខណ្ឌចាំបាច់ជាក់លាក់នៃស្តង់ដាគណនេយ្យសាធារណៈ មូលដ្ឋានបង្គរ សម្រាប់រយៈពេលបីឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការអនុវត្តស្តង់ដាគណនេយ្យសាធារណៈ មូលដ្ឋានបង្គរ ជាលើកដំបូង។ ស្តង់ដា IPSAS ៣៣ បានចែងថា នាកាលបរិច្ឆេទនៃការអនុវត្តស្តង់ដា IPSAS អ្នកប្រើប្រាស់ជាលើកដំបូងអាចជ្រើសរើសអនុវត្តការលើកលែងមួយក្នុងចំណោមការលើកលែងជាច្រើនដែលមាននៅក្នុងស្តង់ដា IPSAS ៣៣ ហើយអាស្រ័យទៅលើចរិកលក្ខណៈនៃការលើកលែងដែលបានអនុវត្ត អាចកំណត់របាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនជា÷

(ក) របាយការណ៍ហិរញ្ញវត្ថុតាមស្តង់ដា IPSAS អន្តរកាល នៅពេលអ្នកប្រើប្រាស់អនុវត្តការលើកលែងដូចបានកំណត់ក្នុងស្តង់ដា IPSAS ៣៣ ថាជា "ការលើកលែងដែលប៉ះពាល់ដល់ការដាក់បង្ហាញដ៏ត្រឹមត្រូវ និងការអនុលោមទៅតាមស្តង់ដាគណនេយ្យសាធារណៈ មូលដ្ឋានបង្គរ" ឬ

(ខ) របាយការណ៍ហិរញ្ញវត្ថុ ដែលអនុលោមតាមស្តង់ដាគណនេយ្យសាធារណៈ មូលដ្ឋានបង្គរ នៅពេលអ្នកប្រើប្រាស់អនុវត្តការលើកលែងផ្សេងទៀត ដូចបានកំណត់នៅក្នុងស្តង់ដា IPSAS ៣៣។ នោះគឺជាការលើកលែងដូចបានកំណត់នៅក្នុងស្តង់ដា IPSAS ៣៣ ថាជា

"ការលើកលែងដែលមិនប៉ះពាល់ដល់ការដាក់បង្ហាញដ៏ត្រឹមត្រូវ និងការអនុលោមទៅតាមស្តង់ដាគណនេយ្យសាធារណៈ មូលដ្ឋានបង្គរ"។

២.២.៩ ឧបសម្ព័ន្ធ "ក" នៃស្តង់ដា IPSAS ៣៣ រាយនាមអំពីការលើកលែង និងបទប្បញ្ញត្តិអន្តរកាលដែលអ្នកប្រើប្រាស់ជាលើកដំបូង ត្រូវបានតម្រូវឱ្យអនុវត្ត និង/ឬ អាចជ្រើសរើសក្នុងការអនុវត្តការប្រើប្រាស់ស្តង់ដាគណនេយ្យសាធារណៈ មូលដ្ឋានបង្គរ និងបង្ហាញថាតើការដាក់បង្ហាញដ៏ត្រឹមត្រូវ និងសមត្ថភាពរបស់អ្នកប្រើប្រាស់ជាលើកដំបូង ដើម្បីអះអាងអនុលោមភាពជាមួយនឹងស្តង់ដាគណនេយ្យសាធារណៈ មូលដ្ឋានបង្គរ នឹងត្រូវបានជះឥទ្ធិពល ឬក៏យ៉ាងណា។

**ឧបសម្ព័ន្ធ ២**

**ការបង្ហាញពីការលាតត្រដាងជាក់លាក់ដែលត្រូវបានលើកទឹកចិត្តនៅក្នុង ផ្នែកទី២ នៃស្តង់ដា**

*ឧបសម្ព័ន្ធនេះគឺសម្រាប់បង្ហាញតែប៉ុណ្ណោះ។ គោលបំណងនៃឧបសម្ព័ន្ធ គឺដើម្បីបង្ហាញពីការអនុវត្តការលើកទឹកចិត្ត និងដើម្បីជាជំនួយក្នុងការបញ្ជាក់ឱ្យបានច្បាស់ពីអត្ថន័យរបស់ពួកគេ។*

**<u>ដកស្រង់ចេញពីកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុរបស់ស្ថាប័នរដ្ឋាភិបាល "កខគ"</u>**

***ប្រតិបត្តិការដែលបានគ្រប់គ្រង (កថាខណ្ឌ ២.១.ខ)***

ប្រតិបត្តិការដែលបានគ្រប់គ្រង រួមមាន លំហូរសាច់ប្រាក់ដែលកើតចេញពីប្រតិបត្តិការដែលបានគ្រប់គ្រងដោយស្ថាប័នជាភ្នាក់ងារមួយជំនួសឱ្យរដ្ឋាភិបាល និងស្ថាប័នរដ្ឋាភិបាលជាក់លាក់។ សាច់ប្រាក់ទាំងអស់ដែលប្រមូលបានក្នុងនាមជាភ្នាក់ងារមួយត្រូវបានដាក់បញ្ចើនៅក្នុងមូលនិធិចំណូលរួម និង/ឬ គណនីបរធន (ឈ្មោះ គណនី) តាមភាពសមស្រប។ គណនីទាំងនេះមិនត្រូវបានគ្រប់គ្រងដោយស្ថាប័ន ហើយសាច់ប្រាក់ដែលបានដាក់បញ្ចើនៅក្នុងគណនីទាំងនេះ មិនអាចត្រូវបានប្រើដោយស្ថាប័នដោយគ្មានការផ្តល់សិទ្ធិជាក់លាក់ ដោយស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធឡើយ។

| (ឯកតារូបិយបណ្ណគិតជាខ្នង់ពាន់) | ចរិកលក្ខណៈនៃប្រតិបត្តិការ | ២០០X | ២០០X-១ |
|---|---|---|---|
| សាច់ប្រាក់ដែលប្រមូលបានជំនួសឱ្យ | | | |
| នាយកប្រតិបត្តិ/អ្នកគ្រប់គ្រង | ការប្រមូលពន្ធ | X | X |
| ភ្នាក់ងារ "ឯច" | ការប្រមូលកម្រៃសេវាប្រើប្រាស់ | <u>X</u> | <u>X</u> |
| | | X | X |
| សាច់ប្រាក់ដែលបានផ្ទេរទៅឱ្យស្ថាប័ននីមួយ។ | | (X) | (X) |
| | | - | - |

**ប្រតិបត្តិការរបស់ភាគីពាក់ព័ន្ធ (កថាខណ្ឌ ២.១.២២)**

ថ្នាក់ដឹកនាំសំខាន់ៗ (ដូចបានផ្តល់និយមន័យដោយស្តង់ដា IPSAS ២០, *ការលាតត្រដាងរបស់ភាគីពាក់ព័ន្ធ*) របស់ស្ថាប័ន "កខគ" គឺជារដ្ឋមន្ត្រី, សមាជិកក្រុមប្រឹក្សាភិបាល (សមាជិកនៃស្ថាប័នរដ្ឋាភិបាល) និងសមាជិកនៃក្រុមថ្នាក់ដឹកនាំជាន់ខ្ពស់។ ក្រុមប្រឹក្សាភិបាល រួមមាន សមាជិកដែលបានចាត់តាំងដោយរដ្ឋាភិបាល "ក"។ នាយកប្រតិបត្តិ និង

ប្រធាននាយកហិរញ្ញវត្ថុចូលរួមកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល ប៉ុន្តែមិនមែនជាសមាជិកនៃក្រុមប្រឹក្សាភិបាលឡើយ។ រដ្ឋមន្ត្រីមិនត្រូវបានផ្តល់ប្រាក់ឈ្នួលដោយ ស្ថាប័ន "កខគ" នោះទេ។ លាភការសរុបរបស់សមាជិកក្រុមប្រឹក្សាភិបាល និងចំនួនសមាជិកដូចបានកំណត់ផ្អែកលើមូលដ្ឋានសមមូលពេញម៉ោងដែលទទួលបានលាភការនៅក្នុងខ្ពង់នេះ គឺ÷

| | |
|---|---|
| លាភការសរុប | XX លាន |
| ចំនួនមនុស្ស | XX នាក់ |

ក្រុមថ្នាក់ដឹកនាំជាន់ខ្ពស់ រួមមាន នាយកប្រតិបត្តិ, ប្រធាននាយកហិរញ្ញវត្ថុ និងប្រធាននាយកដ្ឋាន។ លាភការសរុបរបស់សមាជិកនៃក្រុមថ្នាក់ដឹកនាំជាន់ខ្ពស់ និងចំនួនអ្នកគ្រប់គ្រងដូចបានកំណត់ផ្អែកលើមូលដ្ឋានសមមូលពេញម៉ោងដែលទទួលបានលាភការនៅក្នុងខ្ពង់នេះ គឺ÷

| | |
|---|---|
| លាភការសរុប | XX លាន |
| ចំនួនមនុស្ស | XX នាក់ |

ឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសលេខ ៥៤៥ សហវ-ប្រក ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១៩

**<u>រដ្ឋាភិបាល "X"÷ របាយការណ៍ចំណូលនិងចំណាយសាច់ប្រាក់រួម របស់រដ្ឋាភិបាល "X"</u>**

**<u>ជាមួយនិងការកត់ត្រាពីកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ របស់រដ្ឋាភិបាល "X"</u>**

**រដ្ឋាភិបាល "X"÷ របាយការណ៍ចំណូលនិងចំណាយសាច់ប្រាក់រួម**

**សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០X (*ឧទាហរណ៍ ២.១.៣៧*)**

**(*ចំណូល*)**

| | កំណត់សម្គាល់ | ២០០X | | ២០០X-១ | |
|---|---|---|---|---|---|
| (ឯកតារូបិយបណ្ណគិតជាខ្នង់ពាន់) | | ចំណូល/(ចំណាយ) | | ចំណូល/(ចំណាយ) | |
| ចំណូល | | | | | |
| *ពន្ធ* | | | | | |
| ពន្ធលើប្រាក់ចំណូល | | X | | X | |
| អាករលើតម្លៃបន្ថែម | | X | | X | |
| ពន្ធលើអចលនទ្រព្យ | | X | | X | |
| ពន្ធផ្សេងៗ | | <u>X</u> | | <u>X</u> | |
| | | | X | | X |
| ជំនួយខាងក្រៅ និងជំនួយផ្សេងទៀត | ច | | X | | X |
| *កម្ចី* | | | | | |
| ចំណូលពី | | | | | |
| ស្ថាប័នពាណិជ្ជកម្ម | | | X | | |
| ធនាគារអភិវឌ្ឍន៍ និងអង្គការប្រហាក់ប្រហែល | | | X | | |
| *ចំណូលមូលធន* | | | | | |
| ចំណូលពីការលក់ដោងចក្រ និងបរិក្ខារ | | | X | | X |
| ចំណូលពីការលក់ឧបករណ៍ហិរញ្ញវត្ថុ | | | X | | X |
| *សកម្មភាពផ្ទាល់ខ្លួន* | | | | | |
| ចំណូលពីសកម្មភាពផ្ទាល់ខ្លួន | | | X | | X |
| *ចំណូលផ្សេងៗ* | | | X | | X |
| ចំណូលសរុប | | | **X** | | **X** |

ឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសលេខ ៥៤៥ សហវ-ប្រក ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១៩

**រដ្ឋាភិបាល "X"÷ ១ឆ្នាយការណ៍ចំណូលនិងចំណាយសាច់ប្រាក់រួម**

**សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២OOX**

***(ចំណាយ)***

| | កំណត់សម្គាល់ | ២OOX | | ២OOX-១ | |
|---|---|---|---|---|---|
| (ឯកតារូបិយបណ្ណគិតជាខ្នង់ពាន់) | | ចំណូល/(ចំណាយ) | | ចំណូល/(ចំណាយ) | |
| ចំណាយ | | | | | |
| *ប្រតិបត្តិការ* | | | | | |
| ប្រាក់ឈ្នួល ប្រាក់ខែ និងអត្ថប្រយោជន៍និយោជិក | | (X) | | (X) | |
| សម្ភារៈ និងគ្រឿងប្រើប្រាស់ | | (X) | | (X) | |
| | | | (X) | | (X) |
| *ការផ្ទេរ* | | | | | |
| អំណោយ | | (X) | | (X) | |
| ការផ្ទេរកញ្ចប់ចំណាយផ្សេងទៀត | | (X) | | (X) | |
| | | | (X) | | (X) |
| *ចំណាយមូលធន* | | | | | |
| ការទិញ/ការសាងសង់អគារ ចក្រ និងបរិក្ខារ | | (X) | | (X) | |
| ការទិញឧបករណ៍ហិរញ្ញវត្ថុ | | (X) | | (X) | |
| | | | (X) | | (X) |
| *ការទូទាត់សងឥណទាន និងការប្រាក់* | | | | | |
| ការទូទាត់សងកម្ចី | | (X) | | (X) | |
| ការទូទាត់ការប្រាក់ | | (X) | | (X) | |
| | | | (X) | | (X) |
| *ចំណាយផ្សេងៗ* | | | (X) | | (X) |
| ចំណាយសរុប | | | (X) | | (X) |
| ការកើនឡើង/(ការថយចុះ) នៃសាច់ប្រាក់ | | | X | | X |
| សាច់ប្រាក់ដើមគ្រា | | | X | | X |
| ការកើនឡើង/(ការថយចុះ) នៃសាច់ប្រាក់ | | | X | | X |
| សាច់ប្រាក់ចុងគ្រា | | | X | | X |

**<u>កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុរួម របស់រដ្ឋាភិបាល "X"</u>**

*(ការដកស្រង់ដែលបង្ហាញពីការលាតត្រដាងដែលត្រូវបានលើកទឹកចិត្ត)*

**<u>*កំណត់សម្គាល់ "ក"÷ ស្ថាប័នក្រោមការគ្រប់គ្រង (កថាខណ្ឌ ២.១.៥៣)*</u>**

ស្ថាប័ន "XYZ" មានសិទ្ធិចំពោះអត្ថប្រយោជន៍អថេរ ពីការចូលរួមរបស់ខ្លួនជាមួយនឹងស្ថាប័នក្រោមការគ្រប់គ្រង និងមានសមត្ថភាពក្នុងការជះឥទ្ធិពលដល់ចរិកលក្ខណៈ ឬចំនួននៃអត្ថប្រយោជន៍ទាំងនោះតាមរយៈអំណាចរបស់ខ្លួនទៅលើស្ថាប័នទាំងនោះ។ ស្ថាប័នក្រោមការគ្រប់គ្រងទាំងអស់ ត្រូវបានរួមបញ្ចូលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរួម។ ស្ថាប័នក្រោមការគ្រប់គ្រងសំខាន់ៗ ត្រូវបានកំណត់ដូចខាងក្រោម។

| <u>ស្ថាប័នក្រោមការគ្រប់គ្រងសំខាន់ៗ</u> | <u>យុត្តាធិការ</u> |
|---|---|
| ស្ថាប័ន ក | |
| ស្ថាប័ន ខ | |
| ស្ថាប័ន គ | X |
| ស្ថាប័ន ឃ | |
| ស្ថាប័ន ង | |
| ស្ថាប័ន ច | |
| ស្ថាប័ន ឆ | |
| ស្ថាប័ន ជ | X |
| ស្ថាប័ន ឈ | |
| ស្ថាប័ន ញ | |

ការគ្រប់គ្រងលើស្ថាប័នរដ្ឋាភិបាលកើតឡើងតាមរយៈលក្ខន្តិកៈ ឬច្បាប់អនុញ្ញាតផ្សេងទៀត។ ការគ្រប់គ្រងលើស្ថាប័នសាធារណៈពាណិជ្ជកម្ម (ស្ថាប័នពាណិជ្ជកម្ម) កើតឡើងតាមរយៈលក្ខន្តិកៈ ហើយនៅក្នុងករណីនៃស្ថាប័នពាណិជ្ជកម្ម "គ" និង "ឃ" គឺតាមរយៈផលប្រយោជន៍នៃភាពជាម្ចាស់កម្មសិទ្ធិ។ រដ្ឋាភិបាលរក្សាទុកការគ្រប់គ្រងលើស្ថាប័នពាណិជ្ជកម្ម "ញ" តាមរយៈអាជ្ញាធរអង្គនីតិបញ្ញត្តិ បើទោះបីជាភាគច្រើននៃសមធម៌របស់ស្ថាប័នពាណិជ្ជកម្ម "ញ" ត្រូវបានលក់ទៅឱ្យវិនិយោគិនវិស័យឯកជនក៏ដោយ។

| ស្ថាប័ន | ការប្រាក់នៃភាពជាម្ចាស់កម្មសិទ្ធិ (%) | អំណាចនៃការបោះឆ្នោត (%) |
|---|---|---|
| ស្ថាប័ន គ | XX | XX |
| ស្ថាប័ន ឃ | XX | XX |
| ស្ថាប័ន ញ | XX | XX |

*(ការដកស្រង់ចេញពីកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុរួម របស់រដ្ឋាភិបាល "X" បន្ត)*

**ការវិនិយោគស្ថាប័នក្រោមការគ្រប់គ្រង និងស្ថាប័នប្រតិបត្តិចំណុះ *(កថាខណ្ឌ ២.១.៥៧ និង កថាខណ្ឌ ២.១.៥៨)***

| ឈ្មោះស្ថាប័ន ដែលត្រូវបានទិញ | ចំនួនភាគហ៊ុន ដែលត្រូវបានទិញ % | ការពិចារណា លើការទិញ (ឯកតារូបិយបណ្ណ គិតជាខ្នង់ពាន់) | ចំនួនសាច់ប្រាក់នៃ ការពិចារណា លើការទិញ (ឯកតារូបិយបណ្ណ គិតជាខ្នង់ពាន់) | សមតុល្យ សាច់ប្រាក់ដែល ត្រូវបានទិញ (ឯកតារូបិយបណ្ណ គិតជាខ្នង់ពាន់) |
|---|---|---|---|---|
| ស្ថាប័ន គ | XX | X | X | X |
| | XX | X | X | X |
| ស្ថាប័ន ឃ | | X | X | X |
| | | | | |

*ការលក់ស្ថាប័នក្រោមការគ្រប់គ្រង និងស្ថាប័នប្រតិបត្តិចំណុះផ្សេងទៀត*

| ឈ្មោះស្ថាប័ន ដែលត្រូវបានលក់ | ចំនួនភាគហ៊ុន ដែលត្រូវបានលក់ % | ការពិចារណា លើការលក់ (ឯកតារូបិយបណ្ណ គិតជាខ្នង់ពាន់) | ចំនួនសាច់ប្រាក់នៃ ការពិចារណា លើការលក់ (ឯកតារូបិយបណ្ណ គិតជាខ្នង់ពាន់) | សមតុល្យ សាច់ប្រាក់ដែល ត្រូវបានលក់ (ឯកតារូបិយបណ្ណ គិតជាខ្នង់ពាន់) |
|---|---|---|---|---|
| សហគ្រាស "ជ" | XX | X | X | X |

**កំណត់សម្គាល់ "ខ"÷ កិច្ចសម្រុះសម្រួលរួមគ្នាសំខាន់ៗ *(កថាខណ្ឌ ២.១.៦២)***

| ឈ្មោះកិច្ចសម្រុះសម្រួលរួមគ្នា | សកម្មភាពសំខាន់ៗ | ការប្រាក់នៃទិន្នផល | |
|---|---|---|---|
| | | ២០០X % | ២០០X-១ % |
| ក្រុមប្រឹក្សាធនធានទឹកប្រចាំតំបន់ | ការផ្តល់ទឹក | XX | XX |
| ក្រុមប្រឹក្សាអគ្គិសនីប្រចាំតំបន់ | ការផ្តល់សេវាប្រើប្រាស់ | XX | XX |

*(ដកស្រង់ចេញពីកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុរួម របស់រដ្ឋាភិបាល "X" បន្ត)*

**កំណត់សម្គាល់ "ค"÷ ទ្រព្យសកម្ម, ចំណូល, ចំណូល និងចំណាយ** ***(ឧទាហរណ៍ ២.១.២៤ (ค))***

*អចលនទ្រព្យ, រោងចក្រ និងបរិក្ខារ*

រដ្ឋាភិបាលបានចាប់ផ្តើមដំណើរការនៃការកំណត់ និងផ្តល់តម្លៃដល់ថ្នាក់សំខាន់ៗនៃអចលនទ្រព្យ, រោងចក្រ និងបរិក្ខាររបស់ខ្លួន។ ទ្រព្យសកម្មត្រូវបានអះអាងតាមថ្លៃដើមប្រវត្តិសាស្ត្រ ឬការវាយតម្លៃ។ ការវាយតម្លៃត្រូវបានធ្វើឡើងដោយអ្នកវិជ្ជាជីវៈវាយតម្លៃឯករាជ្យ។ មូលដ្ឋាននៃការវាយតម្លៃដែលបានប្រើសម្រាប់ថ្នាក់នៃទ្រព្យសកម្មនីមួយៗ មានដូចខាងក្រោម÷

| | |
|---|---|
| រោងចក្រ និងបរិក្ខារ | ថ្លៃដើម |
| ដី | តម្លៃបច្ចុប្បន្ន |
| អគារ | ថ្លៃដើម ឬតម្លៃទីផ្សារ |

| (ឯកតារូបិយបណ្ណគិតជាខ្នង់ពាន់) | ២00X | ២00X-១ |
|---|---|---|
| រោងចក្រ និងបរិក្ខារ | X | X |
| ដី និងអគារ | | |
| អចលនទ្រព្យនៅក្នុងដែនកំណត់របស់យុត្តាធិការ (ប្រទេស, រដ្ឋ, ទីក្រុង) | X | X |
| អាគារ តាមថ្លៃដើម | X | X |
| អាគារ តាមការវាយតម្លៃ | X | X |
| | X | X |
| | | |

*ចំណូល និងចំណាយ*

រដ្ឋាភិបាលបន្តកសាងទិន្នន័យនៃចំណូលនិងចំណាយនាការិយបរិច្ឆេទរាយការណ៍ នៅពេលរដ្ឋាភិបាលផ្លាស់ប្តូរទៅកាន់មូលដ្ឋានបង្គរនៃការរាយការណ៍ហិរញ្ញវត្ថុ។

រដ្ឋាភិបាលរក្សាទុកកំណត់ត្រាពន្ធលើអចលនទ្រព្យដែលផ្ទុតកំណត់និងដែលត្រូវសង នាកាលបរិច្ឆេទរាយការណ៍ ផ្អែកលើតម្លៃអចលនទ្រព្យដែលបានវាយតម្លៃដោយការិយាល័យចំណូលដោយឈរលើមូលដ្ឋានរំកិលទៅមុខ បីឆ្នាំម្តង ហើយរដ្ឋាភិបាលក៏ប៉ាន់ស្មានពីចំនួនពន្ធលើទំនិញនិងសេវា និង [កំណត់ឧស្សាហកម្ម] សួយសារបង្គរ ដោយផ្អែកលើការលក់ និងរបាយការណ៍និងចំណូលនៃការផលិត។

រដ្ឋាភិបាលកំពុងអភិវឌ្ឍន្ធវ៍គំរូស្ថិតិមួយសម្រាប់វាស់វែងចំណូលពន្ធលើប្រាក់ចំណូលតាមមូលដ្ឋានបង្គរ ដែលផុតចេញពីស្ថិតិពន្ធដារដែលបានចងក្រងចាប់តាំងពីឆ្នាំ២០0X-៣ ក៏ដូចជាព័ត៌មានផ្សេងទៀត រួមបញ្ចូលទាំង ចំណូលជាមធ្យមប្រចាំសប្តាហ៍, ផលិតផលក្នុងស្រុកសរុប, និងសន្ទស្សន៍តម្លៃអ្នកប្រើប្រាស់ និងសន្ទស្សន៍តម្លៃអ្នកផលិត។ រដ្ឋាភិបាលព្យាករណ៍ថា គំរូស្ថិតិនឹងអនុញ្ញាតឱ្យរដ្ឋាភិបាលអាចវាស់វែងប្រកបដោយទំនុកចិត្តនូវចំណូលពន្ធលើប្រាក់ចំណូលតាមមូលដ្ឋានបង្គរ សម្រាប់ការិយបរិច្ឆេទរាយការណ៍ដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២0XX។

*(ដកស្រង់ចេញពីកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុរួម របស់រដ្ឋាភិបាល "X" បន្ត)*

ចំណាយបង្គរ រួមមានចំនួនទឹកប្រាក់ដែលផុតកំណត់និងដែលត្រូវសងសម្រាប់ប្រាក់ឈ្នួល, ប្រាក់ខែ, និងចំណាយលើថ្លៃជួល និងចំណាយផ្សេងទៀតដែលផុតកំណត់និងដែលត្រូវសង គិតត្រឹមកាលបរិច្ឆេទរាយការណ៍។

| (ឯកតារូបិយបណ្ណគិតជាខ្នង់ពាន់) | ២00X | ២00X-១ |
|---|---|---|
| **ចំណូលបង្គរ** | X | X |
| ពន្ធលើអចលនទ្រព្យ | X | X |
| ពន្ធលើទំនិញ និងសេវា | X | X |
| សួយសារ | X | X |
| | | |
| ចំណាយបង្គរ | | |
| ប្រាក់ឈ្នួល និងប្រាក់ខែ | X | X |
| ថ្លៃជួល | X | X |
| ផ្សេងៗ | X | X |
| | | |

*កម្ចី*

កម្ចីរបស់រាជរដ្ឋាភិបាលត្រូវបានកំណត់ក្នុងតារាងដូចខាងក្រោម÷

| (ឯកតារូបិយបណ្ណគិតជាខ្ទង់ពាន់) | ២០0X | ២០0X-១ |
|---|---|---|
| សមតុល្យដើមគ្រា | X | X |
| **ចំណូល** | | |
| ស្ថាប័នពាណិជ្ជកម្មក្នុងស្រុក | X | X |
| ស្ថាប័នពាណិជ្ជកម្មក្រៅប្រទេស | X | X |
| ធនាគារអភិវឌ្ឍន៍ និងភ្នាក់ងារផ្តល់កម្ចីប្រហាក់ប្រហែល | X | X |
| **កម្ចីសរុប** | X | X |
| **ការទូទាត់សង** | | |
| ស្ថាប័នពាណិជ្ជកម្មក្នុងស្រុក | (X) | (X) |
| ស្ថាប័នពាណិជ្ជកម្មក្រៅប្រទេស | (X) | (X) |
| ធនាគារអភិវឌ្ឍន៍ និងភ្នាក់ងារផ្តល់កម្ចីប្រហាក់ប្រហែល | (X) | (X) |
| **ការទូទាត់សងសរុប** | (X) | (X) |
| សមតុល្យចុងគ្រា | X | X |

*(ដកស្រង់ចេញពីកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុរួម របស់រដ្ឋាភិបាល "X" បន្ត)*

**កំណត់សម្គាល់ "ឃ"÷ ការប្រៀបធៀបជាមួយផែនការថវិកា នៅពេលដែលស្ថាប័នមិនបានធ្វើឱ្យផែនការថវិការបស់ខ្លួនមានជាសាធារណៈ:** ***(កថាខណ្ឌ ២.១.២៤ (ខ))***

| (ឯកតារូបិយបណ្ណគិតជាខ្នង់ពាន់) | ចំនួនទឹកប្រាក់ជាក់ស្តែង | ផែនការថវិកា | ភាពខុសគ្នា |
|---|---|---|---|
| ចំណូល | | | |
| *ពន្ធ* | | | |
| ពន្ធលើប្រាក់ចំណូល | X | X | X |
| អាករលើតម្លៃបន្ថែម | X | X | (X) |
| ពន្ធលើអចលនទ្រព្យ | X | X | X |
| ពន្ធផ្សេងៗ | X | X | (X) |
| | X | X | X |
| | | | X |
| *ជំនួយ-កិច្ចព្រមព្រៀងផ្តល់ជំនួយ* | | | |
| ភ្នាក់ងារអន្តរជាតិ | X | X | - |
| ផ្សេងៗ | X | X | - |
| | X | X | - |
| *កម្ចី* | | | |
| ចំណូលពីកម្ចី | X | X | (X) |
| *ចំណូលមូលធន* | | | |
| ចំណូលពីការលក់រោងចក្រ និងបរិក្ខារ | | | |
| | X | X | X |
| *សកម្មភាពជួញដូរ* | | | |
| ចំណូលពីសកម្មភាពជួញដូរ | X | X | X |
| *ចំណូលផ្សេងៗ* | X | X | X |
| ចំណូលសរុប | X | X | X |

| | | | | | | |
|---|---|---|---|---|---|---|
| ចំណាយ | | | | | | |
| *ប្រតិបត្តិការ* | | | | | | |
| ប្រាក់ឈ្នួល ប្រាក់ខែ និងអត្ថប្រយោជន៍ និយោជិត | (X) | | (X) | | (X) | |
| សម្ភារៈ និងគ្រឿងប្រើប្រាស់ | (X) | | (X) | | X | |
| | | (X) | | (X) | | (X) |
| *ការផ្ទេរ* | | | | | | |
| អំណោយ | (X) | | (X) | | - | |
| ការផ្ទេរផ្សេងៗ | (X) | | (X) | | - | |
| | | (X) | | (X) | | - |
| *ចំណាយមូលធន* | | | | | | |
| ការទិញ/ការសាងសង់រោងចក្រ និងបរិក្ខារ | (X) | | (X) | | (X) | |
| ការទិញឧបករណ៍ហិរញ្ញវត្ថុ | (X) | | (X) | | - | |
| | | (X) | | (X) | | (X) |
| **ការទូទាត់សងឥណទាន និងការប្រាក់** | | | | | | |
| ការទូទាត់សងកម្ចី | (X) | | (X) | | - | |
| ការទូទាត់ការប្រាក់ | (X) | | (X) | | - | |
| | | (X) | | (X) | | - |
| *ចំណាយផ្សេងៗ* | | (X) | | (X) | | X |
| | | | | | | X |
| *ចំណាយសរុប* | | (X) | | (X) | | (X) |
| ចំណូលសុទ្ធ /(ចំណាយ) | | X | | X | | X |

(ដកស្រង់ចេញពីកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុរួម របស់រដ្ឋាភិបាល "X" បន្ត)

**កំណត់សម្គាល់ យ២÷ នៅពេលស្ថាប័នរៀបចំផែនការថវិកាពីរឆ្នាំម្តង**

**ផែនការថវិកាពីរឆ្នាំម្តង តាមមូលដ្ឋានសាច់ប្រាក់- សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០X** ***(កថាខណ្ឌ ២.១.៣០)***

| (ឯកតារូបិយបណ្ណគិតជាខ្នង់ពាន់) | ផែនការថវិកាដើមពីរឆ្នាំម្តង | ផែនការថវិកាគោលដៅ សម្រាប់ឆ្នាំទី ១ | ផែនការថវិកាដែលបានកែសម្រួល នៅក្នុងឆ្នាំទី ១ | ចំនួនទឹកប្រាក់ជាក់ស្តែង សម្រាប់ឆ្នាំទី ១ តាមមូលដ្ឋានដែលអាចប្រៀបធៀបគ្នាបាន | សមតុល្យនៅសល់ សម្រាប់ប្រើប្រាស់ នៅក្នុងឆ្នាំទី ២ | ផែនការថវិកាគោលដៅ សម្រាប់ឆ្នាំទី ២ | ផែនការថវិកាដែលបានកែសម្រួល នៅក្នុងឆ្នាំទី ២ | ចំនួនទឹកប្រាក់ជាក់ស្តែង សម្រាប់ឆ្នាំទី ២ តាមមូលដ្ឋានដែលអាចប្រៀបធៀបគ្នាបាន | *ភាពខុសគ្នា: ផែនការថវិកា និងចំនួនទឹកប្រាក់ជាក់ស្តែង សម្រាប់ការិយបរិច្ឆេទផែនការថវិកា |
|---|---|---|---|---|---|---|---|---|---|
| លំហូរចូលនៃសាច់ប្រាក់ | | | | | | | | | |
| ពន្ធ | X | X | X | X | X | X | X | X | X |
| កិច្ចព្រមព្រៀងជំនួយ | X | X | X | X | X | X | X | X | X |
| តាមរយៈ÷ ឥណ្ឌ | X | X | X | X | X | X | X | X | X |
| តាមរយៈ÷ ការលក់រោងចក្រ និងបរិក្ខារ | X | X | X | X | X | X | X | X | X |
| ឧបករណ៍ហិរញ្ញវត្ថុ | X | X | X | X | X | X | X | X | X |
| ចំណូលផ្សេងៗ | X | X | X | X | X | X | X | X | X |
| **លំហូរចូលនៃសាច់ប្រាក់សរុប** | **X** | **X** | **X** | **X** | **X** | **X** | **X** | **X** | **X** |
| លំហូរចេញនៃសាច់ប្រាក់ | | | | | | | | | |
| សុខាភិបាល | (X) | (X) | (X) | (X) | (X) | (X) | (X) | (X) | (X) |
| ការអប់រំ | (X) | (X) | (X) | (X) | (X) | (X) | (X) | (X) | (X) |
| សណ្តាប់ធ្នាប់/សុវត្ថិភាពសាធារណៈ | (X) | (X) | (X) | (X) | (X) | (X) | (X) | (X) | (X) |
| ការការពារផ្នែកសង្គម | (X) | (X) | (X) | (X) | (X) | (X) | (X) | (X) | (X) |
| ការការពារជាតិ | (X) | (X) | (X) | (X) | (X) | (X) | (X) | (X) | (X) |
| លំនៅស្ថាន និងសហគមន៍ | (X) | (X) | (X) | (X) | (X) | (X) | (X) | (X) | (X) |
| ការកំសាន្ត វប្បធម៌ និងសាសនា | (X) | (X) | (X) | (X) | (X) | (X) | (X) | (X) | (X) |
| កិច្ចការផ្នែកសេដ្ឋកិច្ច | (X) | (X) | (X) | (X) | (X) | (X) | (X) | (X) | (X) |
| ការការពារបរិស្ថាន | (X) | (X) | (X) | (X) | (X) | (X) | (X) | (X) | (X) |
| សេវាសាធារណៈទូទៅ | (X) | (X) | (X) | (X) | (X) | (X) | (X) | (X) | (X) |
| **លំហូរចេញនៃសាច់ប្រាក់សរុប** | **(X)** | **(X)** | **(X)** | **(X)** | **(X)** | **(X)** | **(X)** | **(X)** | **(X)** |
| **លំហូរសាច់ប្រាក់សរុប** | **X** | **X** | **X** | **X** | **X** | **X** | **X** | **X** | **X** |

*តារាងជួរឈរនេះមិនត្រូវបានតម្រូវនោះទេ។ ទោះបីជាយ៉ាងណា ការប្រៀបធៀបរវាងចំនួនទឹកប្រាក់ជាក់ស្តែង និងផែនការថវិការើម ឬផែនការថវិកាចុងក្រោយ ដូចបានកំណត់យ៉ាងច្បាស់ថាសមស្រប អាចត្រូវបានតម្រូវ។

*(ដកស្រង់ចេញពីកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុរួម របស់រដ្ឋាភិបាល "X" បន្ត)*

**<u>កំណត់សម្គាល់ "ឆ"÷ ចំណាយដោយភាគីទីបី (កថាខណ្ឌ ២.១.៧៧)</u>**

រដ្ឋាភិបាល "X" ទទួលបានអត្ថប្រយោជន៍ពីចំណាយដែលបានធ្វើឡើងដោយភាគីទីបី ដើម្បីទិញទំនិញ និងសេវាដោយខ្លួនឯងនៅក្នុងអំឡុងការិយបរិច្ឆេទ។ ចំណាយទាំងនេះមិនបានបង្កើតជាចំណូល ឬចំណាយសាច់ប្រាក់ ដោយរដ្ឋាភិបាលនោះទេ។ ចំណាយទាំងនោះរួមមាន ចំណាយសម្រាប់ទំនិញនិងសេវាដែលបានធ្វើឡើងដោយភ្នាក់ងារផ្តល់ជំនួយទ្វេភាគីនិងពហុភាគី និងអង្គការមិនមែនរដ្ឋាភិបាល។ ពួកគេបង្កើតជាផ្នែកមួយនៃការគាំទ្រសម្រាប់កម្មវិធីរបស់រដ្ឋាភិបាលដែលបានផ្តល់តាមមធ្យោបាយនៃជំនួយខាងក្រៅ និងជំនួយផ្សេងទៀត-ព័ត៌មានបន្ថែមអំពីជំនួយខាងក្រៅ និងជំនួយផ្សេងទៀតត្រូវបានផ្តល់នៅក្នុងកំណត់សម្គាល់ "ច" ដូចខាងក្រោម។ រដ្ឋាភិបាលបានបញ្ជាក់ថា ចំណាយខាងក្រោមត្រូវបានធ្វើឡើងដោយភាគីទីបី ដើម្បីទិញទំនិញនិងសេវានៅក្នុងអំឡុងឆ្នាំ ២០0X និង ២០0X-១។

**ចំណាយរបស់ភាគីទីបី**

| (ឯកតារូបិយបណ្ណគិតជាខ្ទង់ពាន់) | ២0X | ២0X-១ |
|---|---|---|
| ប្រាក់ឈ្នួល និងប្រាក់ខែ | X | X |
| សម្ភារៈ និងគ្រឿងប្រើប្រាស់ | X | X |
| ចំណាយមូលធន | X | X |
| ការទូទាត់សងឥណទាន និងការប្រាក់ | X | X |
| **ចំណាយរបស់ភាគីទីបីសរុប** | X | X |

**<u>កំណត់សម្គាល់ "ច"÷ ជំនួយខាងក្រៅ និងជំនួយផ្សេងទៀត (កថាខណ្ឌ ២.១.៩0 និង ២.១.៩១)</u>**

ជំនួយត្រូវបានទទួលក្នុងទម្រង់ជាការផ្តល់សាច់ប្រាក់ និងការដាក់បញ្ចើសាច់ប្រាក់ទៅក្នុងគណនីប្រាក់បញ្ជើមានកាលកំណត់ និងគណនីចរន្ត និងគណនីមូលនិធិបរធនដែលបានគ្រប់គ្រងដោយរដ្ឋាភិបាល។ វាក៏រួមមានចំនួនដែលបានដកដោយរដ្ឋាភិបាលចេញពីគណនីរបស់ម្ចាស់ជំនួយ ស្របទៅនឹងកិច្ចព្រមព្រៀងផ្តល់ជំនួយខាងក្រៅ និងជំនួយផ្សេងទៀត និងការផ្តល់សិទ្ធិដទៃទៀត។ ជំនួយក៏ត្រូវបានទទួលក្នុងទម្រង់ជាចំណាយរបស់ភាគីទីបីផងដែរ។ ជំនួយខាងក្រៅរួមមាន ឥណទាន និងអំណាយដែលទទួលបានពីភ្នាក់ងារម្ចាស់ជំនួយទ្វេភាគីឬពហុភាគី ក្រោមកិច្ចព្រមព្រៀងដែលបញ្ជាក់ពីគោលបំណងដែលជំនួយនឹងត្រូវបានប្រើ។ ជំនួយផ្សេងទៀតត្រូវបានផ្តល់សម្រាប់គោលបំណងជាក់លាក់របស់អង្គការមិនមែនរដ្ឋាភិបាល, សាជីវកម្មឯកជន និងម្ចាស់ជំនួយផ្សេងទៀត។ ចំនួនទឹកប្រាក់, ថ្នាក់នៃអ្នកផ្តល់ជំនួយ និងគោលបំណងដែលជំនួយខាងក្រៅត្រូវបានផ្តល់នៅក្នុងអំឡុងការិយបរិច្ឆេទ ត្រូវបានបង្ហាញដូចខាងក្រោម។

*(ដកស្រង់ចេញពីកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុរួម របស់រដ្ឋាភិបាល "X" បន្ត)*

***ជំនួយខាងក្រៅ និងជំនួយផ្សេងទៀតដែលបានទទួល (កថាខណ្ឌ ២.១.៩០ (ក), (ខ), (គ) និង (ឃ) និងកថាខណ្ឌ ២.១.៩១)***

| (ឯកតារូបិយបណ្ណគិតជាខ្នង់ពាន់) | ២០០X | | ២០០x-១ |
|---|---|---|---|
| ជំនួយខាងក្រៅ | | | |
| ចំណូលសាច់ប្រាក់សរុប | X | | X |
| ចំណាយរបស់ភាគីទីបីសរុប | X | | X |
| ជំនួយខាងក្រៅសរុប | X | | X |
| ភ្នាក់ងារផ្តល់ជំនួយពហុភាគី | | | |
| ចំណូលសាច់ប្រាក់ | X | | X |
| ចំណាយរបស់ភាគីទីបី | X | | X |
| ភ្នាក់ងារផ្តល់ជំនួយពហុភាគីសរុប | X | | X |
| ភ្នាក់ងារផ្តល់ជំនួយទ្វេភាគី | | | |
| ចំណូលសាច់ប្រាក់ | X | | X |
| ចំណាយរបស់ភាគីទីបី | X | | X |
| ភ្នាក់ងារផ្តល់ជំនួយទ្វេភាគីសរុប | X | | X |
| ជំនួយផ្សេងទៀត | | | |
| ចំណូលសាច់ប្រាក់សរុប | X | | X |
| ចំណាយរបស់ភាគីទីបីសរុប | X | | X |
| ជំនួយផ្សេងទៀតសរុប | X | | X |
| អង្គការមិនមែនរដ្ឋាភិបាល | | | |
| ចំណូលសាច់ប្រាក់ | X | | X |
| ចំណាយរបស់ភាគីទីបី | X | | X |
| អង្គការមិនមែនរដ្ឋាភិបាលសរុប | X | | X |
| សាជីវកម្មឯកជន និងម្ចាស់ជំនួយផ្សេងទៀត | | | |
| ចំណូលសាច់ប្រាក់ | X | | X |
| សាជីវកម្មឯកជន និងម្ចាស់ជំនួយផ្សេងទៀតសរុប | X | | X |

*(ដកស្រង់ចេញពីកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុរួម របស់រដ្ឋាភិបាល "X" បន្ត)*

| (ឯកតារូបិយបណ្ណគិតជាខ្ទង់ពាន់) | ២០០X | | ២០០X+១ |
|---|---|---|---|
| **មូលនិធិឥណទាន** | X | | X |
| ជំនួយខាងក្រៅ | X | | X |
| មូលនិធិឥណទានសរុប | X | | X |
| **អំណោយ និងការបរិច្ចាគ** | | | |
| ជំនួយខាងក្រៅ | X | | X |
| ជំនួយផ្សេងទៀត | X | | X |
| **អំណោយ និងការបរិច្ចាគសរុប** | X | | X |
| | | | |

**គោលបំណងដែលជំនួយខាងក្រៅនិងជំនួយផ្សេងទៀតត្រូវបានផ្តល់ និងប្រើប្រាស់ *(កថាខណ្ឌ ២.១.៥០ (ខ) និងកថាខណ្ឌ ២.១.៥១)***

*ជំនួយខាងក្រៅ*

នៅក្នុងអំឡុងការិយបរិច្ឆេទរាយការណ៍ ជំនួយខាងក្រៅត្រូវបានទទួលពីភ្នាក់ងារផ្តល់ជំនួយខាងក្រៅទ្វេភាគី និងពហុ-ភាគី ក្រោមកិច្ចព្រមព្រៀងដែលបញ្ជាក់ថា ជំនួយអាចនឹងត្រូវបានប្រើប្រាស់សម្រាប់គោលបំណងដូចខាងក្រោម÷

| | ជំនួយអភិវឌ្ឍន៍ | | ជំនួយបន្ទាន់ | | ជំនួយផ្សេងទៀត | | សរុប | |
|---|---|---|---|---|---|---|---|---|
| | ២០០X | ២០០X-១ | ២០០X | ២០០X-១ | ២០០X | ២០០X-១ | ២០០X | ២០០X-១ |
| **មូលនិធិឥណទាន** | X | X | - | - | X | - | X | X |
| **មូលនិធិអំណោយ** | X | - | X | X | - | - | X | X |
| **សរុប** | X | X | X | X | X | - | X | X |
| **ចំនួនដែលបានប្រើ** | X | X | X | X | X | - | X | X |

*ជំនួយផ្សេងទៀត*

នៅក្នុងអំឡុងការិយបរិច្ឆេទរាយការណ៍ ជំនួយផ្សេងទៀតត្រូវបានទទួលជាអំណោយ និងជាការបរិច្ចាគ ពីអង្គការមិនមែនរដ្ឋាភិបាល, សាជីវកម្មឯកជន និងម្ចាស់ជំនួយផ្សេងទៀត សម្រាប់គោលបំណងដូចខាងក្រោម÷

| | ជំនួយអភិវឌ្ឍន៍ | | ជំនួយបន្ទាន់ | | សរុប | |
|---|---|---|---|---|---|---|
| | ២00X | ២00X-១ | ២00X | ២00X-១ | ២00X | ២00X-១ |
| | | | | | | |
| អំណោយ និងការបរិច្ចាគ | X | X | X | X | X | X |
| | | | | | | |
| ចំនួនដែលបានប្រើ | X | X | X | X | X | X |

*(ដកស្រង់ចេញពីកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុរួម របស់រដ្ឋាភិបាល "X" បន្ត)*

***ជំនួយខាងក្រៅ និងជំនួយផ្សេងទៀតដែលមិនទាន់ប្រើប្រាស់ (កថាខណ្ឌ ២.១.៩០ (ជ) និងកថាខណ្ឌ ២.១.៩១)***

ឥណទាននិងអំណោយជាជំនួយខាងក្រៅដែលមិនទាន់បានប្រើប្រាស់ រួមមាន ចំនួនទឹកប្រាក់ដែលត្រូវបានបញ្ជាក់នៅក្នុងកិច្ចព្រមព្រៀងដែលត្រូវអនុវត្តតាម ជាមួយភ្នាក់ងារផ្តល់ជំនួយខាងក្រៅ ប៉ុន្តែមិនត្រូវបានប្រើប្រាស់នាកាលបរិច្ឆេទរាយការណ៍ និងស្ថិតក្រោមលក្ខខណ្ឌដែលត្រូវបានបំពេញនាពេលអតីតកាល ហើយវាត្រូវបានព្យាករណ៍ថានឹងត្រូវបានបំពេញនាពេលអនាគត។ មិនមានចំនួនទឹកប្រាក់នៃជំនួយដែលមិនទាន់បានប្រើប្រាស់ពីអង្គការមិនមែនរដ្ឋាភិបាល ឬអ្នកផ្តល់ជំនួយផ្សេងទៀតនៅក្នុងឆ្នាំ ២00X ឬ ២00X-១ នោះទេ។

| | ជំនួយអភិវឌ្ឍន៍ | | ជំនួយបន្ទាន់ | | ជំនួយផ្សេងទៀត | | សរុប | |
|---|---|---|---|---|---|---|---|---|
| | ២00X | ២00X-១ | ២00X | ២00X-១ | ២00X | ២00X-១ | ២00X | ២00X-១ |
| សមតុល្យចុងគ្រា - ឥណទាន | X | X | - | - | X | X | X | X |
| សមតុល្យចុងគ្រា - អំណោយ | X | X | - | - | X | X | X | X |

**ទំនិញ និងសេវាដែលបានទទួល *(កថាខណ្ឌ ២.១.១០០)***

នៅក្នុងឆ្នាំ ២០0X ការរញ្ជួយដីដ៏ធ្ងន់ធ្ងរមួយបានកើតឡើងនៅក្នុងតំបន់ "ZZZ" ដែលបង្កជាការខូចខាតយ៉ាងដំណាំ ចំពោះទ្រព្យសម្បត្តិរបស់រដ្ឋាភិបាល និងទ្រព្យសម្បត្តិឯកជន និងមានការបាត់បង់អាយុជីវិតមនុស្សយ៉ាងច្រើន។ ភ្នាក់ងារពហុភាគី, ភ្នាក់ងារទ្វេភាគី, អង្គការមិនមែនរដ្ឋាភិបាល, សាជីវកម្មឯកជន, និងសមាគមនៃប្រជាជាតិមួយចំនួនបានបរិច្ចាគទាំងកម្លាំងមនុស្សនិងបរិក្ខារ ដើម្បីជួយជម្លៀសនិងសង្គ្រោះប្រជាពលរដ្ឋដែលបានជាប់គាំងនៅក្នុងកម្ទេចកម្ទីបាក់បែក។ បន្ថែមពីនេះ ក្រុមវេជ្ជសាស្ត្រជំនាញដែលត្រូវបានបណ្តុះបណ្តាលក្នុងការព្យាបាលរបួសធ្ងន់ធ្ងរជាមួយនឹងបរិក្ខារវេជ្ជសាស្ត្រ ត្រូវបានបញ្ជូនទៅក្នុងតំបន់នោះ។ ជំរុំបណ្តោះអាសន្ន អាហារ និងសម្លៀកបំពាក់ ក៏ត្រូវបានផ្គត់ផ្គង់ផងដែរ។ តម្លៃទំនិញនិងសេវាដែលបានទទួលត្រូវបានប៉ាន់ស្មានទៅតាមឯកតារូបិយបណ្ណក្នុងស្រុក។ តម្លៃជំនួយបន្ទាន់ដែលបានផ្តល់ ត្រូវបានប៉ាន់ស្មានដោយផ្អែកលើការប៉ាន់ស្មានចំណាយដែលបានផ្តល់ដោយភ្នាក់ងារផ្តល់ជំនួយអន្តរជាតិ, អង្គការមិនមែនរដ្ឋាភិបាល និងសាជីវកម្មដែលជាអ្នកចូលរួមវិភាគទានយ៉ាងសំខាន់ ពីព្រោះតម្លៃទំនិញឬសេវាសមមូលក្នុងស្រុកមិនមានឡើយ។

អង្ករចំនួន ៥ ម៉ឺនតោន ត្រូវបានទទួលជាជំនួយអាហារនៅក្នុងអំឡុងឆ្នាំ។ វាត្រូវបានផ្តល់តម្លៃតាមឯកតារូបិយបណ្ណក្នុងស្រុក XX ដែលតំណាងឱ្យតម្លៃបោះដុំរបស់អង្ករប្រហាក់ប្រហែល នៅក្នុងទីផ្សារបោះដុំក្នុងស្រុក។

ទំនិញនិងសេវាដែលបានទទួលនៅក្នុងអំឡុងឆ្នាំមិនត្រូវបានកត់ត្រានៅក្នុងរបាយការណ៍ចំណូលនិងចំណាយសាច់ប្រាក់ឡើយ ដែលឆ្លុះបញ្ចាំងតែសាច់ប្រាក់ដែលបានទទួល (ដោយផ្ទាល់ ឬប្រយោល) ឬត្រូវបានទូទាត់ដោយរដ្ឋាភិបាល។ ទំនិញនិងសេវាមិនមែនប្រាក់ ត្រូវបានទទួលជាផ្នែកមួយនៃជំនួយបន្ទាន់ និងត្រូវបានឆ្លុះបញ្ចាំងក្នុងកំណត់សម្គាល់នេះ។

**ឧបសម្ព័ន្ធ ៣**

**ការដាក់បញ្ជាញ្ជរបាយការណ៍ចំណូលនិងចំណាយសាច់ប្រាក់ ក្នុងទម្រង់ដែលបានតម្រូវដោយស្តង់ដា** IPSAS 2, ***របាយការណ៍លំហូរសាច់ប្រាក់***

*កថាខណ្ឌ ២.២.១ នៃផ្នែកទី ២ នៃស្តង់ដានេះ លើកទឹកចិត្តឱ្យស្ថាប័នមួយដែលកំពុងបំពេញនូវដំណើរផ្លាស់ប្តូរទៅកាន់មូលដ្ឋានបង្គរនៃការរាយការណ៍ហិរញ្ញវត្ថុ និងការអនុវត្តស្តង់ដាគណនេយ្យសាធារណៈ មូលដ្ឋានបង្គរ ដើម្បីដាក់បង្ហាញរបាយការណ៍ចំណូលនិងចំណាយសាច់ប្រាក់ក្នុងទម្រង់ដូចគ្នាទៅនឹងទម្រង់ដែលបានតម្រូវដោយ IPSAS ២, របាយការណ៍លំហូរសាច់ប្រាក់។ ស្តង់ដា IPSAS ២ ត្រូវបានអនុវត្តដោយស្ថាប័នមួយដែលរាយការណ៍តាមមូលដ្ឋានបង្គរនៃការរាយការណ៍ហិរញ្ញវត្ថុ ដោយអនុលោមតាមស្តង់ដាគណនេយ្យអន្តរជាតិសម្រាប់វិស័យសាធារណៈ។*

*ឧបសម្ព័ន្ធនេះផ្តល់នូវការសង្ខេបមួយអំពីផ្នែកសំខាន់ៗនៃស្តង់ដា IPSAS ២ និងសេចក្តីណែនាំលើការអនុវត្តរបស់ពួកវាសម្រាប់ការរាយការណ៍ហិរញ្ញវត្ថុតាមមូលដ្ឋានគណនេយ្យសាច់ប្រាក់ ដូចបានតម្រូវដោយស្តង់ដានេះ។ ស្ថាប័នដែលមានបំណងដាក់បង្ហាញរបាយការណ៍ចំណូលនិងចំណាយសាច់ប្រាក់ ដោយអនុលោមតាមលក្ខខណ្ឌចាំបាច់នៃស្តង់ដា IPSAS ២ ឱ្យបានសមស្របតាមតែអាចធ្វើទៅបាន នឹងចាំបាច់ត្រូវសំដៅដល់ស្តង់ដា IPSAS នោះ។*

**ការដាក់បញ្ជាញ្ជក្នុងទម្រង់ដូចបានតម្រូវដោយស្តង់ដា IPSAS ២, *របាយការណ៍លំហូរសាច់ប្រាក់***

១. ស្តង់ដា IPSAS ២, *របាយការណ៍លំហូរសាច់ប្រាក់* តម្រូវឱ្យស្ថាប័នមួយដែលរៀបចំ និងដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុតាមមូលដ្ឋានបង្គរនៃការរាយការណ៍ហិរញ្ញវត្ថុ ***និងការអនុវត្តស្តង់ដាគណនេយ្យសាធារណៈ មូលដ្ឋានបង្គរ*** រៀបចំរបាយការណ៍លំហូរសាច់ប្រាក់ដែលរាយការណ៍អំពីលំហូរសាច់ប្រាក់នៅក្នុងអំឡុងការិយបរិច្ឆេទដូចបានធ្វើចំណាត់ថ្នាក់ដោយសកម្មភាពប្រតិបត្តិការ, សកម្មភាពវិនិយោគ និងសកម្មភាពហិរញ្ញប្បទាន ដូចបានផ្តល់និយមន័យខាងក្រោម។

**និយមន័យ**

២. *<u>សកម្មភាពហិរញ្ញប្បទាន</u> គឺជាសកម្មភាពដែលឱ្យលទ្ធផលជាការផ្លាស់ប្តូរទំហំនិងសមាសធាតុនៃមូលធន និងកម្ចីដែលត្រូវបានចូលរួមវិភាគទានរបស់ស្ថាប័ន។*

*<u>សកម្មភាពវិនិយោគ</u> គឺជាការទទួលបាន និងការលក់ទ្រព្យសកម្មរយៈពេលវែង និងការវិនិយោគផ្សេងទៀតដែលមិនបានរួមបញ្ចូលនៅក្នុងសាច់ប្រាក់សមមូល។*

*<u>សកម្មភាពប្រតិបត្តិការ</u> គឺជាសកម្មភាពរបស់ស្ថាប័ន ដែលមិនមែនជាសកម្មភាពវិនិយោគ ឬសកម្មភាពហិរញ្ញប្បទាន។*

**សមាសធាតុនៃរបាយការណ៍ហិរញ្ញវត្ថុ**

៣. ក្នុងការដាក់បង្ហាញរបាយការណ៍ចំណូលនិងចំណាយសាច់ប្រាក់នៅក្នុងទម្រង់នេះ វាអាចចាំបាច់ដើម្បីធ្វើចំណាត់ថ្នាក់លំហូរសាច់ប្រាក់ដែលកើតឡើងពីប្រតិបត្តិការតែមួយនៅក្នុងមធ្យោបាយផ្សេងគ្នា។ (ពាក្យថា របាយការណ៍លំហូរសាច់ប្រាក់ ត្រូវបានប្រើជាផ្នែកដែលនៅសល់នៃឧបសម្ព័ន្ធនេះសម្រាប់ របាយការណ៍ចំណូលនិងចំណាយសាច់ប្រាក់ ដែលត្រូវបានដាក់បង្ហាញក្នុងទម្រង់ដូចគ្នានឹងទម្រង់ដែលបានតម្រូវដោយ IPSAS ២)។ ឧទាហរណ៍ នៅពេលការទូទាត់សងឥណទានជាសាច់ប្រាក់ រួមបញ្ចូលទាំងការប្រាក់និងមូលធន ធាតុការប្រាក់អាចត្រូវបានធ្វើចំណាត់ថ្នាក់ជាសកម្មភាពប្រតិបត្តិការមួយ ហើយធាតុមូលធនអាចត្រូវបានធ្វើចំណាត់ថ្នាក់ជាសកម្មភាពហិរញ្ញប្បទានមួយ។

៤. របាយការណ៍លំហូរសាច់ប្រាក់ នឹងរួមបញ្ចូលនូវបន្ទាត់គណនីដែលដាក់បង្ហាញនូវចំនួនដូចខាងក្រោម÷

(ក) ចំណូលសរុបពីសកម្មភាពប្រតិបត្តិការ

(ខ) ចំណាយសរុបលើសកម្មភាពប្រតិបត្តិការ

(គ) លំហូរសាច់ប្រាក់សុទ្ធពីសកម្មភាពប្រតិបត្តិការ

(ឃ) លំហូរសាច់ប្រាក់សុទ្ធពីសកម្មភាពវិនិយោគ

(ង) លំហូរសាច់ប្រាក់សុទ្ធពីសកម្មភាពហិរញ្ញប្បទាន

(ច) សមតុល្យសាច់ប្រាក់ដើមគ្រានិងចុងគ្រា និង

(ឆ) ការកើនឡើង ឬការធ្លាក់ចុះសុទ្ធនៃសាច់ប្រាក់។

បន្ទាត់គណនីបន្ថែម, ចំណងជើង និងសរុបរង ក៏នឹងត្រូវបានដាក់បង្ហាញនៅលើផ្នែមុខនៃរបាយការណ៍ផងដែរ នៅពេលការដាក់បង្ហាញបែបនេះមានភាពចាំបាច់ដើម្បីដាក់បង្ហាញឱ្យបានត្រឹមត្រូវនូវលំហូរសាច់ប្រាក់របស់ស្ថាប័ន។

៥. ស្ថាប័នមួយក៏នឹងដាក់បង្ហាញនៅលើផ្នែមុខនៃរបាយការណ៍លំហូរសាច់ប្រាក់ ឬក្នុងកំណត់សម្គាល់នូវ÷

(ក) ថ្នាក់សំខាន់ៗនៃចំណូលសាច់ប្រាក់ដុល និងចំណាយសាច់ប្រាក់ដុលដែលកើតឡើងពីសកម្មភាពប្រតិបត្តិការ, សកម្មភាពវិនិយោគ និងសកម្មភាពហិរញ្ញប្បទាន លើកលែងតែនៅក្នុងវិសាលភាពដែលកថាខណ្ឌ ១.៣.១៣ នៃផ្នែកទី ១ នៃស្តង់ដានេះ អនុញ្ញាតឱ្យមានការរាយការណ៍ទៅតាមមូលដ្ឋានសុទ្ធប៉ុណ្ណោះ

(ខ) ចំណាត់ថ្នាក់រងនៃចំណូលសាច់ប្រាក់សរុបដែលបានពីប្រតិបត្តិការ នៅក្នុងមធ្យោបាយសមស្របមួយចំពោះប្រតិបត្តិការរបស់ស្ថាប័ន និង

(គ) ការវិភាគអំពីចំណាយលើសកម្មភាពប្រតិបត្តិការដោយប្រើចំណាត់ថ្នាក់មួយផ្អែកលើចរិកលក្ខណៈនៃចំណាយ ឬមុខងាររបស់ពួកគេនៅក្នុងស្ថាប័ន តាមភាពសមស្រប។

ការលាតត្រដាងដាច់ដោយឡែកអំពីចំណាយដែលបានធ្វើឡើងសម្រាប់ការទទួលបានមូលធន និងសម្រាប់ការប្រាក់និងភាគលាភ ក៏មានសង្គតិភាពជាមួយនឹងលក្ខខណ្ឌចាំបាច់នៃ IPSAS ២ ផងដែរ។

៦. ការលាតត្រដាងព័ត៌មានអំពីបញ្ហាទាំងនេះថាតើសាច់ប្រាក់ត្រូវបានបង្កើតឡើងពីពន្ធ, ការពិន័យ, កម្រៃ (សកម្មភាពប្រតិបត្តិការ), ការលក់ទ្រព្យសកម្មមូលធន (សកម្មភាពវិនិយោគ) និង/ឬ កម្ចី (សកម្មភាពហិរញ្ញប្បទាន) និងថាតើសាច់ប្រាក់ត្រូវបានពង្រីកបន្ថែមដើម្បីទូទាត់ជាមួយចំណាយប្រតិបត្តិការសម្រាប់ការទិញទ្រព្យសកម្មមូលធន(សកម្មភាពវិនិយោគ)ឬសម្រាប់ការបញ្ចប់បំណុល(សកម្មភាពហិរញ្ញប្បទាន) នឹងធ្វើឱ្យប្រសើរឡើងនូវតម្លាភាព និងគណនេយ្យភាពនៃរបាយការណ៍ហិរញ្ញវត្ថុ។ ការលាតត្រដាងទាំងនេះក៏នឹងជួយសម្រួលដល់ការវិភាគឱ្យបានគ្រប់ជ្រុងជ្រោយ និងការវាយតម្លៃលើធនធានសាច់ប្រាក់បច្ចុប្បន្នរបស់ស្ថាប័ននិងប្រភពដែលអាចទៅរួច និងនិរន្តរភាពនៃលំហូរចូលសាច់ប្រាក់នាពេលអនាគតផងដែរ។ ដូច្នេះ ស្តង់ដានេះលើកទឹកចិត្តឱ្យស្ថាប័នទាំងអស់ធ្វើការលាតត្រដាងព័ត៌មានទាំងនេះនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ និង/ឬ កំណត់សម្គាល់ពាក់ព័ន្ធ។

**សកម្មភាពប្រតិបត្តិការ**

៧. ចំនួនលំហូរសាច់ប្រាក់សុទ្ធដែលកើតឡើងពីសកម្មភាពប្រតិបត្តិការ គឺជាសូចនករគន្លឹះមួយនៃវិសាលភាពដែលប្រតិបត្តិការរបស់ស្ថាប័ន ត្រូវបានផ្តល់មូលនិធិ÷

(ក) តាមមធ្យោបាយពន្ធ (ដោយផ្ទាល់ ឬប្រយោល) និង

(ខ) ពីតម្យជនទទួលទំនិញនិងសេវា ដែលបានផ្តល់ដោយស្ថាប័ន។

ការលាតត្រដាងអំពីចំនួនលំហូរសាច់ប្រាក់សុទ្ធដែលកើតឡើងពីសកម្មភាពប្រតិបត្តិការ ក៏ជួយដល់ការកំណត់ពីវិសាលភាពដែលប្រតិបត្តិការរបស់ស្ថាប័នបង្កើតសាច់ប្រាក់ដែលអាចត្រូវបានប្រើ ដើម្បីធ្វើការទូទាត់សងកាតព្វកិច្ច, ទូទាត់ភាគលាភ/ការចែកចាយទៅឱ្យម្ចាស់របស់ខ្លួន និងបង្កើតការវិនិយោគថ្មីៗបន្ថែម ដោយពុំត្រូវការប្រភពនៃការផ្តល់ហិរញ្ញប្បទានពីខាងក្រៅ។ លំហូរសាច់ប្រាក់ប្រតិបត្តិការរួមរបស់រដ្ឋាភិបាលទាំងមូល ផ្តល់នូវការបង្ហាញពីវិសាលភាពដែលរដ្ឋាភិបាលមួយបានផ្តល់ហិរញ្ញប្បទានដល់សកម្មភាពបច្ចុប្បន្នរបស់ខ្លួនតាមរយៈពន្ធនិងការគិតកម្រៃ។ ព័ត៌មានអំពីសមាសភាគជាក់លាក់នៃលំហូរសាច់ប្រាក់ប្រតិបត្តិការប្រវត្តិសាស្ត្រគឺមានសារៈសំខាន់ ជាមួយនឹងព័ត៌មានដទៃផ្សេងទៀតក្នុងការព្យាករណ៍ពីលំហូរសាច់ប្រាក់ប្រតិបត្តិការនាពេលអនាគត។

៨. លំហូរសាច់ប្រាក់ដែលកើតឡើងពីសកម្មភាពប្រតិបត្តិការ ត្រូវបានដកចេញជាពិសេសពីសកម្មភាពបង្កើតប្រាក់សំខាន់ៗរបស់ស្ថាប័ន។ ឧទាហរណ៍អំពីលំហូរសាច់ប្រាក់ដែលកើតឡើងពីសកម្មភាពប្រតិបត្តិការ គឺ÷

(ក) ចំណូលសាច់ប្រាក់ពីពន្ធ, ពន្ធនាំចូល និងការពិន័យ

(ខ) ចំណូលសាច់ប្រាក់ពីការគិតកម្រៃ សម្រាប់ទំនិញនិងសេវាដែលបានផ្តល់ដោយស្ថាប័ន

(គ) ចំណូលសាច់ប្រាក់ពីអំណោយ ឬការផ្តេរ និងវិភាជន៍ដទៃទៀត ឬការផ្តល់សិទ្ធិប្រើប្រាស់ផែនការថវិកាដែលធ្វើឡើងដោយរដ្ឋាភិបាលកណ្តាល ឬស្ថាប័នសាធារណៈផ្សេងទៀត រួមបញ្ចូលទាំងចំណូលសាច់ប្រាក់ទាំងឡាយណាដែលបានធ្វើឡើងសម្រាប់ការទិញទ្រព្យសកម្មមួលធន។

(ឃ) ចំណូលសាច់ប្រាក់ពីសួយសារ, កម្រៃ និងកម្រៃជើងសារ

(ង) ចំណាយសាច់ប្រាក់ទៅកាន់ស្ថាប័នសាធារណៈផ្សេងទៀតដើម្បីផ្តល់ហិរញ្ញប្បទានដល់ប្រតិបត្តិការរបស់ពួកគេ (ដោយមិនរួមបញ្ចូលនូវឥណទាន ឬការបញ្ចូលមូលធនបន្ថែម)

(ច) ចំណាយសាច់ប្រាក់ទៅកាន់អ្នកផ្គត់ផ្គង់ទំនិញ និងសេវា

(ឆ) ចំណាយសាច់ប្រាក់ទៅកាន់ និងជំនួយឱ្យនិយោជិក

(ជ) ចំណូលសាច់ប្រាក់និងចំណាយសាច់ប្រាក់របស់ស្ថាប័នធានារ៉ាប់រងសាធារណៈ សម្រាប់បុព្វលាភរ៉ាប់រង និងប្រាក់ត្រូវទទួល, ធនលាភ និងអត្ថប្រយោជន៍គោលនយោបាយផ្សេងទៀត

(ឈ) ចំណាយសាច់ប្រាក់នៃពន្ធលើអចលនទ្រព្យក្នុងស្រុក ឬពន្ធលើប្រាក់ចំណូល (តាមភាពសមស្រប) ពាក់ព័ន្ធនឹងសកម្មភាពប្រតិបត្តិការ

(ញ) ចំណូលសាច់ប្រាក់និងចំណាយសាច់ប្រាក់ដែលបានពីកិច្ចសន្យា ដែលត្រូវបានរក្សាទុកសម្រាប់គោលបំណងនៃការដោះស្រាយ ឬការជួញដូរ

(ត) ចំណូលសាច់ប្រាក់ឬចំណាយសាច់ប្រាក់ពីការបញ្ឈប់ប្រតិបត្តិការ និង

(ថ) ចំណូលសាច់ប្រាក់ឬចំណាយសាច់ប្រាក់ ពាក់ព័ន្ធនឹងការដោះស្រាយវិវាទ។

៩. ស្ថាប័នមួយអាចរក្សាទុកមូលបត្រ និងឥណទាន សម្រាប់គោលបំណងនៃការដោះស្រាយនិងការជួញដូរ នៅក្នុងករណីដែលពួកគេមានភាពស្រដៀងគ្នាទៅនឹងសន្និធិដែលបានទិញ ជាពិសេសសម្រាប់ការលក់ឡើងវិញ។ ដូច្នេះលំហូរសាច់ប្រាក់ដែលកើតឡើងពីការទិញនិងការលក់មូលបត្រសម្រាប់ការដោះស្រាយនិងការជួញដូរ ត្រូវបានធ្វើចំណាត់ថ្នាក់ជាសកម្មភាពប្រតិបត្តិការ។ ស្រដៀងគ្នានេះដែរ បុរេប្រទាន និងឥណទានក្នុងទម្រង់ជាសាច់ប្រាក់ដែលត្រូវបានធ្វើឡើងដោយស្ថាប័នហិរញ្ញវត្ថុសាធារណៈ គឺតែងតែត្រូវបានធ្វើចំណាត់ថ្នាក់ជាសកម្មភាពប្រតិបត្តិការ ពីព្រោះពួកគេពាក់ព័ន្ធនឹងសកម្មភាពបង្កើតសាច់ប្រាក់សំខាន់របស់ស្ថាប័ននោះ។

១០. នៅក្នុងយុត្តាធិការមួយចំនួន រដ្ឋាភិបាលឬស្ថាប័នសាធារណៈផ្សេងទៀតនឹងធ្វើវិភាជន៍ ឬផ្តល់សិទ្ធិក្នុងការប្រើប្រាស់មូលនិធិទៅឱ្យស្ថាប័ន ដើម្បីផ្តល់ហិរញ្ញប្បទានដល់ប្រតិបត្តិការរបស់ស្ថាប័ន ហើយពុំមានការញែកឱ្យដាច់ច្បាស់លាស់ណាមួយត្រូវបានធ្វើឡើងសម្រាប់ការរៀបចំមូលនិធិទាំងនោះ រវាងសកម្មភាពបច្ចុប្បន្ន, ការងារមូលធន និងមូលធនដែលបានចូលរួមវិភាគទាននោះទេ។ នៅពេលដែលស្ថាប័នមួយមិនអាចកំណត់ឱ្យបានដាច់ដោយឡែកនៃវិភាជន៍ឬការផ្តល់សិទ្ធិប្រើប្រាស់ផែនការថវិកាថាជាសកម្មភាព

បច្ចុប្បន្ន, ការងារមូលធន (សកម្មភាពប្រតិបត្តិការ) និងមូលធនដែលបានចូលរួមវិភាគទាន (សកម្មភាពវិនិយោគ) នោះស្តង់ដា IPSAS ២ បានពន្យល់ថា ស្ថាប៉ន់គួរធ្វើចំណាត់ថ្នាក់វិភាជន៍ ឬការផ្តល់សិទ្ធិប្រើប្រាស់ផែនការថវិកា ទៅជាលំហូរសាច់ប្រាក់ដែលកើតឡើងពីប្រតិបត្តិការ ហើយលាតត្រដាងពួកគេនៅក្នុងកំណត់សម្គាល់លើរបាយការណ៍លំហូរសាច់ប្រាក់។

**សកម្មភាពវិនិយោគ**

១១. ការលាតត្រដាងដាច់ដោយឡែកអំពីលំហូរសាច់ប្រាក់ដែលកើតឡើងពីសកម្មភាពវិនិយោគ បានកំណត់ពីវិសាលភាពដែលលំហូរចេញនៃសាច់ប្រាក់ត្រូវបានធ្វើឡើងសម្រាប់ធនធានដែលត្រូវបានគ្រោងទុក ដើម្បីចូលរួមវិភាគទានដល់ការផ្តល់សេវានាពេលអនាគតរបស់ស្ថាប៉ន់។ ឧទាហរណ៍អំពីលំហូរសាច់ប្រាក់ដែលកើតឡើងពីសកម្មភាពវិនិយោគ គឺ÷

(ក) ចំណាយសាច់ប្រាក់ដើម្បីទិញអចលនទ្រព្យ, រោងចក្រ និងបរិក្ខារ, ទ្រព្យសកម្មអរូបិយ និងទ្រព្យសកម្មរយៈពេលវែងផ្សេងទៀត។ ចំណាយទាំងនេះរួមបញ្ចូលនូវចំណាយដែលទាក់ទងនឹងទុនចំណាយលើការអភិវឌ្ឍ និងអចលនទ្រព្យ រោងចក្រ និងបរិក្ខារដែលបានសាងសង់ដោយខ្លួនឯង

(ខ) ចំណូលសាច់ប្រាក់ពីការលក់អចលនទ្រព្យ រោងចក្រ និងបរិក្ខារ, ទ្រព្យសកម្មអរូបិយ និងទ្រព្យសកម្មរយៈពេលវែងផ្សេងទៀត

(គ) ចំណាយសាច់ប្រាក់ដើម្បីទិញឧបករណ៍មូលធន ឬឧបករណ៍បំណុលរបស់ស្ថាប៉ន់ផ្សេងទៀត និងការប្រាក់នៅក្នុងក្រុមហ៊ុនរួមទុន (ជាជាង ចំណាយសម្រាប់ឧបករណ៍ទាំងនោះដែលត្រូវបានចាត់ទុកជាសាច់ប្រាក់សមមូល ឬចំណាយដែលត្រូវបានរក្សាទុកសម្រាប់គោលបំណងនៃការដោះស្រាយ ឬការជួញដូរ)

(ឃ) ចំណូលសាច់ប្រាក់ពីការលក់ឧបករណ៍មូលធន ឬឧបករណ៍បំណុលរបស់ស្ថាប៉ន់ផ្សេងទៀត និងការប្រាក់នៅក្នុងក្រុមហ៊ុនរួមទុន (ជាជាង ចំណូលសម្រាប់ឧបករណ៍ទាំងនោះដែលត្រូវបានចាត់ទុកជាសាច់ប្រាក់សមមូល និងចំណូលដែលត្រូវបានរក្សាទុកសម្រាប់គោលបំណងនៃការដោះស្រាយ ឬការជួញដូរ)

(ង) បុរេប្រទាននិងឥណទានក្នុងទម្រង់ជាសាច់ប្រាក់ ដែលត្រូវបានធ្វើឡើងទៅកាន់ភាគីផ្សេងទៀត (ជាជាង បុរេប្រទាននិងឥណទានដែលត្រូវបានធ្វើឡើងដោយស្ថាប៉ន់ហិរញ្ញវត្ថុសាធារណៈមួយ)

(ច) ចំណូលសាច់ប្រាក់ពីការទូទាត់សងបុរេប្រទាននិងឥណទាន ដែលត្រូវបានធ្វើឡើងទៅកាន់ភាគីផ្សេងទៀត (ជាជាង បុរេប្រទាននិងឥណទានរបស់ស្ថាប៉ន់ហិរញ្ញវត្ថុសាធារណៈមួយ)

(ឆ) ចំណាយសាច់ប្រាក់សម្រាប់កិច្ចសន្យានាពេលអនាគត, កិច្ចសន្យាកំណត់ទុកមុន, កិច្ចសន្យាជម្រើស និងកិច្ចសន្យាដោះដូរ លើកលែងតែនៅពេលដែលកិច្ចសន្យាត្រូវបានរក្សាទុកសម្រាប់

គោលបំណងនៃការដោះស្រាយ ឬការជួញដូរ ឬចំណាយត្រូវបានធ្វើចំណាត់ថ្នាក់ជាសកម្មភាពហិរញ្ញប្បទាន និង

(ជ) ចំណូលសាច់ប្រាក់ពីកិច្ចសន្យានាពេលអនាគត, កិច្ចសន្យាកំណត់ទុកមុន, កិច្ចសន្យាជម្រើស និងកិច្ចសន្យាដោះដូរ លើកលែងតែនៅពេលដែលកិច្ចសន្យាត្រូវបានរក្សាទុកសម្រាប់គោលបំណងនៃការដោះស្រាយ ឬការជួញដូរ ឬចំណូលត្រូវបានធ្វើចំណាត់ថ្នាក់ជាសកម្មភាពហិរញ្ញប្បទាន។

នៅពេលកិច្ចសន្យាមួយត្រូវបានជ្រើសតាំងជាការទប់ស្កាត់ហានិភ័យនៃស្ថានភាពដែលអាចកំណត់បានលំហូរសាច់ប្រាក់នៃកិច្ចសន្យាត្រូវបានធ្វើចំណាត់ថ្នាក់ក្នុងមធ្យោបាយដូចគ្នាទៅនឹងលំហូរសាច់ប្រាក់នៃស្ថានភាពដែលត្រូវបានទប់ស្កាត់ហានិភ័យ។

**សកម្មភាពហិរញ្ញប្បទាន**

១២. ការលាតត្រដាងដាច់ដោយឡែកអំពីលំហូរសាច់ប្រាក់ដែលកើតឡើងពីសកម្មភាពហិរញ្ញប្បទាន គឺមានសារៈសំខាន់ក្នុងការព្យាករណ៍ពីការអះអាងលើលំហូរសាច់ប្រាក់នាពេលអនាគត ដោយអ្នកផ្តល់មូលធនទៅកាន់ស្ថាប័ន។ ឧទាហរណ៍អំពីលំហូរសាច់ប្រាក់ដែលកើតឡើងពីសកម្មភាពហិរញ្ញប្បទាន គឺ÷

(ក) ចំណូលសាច់ប្រាក់ពីការបោះផ្សាយបណ្ណបំណុល, ឥណទាន, សន្លឹកកូរ៉ូបិយបណ្ណ, សញ្ញាបណ្ណ, ប្រាក់កម្ចីទិញផ្ទះ និងកម្ចីរយៈពេលខ្លី ឬកម្ចីរយៈពេលវែងផ្សេងទៀត

(ខ) ការទូទាត់សងកម្ចីជាសាច់ប្រាក់

(គ) ចំណាយសាច់ប្រាក់ដោយភតិកៈ សម្រាប់ការកាត់បន្ថយបំណុលដែលមិនទាន់បានសង ពាក់ព័ន្ធនឹងភតិសន្យាហិរញ្ញវត្ថុ និង

(ឃ) ចំណូលនិងចំណាយសាច់ប្រាក់ ពាក់ព័ន្ធនឹងការបោះផ្សាយ និងការទូទាត់សងរូបិយបណ្ណ។

**ការប្រាក់ និងភាគលាភ**

១៣. IPSAS ២ តម្រូវឱ្យមានការលាតត្រដាងដាច់ដោយឡែកអំពីលំហូរសាច់ប្រាក់ដែលកើតឡើងពីការប្រាក់និងភាគលាភដែលបានទទួលនិងបានទូទាត់។ IPSAS ២ ក៏តម្រូវផងដែរថា នៅពេលការលាតត្រដាងបែបនេះត្រូវបានធ្វើឡើង ការលាតត្រដាងគួរត្រូវបានធ្វើចំណាត់ថ្នាក់ក្នុងមធ្យោបាយមួយប្រកបដោយសង្គតិភាពពីការិយបរិច្ឆេទមួយទៅការិយបរិច្ឆេទមួយទៀត ជាសកម្មភាពប្រតិបត្តិការ, សកម្មភាពវិនិយោគ ឬសកម្មភាពហិរញ្ញប្បទាន។

១៤. ចំនួនទឹកប្រាក់សរុបនៃការប្រាក់និងភាគលាភដែលត្រូវបានទូទាត់និងបានទទួល នៅក្នុងអំឡុងការិយ-បរិច្ឆេទមួយត្រូវបានលាតត្រដាងនៅក្នុងរបាយការណ៍លំហូរសាច់ប្រាក់។ ការប្រាក់ដែលត្រូវបានទូទាត់និងការប្រាក់និងភាគលាភដែលត្រូវបានទទួល តែងតែត្រូវបានធ្វើចំណាត់ថ្នាក់ជាលំហូរសាច់ប្រាក់ប្រតិបត្តិការសម្រាប់ស្ថាប័នហិរញ្ញវត្ថុសាធារណៈមួយ។ ទោះបីជាយ៉ាងណា ពុំមានការឯកភាពណាមួយ

លើការធ្វើចំណាត់ថ្នាក់លំហូរសាច់ប្រាក់ ដែលទាក់ទងនឹងការប្រាក់និងភាគលាភដែលត្រូវបានទទួល និងត្រូវបានទូទាត់សម្រាប់ស្ថាប័នផ្សេងទៀតឡើយ។ ការប្រាក់និងភាគលាភដែលត្រូវបានទូទាត់ និងការប្រាក់និងភាគលាភដែលបានទទួល អាចត្រូវបានធ្វើចំណាត់ថ្នាក់ជាលំហូរសាច់ប្រាក់ប្រតិបត្តិការ។ ជាជម្រើសបន្ថែម ការប្រាក់និងភាគលាភដែលត្រូវបានទូទាត់ និងការប្រាក់និងភាគលាភដែលត្រូវបានទទួល អាចត្រូវបានចាត់ថ្នាក់ជាលំហូរសាច់ប្រាក់ហិរញ្ញប្បទាន និងលំហូរសាច់ប្រាក់វិនិយោគរៀងគ្នាពីព្រោះការប្រាក់និងភាគលាភទាំងនោះ គឺជាចំណាយក្នុងការទទួលបានធនធានហិរញ្ញវត្ថុ ឬចំណូលពីការវិនិយោគ។

**ការរាយការណ៍ថ្នាក់សំខាន់នៃចំណូលនិងចំណាយ**

១៥. ចំណាត់ថ្នាក់រងនៃចំណូល គឺផ្អែកទៅលើទំហំ, ចរិកលក្ខណៈ និងមុខងារនៃចំនួនទឹកប្រាក់ដែលមានការពាក់ព័ន្ធ។ ផ្អែកទៅលើចរិកលក្ខណៈរបស់ស្ថាប័ន ចំណាត់ថ្នាក់រងខាងក្រោមអាចមានភាពសមស្រប÷

(ក) ចំណូលពីពន្ធ (ចំណូលទាំងនេះអាចត្រូវបានធ្វើចំណាត់ថ្នាក់រងបន្ត ទៅជាប្រភេទពន្ធ)

(ខ) ចំណូលពីកម្រៃ, ការពិន័យ, ទោសប្បញ្ញត្តិ និងអាជ្ញាបណ្ណ

(គ) ចំណូលពីប្រតិបត្តិការប្តូរប្រាក់ រួមបញ្ចូលទាំងចំណូលពីការលក់ទំនិញនិងសេវា និងកម្រៃសេវាអ្នកប្រើប្រាស់ (នៅពេលចំណូលទាំងនេះត្រូវបានធ្វើចំណាត់ថ្នាក់ជាប្រតិបត្តិការប្តូរប្រាក់)

(ឃ) ចំណូលពីអំណោយ, ការផ្ទេរ, ឬវិភាជន៍នៃផែនការថវិកា (អាចត្រូវបានធ្វើចំណាត់ថ្នាក់ទៅតាមប្រភព) និង

(ង) ចំណូលពីការប្រាក់ និងភាគលាភ។

១៦. គណនីចំណាយត្រូវបានធ្វើចំណាត់ថ្នាក់រង ដើម្បីគួសបញ្ជាក់ពីចំណាយ និងការស្រង់ដើមមកវិញនៃកម្មវិធី, សកម្មភាពជាក់លាក់ ឬផ្នែកពាក់ព័ន្ធផ្សេងទៀតរបស់ស្ថាប័នរាយការណ៍។ ឧទាហរណ៍អំពីការធ្វើចំណាត់ថ្នាក់ចំណាយទៅតាមចរិកលក្ខណៈនិងមុខងារ ត្រូវបានរួមបញ្ចូលនៅក្នុងផ្នែកទី ១ និងផ្នែកទី ២ នៃស្តង់ដានេះ។

**ឧបសម្ព័ន្ធ ៤**

**បុគ្គលិកលក្ខណៈបែបគុណភាពនៃព័ត៌មាន ដែលត្រូវបានរួមបញ្ចូលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសម្រាប់គោលបំណងទូទៅ**

*កថាខណ្ឌ ១.៣.២៧ នៃផ្នែកទី ១ នៃស្តង់ដានេះ តម្រូវថា របាយការណ៍ហិរញ្ញវត្ថុផ្តល់នូវព័ត៌មានដែលបំពេញតាមបុគ្គលិកលក្ខណៈបែបគុណភាពនៃព័ត៌មាន ដែលត្រូវបានរួមបញ្ចូលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសម្រាប់គោលបំណងទូទៅ និងបំពេញនូវការដាក់កម្រិតលើព័ត៌មានទាំងនេះ។ ឧបសម្ព័ន្ធនេះសង្ខេបពីបុគ្គលិកលក្ខណៈបែបគុណភាព និងការដាក់កម្រិតនៃរបាយការណ៍ហិរញ្ញវត្ថុសម្រាប់គោលបំណងទូទៅ ដូចបានកំណត់នៅក្នុងកថាខណ្ឌ ១.៣.២៧។ ដើម្បីទទួលបាននូវការពន្យល់ពេញលេញមួយអំពីបុគ្គលិកលក្ខណៈបែបគុណភាពនិងការដាក់កម្រិត អ្នកអានគួរមើល "ក្របខ័ណ្ឌទស្សនទានសម្រាប់ការរាយការណ៍ហិរញ្ញវត្ថុសម្រាប់គោលបំណងទូទៅ ដោយស្ថាប័នសាធារណៈ"។*

បុគ្គលិកលក្ខណៈបែបគុណភាព គឺជាលក្ខណៈសម្បត្តិដែលធ្វើឱ្យព័ត៌មានដែលបានផ្តល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុមានសារៈសំខាន់ចំពោះអ្នកប្រើប្រាស់ និងគាំទ្រដល់ការសម្រេចបាននូវគោលបំណងនៃការរាយការណ៍ហិរញ្ញវត្ថុ។ គោលបំណងនៃការរាយការណ៍ហិរញ្ញវត្ថុ គឺដើម្បីផ្តល់ជូននូវព័ត៌មានដែលមានសារៈសំខាន់សម្រាប់គោលបំណងគណនេយ្យភាព និងការធ្វើសេចក្តីសម្រេចចិត្ត។ គោលបំណងមានការពាក់ព័ន្ធនឹងរបាយការណ៍ហិរញ្ញវត្ថុ ដោយមិនគិតពីមូលដ្ឋានគណនេយ្យដែលបានប្រើដើម្បីរៀបចំរបាយការណ៍ហិរញ្ញវត្ថុឡើយ។ បុគ្គលិកលក្ខណៈបែបគុណភាព គឺភាពដែលអាចយល់បាន, ភាពពាក់ព័ន្ធ, ការតំណាងដ៏ត្រឹមត្រូវ, ភាពទាន់ពេលវេលា, ភាពដែលអាចប្រៀបធៀបគ្នាបាន និងភាពដែលអាចបញ្ជាក់បាន។ ការដាក់កម្រិតលើព័ត៌មានដែលត្រូវបានរួមបញ្ចូលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ គឺភាពជាសារវន្ត, អត្ថប្រយោជន៍ចំណាយ, និងការសម្រេចបាននូវសមតុល្យដ៏សមស្របមួយរវាងបុគ្គលិកលក្ខណៈបែបគុណភាព។

**ភាពដែលអាចយល់បាន**

ភាពដែលអាចយល់បាន គឺជាគុណភាពព័ត៌មានដែលអនុញ្ញាតឱ្យអ្នកប្រើប្រាស់អាចយល់អំពីអត្ថន័យរបស់វា។ របាយ-ការណ៍ហិរញ្ញវត្ថុសម្រាប់គោលបំណងទូទៅ (របាយការណ៍ហិរញ្ញវត្ថុ) របស់ស្ថាប័នសាធារណៈ គួរដាក់បង្ហាញព័ត៌មានក្នុងមធ្យោបាយមួយដែលឆ្លើយតបទៅនឹងតម្រូវការនិងមូលដ្ឋានចំណេះដឹងរបស់អ្នកប្រើប្រាស់ និងចំពោះចរិកលក្ខណៈនៃព័ត៌មានដែលបានដាក់បង្ហាញ។ អ្នកប្រើប្រាស់ត្រូវបានសន្មតថាមានចំណេះដឹងសមល្មមគ្រប់គ្រាន់អំពីសកម្មភាពរបស់ស្ថាប័ន និងបរិយាកាសដែលស្ថាប័នកំពុងធ្វើប្រតិបត្តិការ និងពេញចិត្តសិក្សាពីព័ត៌មាននោះ។ ព័ត៌មានអំពីបញ្ហាស្មុគស្មាញ មិនគួរត្រូវបានដកចេញពីរបាយការណ៍ហិរញ្ញវត្ថុនោះទេ ដោយផ្អែកលើមូលដ្ឋានដែលព័ត៌មានទាំងនោះអាចមានភាពពិបាកយល់សម្រាប់អ្នកប្រើប្រាស់ជាក់លាក់មួយចំនួន ប្រសិនបើគ្មានជំនួយ។

**ភាពពាក់ព័ន្ធ**

ព័ត៌មានមានភាពពាក់ព័ន្ធ ប្រសិនបើព័ត៌មានអាចបង្កើតឱ្យមានភាពខុសប្លែកគ្នាមួយក្នុងការសម្រេចបានគោលបំណងនៃការរាយការណ៍ហិរញ្ញវត្ថុ។ ព័ត៌មានអាចបង្កើតឱ្យមានភាពខុសប្លែកគ្នាមួយ នៅពេលព័ត៌មានមានតម្លៃដែលអាច

បញ្ជាក់, តម្លៃដែលអាចពាក្យការណ៍ ឬមានទាំងពីរ។ ព័ត៌មានអាចបង្កើតឱ្យមានភាពខុសប្លែកគ្នាមួយ ហើយអាចមានភាពពាក់ព័ន្ធ សូម្បីតែអ្នកប្រើប្រាស់មួយចំនួនជ្រើសរើសមិនទាញយកផលប្រយោជន៍ពីវា ឬបានដឹងពីវារួចមកហើយក្តី។

**ការតំណាងដ៏ត្រឹមត្រូវ**

ដើម្បីធ្វើឱ្យមានសារៈសំខាន់ក្នុងការរាយការណ៍ហិរញ្ញវត្ថុ ព័ត៌មានត្រូវតែជាការតំណាងដ៏ត្រឹមត្រូវមួយនៃបាតុភូតសេដ្ឋកិច្ច និងបាតុភូតផ្សេងទៀតដែលព័ត៌មានមានបំណងតំណាងឱ្យ។ ការតំណាងដ៏ត្រឹមត្រូវអាចសម្រេចទៅបាននៅពេលដែលការបង្ហាញពីបាតុភូតនោះមានភាពពេញលេញ មិនលម្អៀង និងមិនមានកំហុសឆ្គងជាសារវន្ត។ ព័ត៌មានដែលតំណាងបាតុភូតសេដ្ឋកិច្ចមួយឬបាតុភូតផ្សេងទៀតបានយ៉ាងត្រឹមត្រូវ បង្ហាញពីសមាសធាតុនៃប្រតិបត្តិការសំខាន់ៗ និងព្រឹត្តិការណ៍ផ្សេងទៀត, សកម្មភាព, ឬស្ថានភាពដែលមិនតែងតែដូចគ្នាទៅនឹងទម្រង់ច្បាប់របស់ព័ត៌មាននោះទេ។

**ភាពដែលអាចប្រៀបធៀបគ្នាបាន**

ព័ត៌មាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុគឺអាចប្រៀបធៀបគ្នាបាន នៅពេលអ្នកប្រើប្រាស់អាចកំណត់ពីភាពស្រដៀងគ្នានិងភាពខុសគ្នារវាងសំណុំបាតុភូតពីរ។ ភាពដែលអាចប្រៀបធៀបគ្នាបាន គឺមិនមែនជាគុណភាពនៃគណនីព័ត៌មាននីមួយៗនោះទេ ប៉ុន្តែ វាគឺជាគុណភាពនៃទំនាក់ទំនងរវាងគណនីព័ត៌មានពីរ ឬច្រើន។

ភាពដែលអាចប្រៀបធៀបគ្នាបាន អនុវត្តចំពោះ÷

- ការប្រៀបធៀបរបាយការណ៍ហិរញ្ញវត្ថុរបស់ស្ថាប័នផ្សេងគ្នា និង
- ការប្រៀបធៀបរបាយការណ៍ហិរញ្ញវត្ថុរបស់ស្ថាប័នតែមួយ សម្រាប់ការិយបរិច្ឆេទបន្តបន្ទាប់។

លទ្ធផលសំខាន់មួយនៃបុគ្គលិកលក្ខណៈនៃភាពដែលអាចប្រៀបធៀបគ្នាបានគឺថា អ្នកប្រើប្រាស់ចាំបាច់ត្រូវទទួលបានការជូនព័ត៌មានអំពីគោលនយោបាយដែលបានប្រើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ,ការផ្លាស់ប្តូរគោលនយោបាយទាំងនោះ និងឥទ្ធិពលនៃការផ្លាស់ប្តូរទាំងនោះ។

ដោយអ្នកប្រើប្រាស់ចង់ធ្វើការប្រៀបធៀបលទ្ធផលប្រតិបត្តិការរបស់ស្ថាប័នមួយជាបន្តបន្ទាប់ វាពិតជាមានសារៈសំខាន់ដែលរបាយការណ៍ហិរញ្ញវត្ថុបង្ហាញពីព័ត៌មានត្រូវគ្នា សម្រាប់ការិយបរិច្ឆេទមុនៗ។

**ភាពទាន់ពេលវេលា**

ភាពទាន់ពេលវេលា មានន័យថា ការមានព័ត៌មានសម្រាប់អ្នកប្រើប្រាស់ មុនពេលដែលព័ត៌មានបាត់បង់ភាពមានសារៈសំខាន់របស់ខ្លួន សម្រាប់គោលបំណងគណនេយ្យភាព និងការធ្វើសេចក្តីសម្រេចចិត្ត។ ការមានព័ត៌មានពាក់ព័ន្ធបានឆាប់រហ័សអាចធ្វើឱ្យប្រសើរឡើងនូវភាពមានសារៈសំខាន់របស់វា ជាធាតុចូលចំពោះការវាយតម្លៃលើគណនេយ្យភាពនិងសមត្ថភាពរបស់វា ដើម្បីជួនដំណឹង និងជះឥទ្ធិពលដល់ការសម្រេចចិត្តដែលចាំបាច់ត្រូវធ្វើឡើង។ ការខ្វះភាពទាន់ពេលវេលា អាចធ្វើឱ្យព័ត៌មានលែងសូវមានសារៈសំខាន់។

**ភាពដែលអាចបញ្ជាក់បាន**

ភាពដែលអាចបញ្ជាក់បាន គឺជាគុណភាពព័ត៌មានដែលជួយធានាដល់អ្នកប្រើប្រាស់ថា ព័ត៌មាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុតំណាងបាតុភូតសេដ្ឋកិច្ចមួយ ឬបាតុភូតផ្សេងទៀតបានយ៉ាងត្រឹមត្រូវដែលវាមានបំណងដើម្បីតំណាងឱ្យ។ ភាពដែលអាចគាំទ្របាន គឺពេលខ្លះត្រូវបានប្រើដើម្បីពិពណ៌នាអំពីគុណភាពនេះ នៅពេលត្រូវបានអនុវត្តទាក់ទងនឹងព័ត៌មានពន្យល់ និងព័ត៌មានបែបគុណភាពហិរញ្ញវត្ថុនិងមិនមែនហិរញ្ញវត្ថុ ដែលបានលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ មិនថាសំដៅទៅលើភាពដែលអាចបញ្ជាក់បាន ឬភាពដែលអាចគាំទ្របាន បុគ្គលិកលក្ខណៈបញ្ជាក់ថាអ្នកស៊ើបអង្កេតដែលមានចំណេះដឹងនិងឯករាជ្យផ្សេងៗគ្នា អាចឈានដល់ការឯកភាពជាទូទៅ បើទោះបីជាមិនបានបំពេញតាមកិច្ចព្រមព្រៀងដែល÷

- ព័ត៌មានតំណាងឱ្យបាតុភូតសេដ្ឋកិច្ចនិងបាតុភូតផ្សេងទៀតដែលវាមានបំណងដើម្បីតំណាងឱ្យ ដោយគ្មានកំហុសឆ្គងជាសារវ័ន្ត ឬភាពលម្អៀង ឬ
- មធ្យោបាយនៃការទទួលស្គាល់, ការវាស់វែង ឬមធ្យោបាយនៃការតំណាងសមស្របមួយ ត្រូវបានអនុវត្ត ដោយគ្មានកំហុសឆ្គងជាសារវ័ន្ត ឬភាពលម្អៀង។

**ការដាក់កម្រិតលើព័ត៌មានដែលត្រូវបានរួមបញ្ចូលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសម្រាប់គោលបំណងទូទៅ**

*ភាពជាសារវ័ន្ត*

ព័ត៌មានមានភាពជាសារវ័ន្ត ប្រសិនបើការលុបឬការអះអាងខុស អាចជះឥទ្ធិពលដល់ការទទួលខុសត្រូវគណនេយ្យភាពរបស់ស្ថាប័ន ឬការធ្វើសេចក្ដីសម្រេចចិត្តដែលអ្នកប្រើប្រាស់ធ្វើឡើង ផ្អែកលើមូលដ្ឋាននៃរបាយការណ៍ហិរញ្ញវត្ថុរបស់ស្ថាប័នដែលត្រូវបានរៀបចំឡើងសម្រាប់ការិយបរិច្ឆេទរាយការណ៍នោះ។ ភាពជាសារវ័ន្តអាស្រ័យលើទាំងចរិកលក្ខណៈ និងចំនួនគណនីដែលត្រូវបានវិនិច្ឆ័យនៅក្នុងស្ថានភាពជាក់លាក់របស់ស្ថាប័ននីមួយៗ។

*សមតុល្យរវាងអត្ថប្រយោជន៍ និងចំណាយ*

សមតុល្យរវាងអត្ថប្រយោជន៍និងចំណាយ គឺជាការដាក់កម្រិតមួយ។ អត្ថប្រយោជន៍ដែលបានទទួលពីព័ត៌មានគួរផ្ដល់ហេតុផលបញ្ជាក់ពីចំណាយនៃការផ្ដល់ព័ត៌មាននោះ។ ការវាយតម្លៃថាតើអត្ថប្រយោជន៍នៃការផ្ដល់ព័ត៌មានផ្ដល់ហេតុផលបញ្ជាក់ពីចំណាយពាក់ព័ន្ធ គឺតែងតែជាបញ្ហាមួយនៃការវិនិច្ឆ័យ ពីព្រោះវាគឺតែងតែមិនអាចទៅរួច ដើម្បីកំណត់ និង/ឬកំណត់ជាចំនួនចំណាយនិងអត្ថប្រយោជន៍ទាំងអស់នៃព័ត៌មានដែលត្រូវបានរួមបញ្ចូលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ចំណាយនៃការផ្ដល់ព័ត៌មាន រួមបញ្ចូលទាំងចំណាយនៃការប្រមូលនិងការដំណើរការព័ត៌មាន, ចំណាយនៃការផ្ទៀងផ្ទាត់ព័ត៌មាន និង/ឬ ការដាក់បង្ហាញការសន្ទូត និងវិធីសាស្ត្រដែលគាំទ្រព័ត៌មាន និងចំណាយនៃការផ្សព្វផ្សាយព័ត៌មានទាំងនោះ។ អ្នកប្រើប្រាស់បង្កើតឱ្យមានចំណាយនៃការវិភាគ និងការបកស្រាយ។

អ្នករៀបចំរបាយការណ៍បង្កើនការខិតខំប្រឹងប្រែងដើម្បីផ្ដល់នូវព័ត៌មាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ ទោះបីជាយ៉ាងណា គម្យជនសេវានិងអ្នកផ្ដល់ធនធាន ចុងក្រោយត្រូវរ៉ាប់រងចំណាយនៃការខិតខំប្រឹងប្រែងទាំងនោះ ពីព្រោះធនធានត្រូវបានផ្លាស់ប្ដូរទិសដៅពីសកម្មភាពនៃការផ្ដល់សេវា ទៅជាការរៀបចំព័ត៌មានសម្រាប់រួមបញ្ចូលនៅក្នុងរបាយការណ៍

ហិរញ្ញវត្ថុ។ អ្នកប្រើប្រាស់ទាញយកអត្ថប្រយោជន៍ភាគច្រើនពីព័ត៌មានដែលបានផ្តល់ដោយរបាយការណ៍ហិរញ្ញវត្ថុ។ ទោះបីជាយ៉ាងណា ព័ត៌មានដែលត្រូវបានរៀបចំឡើងសម្រាប់របាយការណ៍ហិរញ្ញវត្ថុ ក៏អាចត្រូវបានប្រើផ្ទៃក្នុងដោយថ្នាក់ដឹកនាំ និងឱ្យផលជាការធ្វើសេចក្តីសម្រេចចិត្តបានកាន់តែប្រសើរដោយថ្នាក់ដឹកនាំ។

ក្នុងការអភិវឌ្ឍស្តង់ដាគណនេយ្យអន្តរជាតិសម្រាប់វិស័យសាធារណៈ ក្រុមប្រឹក្សាភិបាលស្តង់ដាគណនេយ្យអន្តរជាតិសម្រាប់វិស័យសាធារណៈពិចារណាព័ត៌មានដែលទទួលបានពីអ្នករៀបចំរបាយការណ៍, អ្នកប្រើប្រាស់, ក្រុមអ្នកសិក្សា និងបុគ្គលផ្សេងទៀត អំពីចរិកលក្ខណៈដែលបានរំពឹងទុក និងចំនួនអត្ថប្រយោជន៍ និងចំណាយនៃលក្ខខណ្ឌចាំបាច់ដែលបានស្នើ។ ការលាតត្រដាងនិងលក្ខខណ្ឌចាំបាច់ផ្សេងទៀតដែលឱ្យផលជាការដាក់បង្ហាញព័ត៌មានដែលមានសារៈសំខាន់ចំពោះអ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុសម្រាប់គោលបំណងគណនេយ្យភាព និងការធ្វើសេចក្តីសម្រេចចិត្ត និងបំពេញតាមបុគ្គលិកលក្ខណៈបែបគុណភាព ត្រូវបានកំណត់ដោយស្តង់ដាគណនេយ្យអន្តរជាតិសម្រាប់វិស័យសាធារណៈ នៅពេលដែលអត្ថប្រយោជន៍នៃការអនុលោមតាមការលាតត្រដាងនិងលក្ខខណ្ឌចាំបាច់ទាំងនោះ ត្រូវបានវាយតម្លៃដោយក្រុមប្រឹក្សាភិបាលស្តង់ដាគណនេយ្យអន្តរជាតិសម្រាប់វិស័យសាធារណៈ ដើម្បីផ្តល់ហេតុផលបញ្ជាក់ពីចំណាយទាំងនោះ។

*សមតុល្យរវាងបុគ្គលិកលក្ខណៈបែបគុណភាព*

បុគ្គលិកលក្ខណៈបែបគុណភាពធ្វើការជាមួយគ្នាដើម្បីបង្កើតឱ្យមានភាពមានសារៈសំខាន់នៃព័ត៌មាន។ នៅក្នុងករណីមួយចំនួន តុល្យភាពឬការដោះដូរអត្ថប្រយោជន៍រវាងបុគ្គលិកលក្ខណៈបែបគុណភាព អាចចាំបាច់ដើម្បីសម្រេចបាននូវគោលបំណងនៃការរាយការណ៍ហិរញ្ញវត្ថុ។ សារៈសំខាន់ពាក់ព័ន្ធនៃបុគ្គលិកលក្ខណៈបែបគុណភាពនៅក្នុងស្ថានភាពនីមួយៗគឺជាបញ្ហាមួយនៃការវិនិច្ឆ័យបែបវិជ្ជាជីវៈ។ គោលបំណងគឺដើម្បីសម្រេចបាននូវសមតុល្យសមស្របមួយក្នុងចំណោមបុគ្គលិកលក្ខណៈផ្សេងៗ ដើម្បីបំពេញតាមគោលបំណងនៃការរាយការណ៍ហិរញ្ញវត្ថុ។



បញ្ចប់

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : ១២៥.ក.ស.ក.ឧ.ប.ត.០៤

ថ្ងៃ.សុក្រ.១៤ រោច.....ខែ.ភាទ.. ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី...០៤..... ខែ.កញ្ញា.. ឆ្នាំ២០១៩

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/ ០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- យោងលិខិតលេខ ១៥៦/១៩ គ.វ.ក ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៩ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញសំណើសុំប្រកាសបង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៩ របស់ក្រុមហ៊ុន អិល ស៊ី ហ្គាមុិន (ខេមបូឌា) ឯ.ក

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន អិល ស៊ី ហ្គាមុិន (ខេមបូឌា) ឯ.ក (L C GARMENT (CAMBODIA) CO., LTD.) តំណាងដោយលោក **SHI, JIANFENG** បង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ ដែលមានទីតាំងស្ថិតនៅ ភូមិត្រពាំងមាន ឃុំស្នំក្រពើ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ។



៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥)-២៣-២១១១៤១ , ទូរសារ : (៨៥៥)-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141, Fax: 855-23-428263

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| សម្លៀកបំពាក់ | ១៤១០ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកផ្ទាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះ រោងចក្រ និងសិប្បកម្ម។

**ផ្ទាកឈ្មោះរោងចក្រ៖** " រោងចក្រកាត់ដេរសម្លៀកបំពាក់ អិល ស៊ី ហ្គាមុិន (ខេមបូឌា) ឯ.ក "

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទបញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព ០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណី ប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្របតាមមាត្រា១៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រង រោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល ០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណី រោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល ០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និង តាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តកំពង់ស្ពឺ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
**រដ្ឋលេខាធិការ**

**ហាន សុភា**

**ទទួលខុសនៃ**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងបរិស្ថាន
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-អគ្គនាយកដ្ឋានរាជកិច្ច និងតម្កល់ឯកសារជាតិ
-វិទ្យាស្ថានស្តង់ដារកម្ពុជា
-មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
-សាលាខេត្តកំពង់ស្ពឺ
-មន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តកំពង់ស្ពឺ
-រដ្ឋបាលស្រុកគងពិសី
-រដ្ឋបាលឃុំស្វ៊ីក្រពើ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៨ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ ...

ថ្ងៃ... ... ...

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| ស្បែក (កែច្នៃ) | ១៥១១ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកផ្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះ រោងចក្រ និងសិប្បកម្ម។

**ផ្លាកឈ្មោះរោងចក្រ៖** " រោងចក្រកែច្នៃស្បែក ខេមបូឌាន រ៉ូម អ៊ិនដាសស្ត្រៀល ឯ.ក "

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទបញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព ០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើការផ្លាស់ប្តូរទីតាំងការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណី ប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ម្រាមាសខ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្របតាមមាត្រា១៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមដំពូកទី៣នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។ ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួល ហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាម មាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល ០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណី រោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល ០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និង តាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តព្រះសីហនុ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការ រៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
**រដ្ឋលេខាធិការ**

**ហាន សុតា**

**ចម្លងជូន៖**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងបរិស្ថាន
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-អគ្គនាយកដ្ឋានពាណិជ្ជកិច្ច និងតម្លៃឯកសារជាតិ
-វិទ្យាស្ថានស្តង់ដារកម្ពុជា
-មជ្ឌលមណ្ឌលមាត្រាសាស្ត្រជាតិ
-សាលាខេត្តព្រះសីហនុ
-មន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តព្រះសីហនុ
-អង្គភាពរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស ខេមបូឌាន ចេជាង ហ្គ័ដើ
-រដ្ឋបាលស្រុកព្រៃនប់
-រដ្ឋបាលឃុំជើងគោ
"ដើម្បីជូនជ្រាប"
-ផ្ទៃប្រការ១៨ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

សូមរក្សាសិទ្ធិនិងបោះពុម្ពដោយនាយកដ្ឋានរាជកិច្ច នៃ
អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ
ទីស្តីការគណៈរដ្ឋមន្ត្រី